# មុខវិជ្ជា៖
# វិធីសាស្ត្រស្រាវជ្រាវ

## កញ្ចប់សមត្ថភាពទី ១
## ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រជាន់ខ្ពស់

## ការពណ៌នាអំពីមុខវិជ្ជា

មុខវិជ្ជានេះត្រូវបានរៀបចំឡើងដើម្បីឲ្យនិស្សិតស្វែងយល់ និងអាចអនុវត្តបាននូវ ការបង្កើតចំណេះដឹងថ្មី ឬដំណោះស្រាយថ្មីចំពោះបញ្ហាដែលកើតមានឡើងចំពោះមុខគ្រូបង្រៀននៅក្នុងថ្នាក់រៀន ។ ដែលចំណេះដឹងថ្មី ឬដំណោះស្រាយថ្មីអាចជាវិធីសាស្ត្របង្រៀន ការបង្កើតបរិយាកាសនៅក្នុងថ្នាក់រៀន សកម្មភាពនៃការបង្រៀននិងរៀន ទំនាក់ទំនងរវាងគ្រូសិស្ស ទំនាក់ទំនងរវាងសិស្សនិងសិស្សប្រយោជន៍ដើម្បីឈានទៅកាន់លទ្ធផលសិក្សារំពឹងទុកដែលបានកំណត់ទុកដោយកម្មវិធីសិក្សានិងមេរៀននីមួយៗ

## លទ្ធផលសិក្សារំពឹងទុកៈ

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹងៈ*

លទ្ធផលសិក្សារំពឹងទុកទី១ៈ ពន្យល់បានពីការធ្វើគំរូស្រាវជ្រាវប្រតិបត្តិនៅក្នុងថ្នាក់រៀន

លទ្ធផលសិក្សារំពឹងទុកទី២ៈកំណត់បានបញ្ហាជាក់លាក់ចេញពីការអនុវត្តជាក់ស្តែងនៅក្នុងថ្នាក់រៀន។

លទ្ធផលសិក្សារំពឹងទុកទី ៣ៈ កំណត់បាននូវដំណោះស្រាយតាមលក្ខណវិទ្យាសាស្ត្រដែលអាចជឿទុកចិត្តបាន។

លទ្ធផលសិក្សារំពឹងទុកទី ៤ៈ រៀបចំផែនការដើម្បីអនុវត្តនូវលទ្ធផលសិក្សាស្រាវជ្រាវដែលបានរកឃើញ។

លទ្ធផលសិក្សារំពឹងទុកទី ៥ៈ អាចធ្វើការស្រាវជ្រាវប្រតិបត្តនៅក្នុងថ្នាក់រៀនបានត្រឹមត្រូវ។

## របាយតម្លៃសិក្សា

*ដើម្បីបំពេញគ្រប់លក្ខខណ្ឌបញ្ចប់ការសិក្សាមុខវិជ្ជានេះ អ្នកសិក្សាត្រូវ*

១. វត្តមានចូលសិក្សា ១០%

២. ការចូលរួមសកម្មភាពសិក្សា ២០%

៣. ការវាយតម្លៃកំឡុងពេលសិក្សា ៣០%

៤. ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា ៤០%

# អារម្ភកថា

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្នុងចំណុចចតុកោណទី១ បានកំណត់យក "ការអភិវឌ្ឍធនធានមនុស្ស" មុំទី១ជាវិស័យអាទិភាព។ សាកលវិទ្យាល័យ-ភូមិន្ទភ្នំពេញដើរតួនាទីយ៉ាងសំខាន់ជាចំណែកមួយនៃការកែទម្រង់វិស័យអប់រំក្នុងការស្តារប្រព័ន្ធអប់រំជាតិឡើងវិញ តាមរយៈការផលិតអ្នកអប់រំដែលមានគុណភាពខ្ពស់។

នៅដើមអាណត្តិទី៦នេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់ វិស័យអប់រំ ២០១៨-២០២៣ ដែលមានចក្ខុវិស័យ "កសាង និងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្នែកចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន"។ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក៏បានលើកឡើងពីតួនាទីយ៉ាងសំខាន់របស់គ្រូបង្រៀនក្នុងវិស័យអប់រំ និងសង្គមជាតិ ដោយបញ្ជាក់ថា "គុណភាពគ្រូ ជាគុណភាពមូលធនមនុស្ស សម្រាប់ ការអភិវឌ្ឍប្រកបដោយចីរភាព" ដែលប្រែក្លាយប្រទេសមានប្រាក់ចំណូល មធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងប្រទេសអភិវឌ្ឍន៍ក្នុងឆ្នាំ២០៥០។

ដើម្បីឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រ និងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយនឹងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានទទួលភារកិច្ចបន្ថែមទៀត តាមរយៈការអនុវត្តគម្រោងកែលម្អការអប់រំនៅកម្រិតមធ្យមសិក្សា និងបន្តអនុវត្តគម្រោងកែលម្អការអប់រំចំណេះទូទៅរយៈពេលបួនឆ្នាំបន្ថែមទៀត ចាប់ពីឆ្នាំ២០២២-២០២៦។ ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាបានដឹកនាំ និងផ្តល់អនុសាសន៍យ៉ាងច្រើន ដែលធ្វើឱ្យគម្រោងប្រព្រឹត្តទៅដោយរលូន និង ជោគជ័យ។

គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សារៀបចំឡើង ដើម្បីលើកកម្ពស់គុណវុឌ្ឍិគ្រូឯកទេសលើមុខវិជ្ជាគោល៦ តាមគ្រឹះស្ថានមធ្យមសិក្សាគោលដៅ។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញទទួលបណ្តុះបណ្តាលក្របខណ្ឌកម្មវិធីកម្រិតបរិញ្ញាបត្រអប់រំដល់នាយកសាលារៀន និងគ្រូឯកទេសដែលពុំទាន់មានសញ្ញាបត្របរិញ្ញាបត្រ ឬមានសញ្ញាបត្រខុសឯកទេសនៅតាមគ្រឹះស្ថានមធ្យមសិក្សាចំនួន១០០ នៅក្នុងគោលដៅគម្រោងនៅប្រទេសកម្ពុជា។ ដើម្បីពង្រីកវិសាលភាពនៃកំណែទម្រង់អប់រំ គម្រោងកែលម្អការអប់រំចំណេះទូទៅ ដែលប្រើប្រាស់យុទ្ធសាស្ត្រសហគមន៍សាលារៀនជាយុទ្ធសាស្ត្រស្នូលក្នុងការអនុវត្ត បានលេចរូបរាងឡើងក្នុងគោលបំណងបណ្តុះបណ្តាលនាយកសាលា និងគ្រូបង្រៀនចំនួនប្រមាណ ១៧០០០ នាក់ ដែលមកពី ១៧០០សាលា ក្នុងអនុវិស័យបី រួមមាន កុមារតូច បឋមសិក្សា និងមធ្យមសិក្សា។ មហាវិទ្យាល័យអប់រំក៏ត្រូវសហការផងដែរ ជាមួយស្ថាប័ន បណ្តុះបណ្តាលគ្រូទាំងអស់ ដើម្បីឈានទៅបង្កើតស្តង់ដាគុណភាពរួមមួយក្នុងការអប់រំគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលាឱ្យបានទូលំទូលាយ។ ដើម្បីឈានទៅសម្រេចបានការអនុវត្តគម្រោងថ្មីនេះ មហាវិទ្យាល័យត្រូវមានយុទ្ធសាស្ត្ររយៈពេលវែងមួយ សម្រាប់ឆ្នាំ ២០២១-២០៣០ ដើម្បីជាមគ្គុទេសបង្ហាញផ្លូវ។

សៀវភៅសិក្សាគោលយុទ្ធសាស្ត្រសហគមន៍សាលារៀននេះ បានរៀបចំឡើងជាការឆ្លើយតបជាមួយតម្រូវការដែលអ្នកសិក្សាជានាយក និងគ្រូបង្រៀនក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅដើម្បីធ្វើការស្វ័យសិក្សាលើខ្លឹមសារសំខាន់ៗ នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន ដែលការស្វ័យសិក្សានេះបានភ្ជាប់មកជាមួយសំណួរស្វ័យសិក្សា ដែល

បញ្ជាក់ពីកម្រិតយល់ដឹងពីខ្លឹមសារគោលនីមួយៗនៃយុទ្ធសាស្ត្រសហគមន៍សាលារៀន។ តាមរយៈសៀវភៅសិក្សាគោលនេះ អ្នកសិក្សាក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) និងគ្រឹះស្ថានបណ្ដុះបណ្ដាលឯទៀតអាចយកជាប្រយោជន៍ក្នុងការអនុវត្តកំណែទម្រង់សាលារៀន ដែលយកសហគមន៍ជាធនធានគោល ដើម្បីអភិវឌ្ឍន៍សាលារៀនឱ្យឈានទៅរកសាលារៀនជាប់ស្តង់ដាសហគមន៍សាលារៀន។

ទន្ទឹមនឹងនេះ វាជាឯកសារដែលឆ្លុះបញ្ចាំងពីមេរៀន បទពិសោធន៍នៃការអនុវត្ត និងផលសម្រេចជាក់ស្ដែង និងជាឯកសាររស់ដែលមានលក្ខណៈបើកទូលាយឱ្យមានការកែលម្អបន្តផ្អែកលើការរៀនពីការអនុវត្ត ដែលនាំមកនូវលទ្ធផលវិជ្ជមាន។ ឯកសារនេះមានខ្លឹមសារ ដែលជាអត្ថប្រយោជន៍សម្រាប់ប្រើប្រាស់ក្នុងពេល ដែលបានអនុវត្តន៍កន្លងមក និងបន្តប្រើប្រាស់ក្នុងពេលបច្ចុប្បន្ន ហើយអាចនឹងប្រើប្រាស់សម្រាប់អនាគត ឬអាចនឹងកែសម្រួលបន្ថែមឱ្យសមស្របតាមកាលៈទេសៈ និងល្បឿននៃការអភិវឌ្ឍក្នុងសង្គមជាតិ។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញមានជំនឿយ៉ាងមុតមាំ ក្នុងការរៀបចំក្របខណ្ឌកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ក្រោមគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាពិតជាដើរតួនាទីយ៉ាងសំខាន់ និងឆ្លើយតបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការសាងធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងក្រមសីលធម៌។ យើងនឹងបន្តការខិតខំប្រឹងប្រែងក្នុងការអនុវត្តគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) ឱ្យបានកាន់តែប្រសើរជាមួយនឹងសៀវភៅសិក្សាគោលយុទ្ធសាស្ត្រសហគមន៍សាលារៀន និងឧត្តមានុវត្តន៍ផ្សេងៗដែលបានចងក្រង។

ខ្ញុំសូមថ្លែងអំណរគុណ និងសូមកោតសរសើរចំពោះក្រុមការងារដែលបានខិតខំកសាងក្របខណ្ឌកម្មវិធីឱ្យទទួលបានលទ្ធផលល្អ។

ថ្ងៃ ពុធ ១៤ រោច ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៧ខែ កក្កដា ឆ្នាំ២០២២
**សាកលវិទ្យាធិការ**

**បណ្ឌិត ជេត ជាលី**

# អនុវត្ត រៀនសូត្រ សម្របនិងឆ្លើយតបតាមតម្រូវការសិក្សា អភិវឌ្ឍ តាមការអភិវឌ្ឍ នវានុវត្តន៍ ដោះស្រាយជាបន្ត នូវភាពក្រីក្ររៀនសូត្រ ភាពក្រីក្រសង្គម និង ភាពក្រីក្ររូបិយវត្ថុ»

"Apply, Learn, Adapt, Teach, and Develop Addressing Learning Poverty, Social Poverty, and Monetary Poverty"

## ព័ត៌មានសង្ខេប

| កម្មវិធីសិក្សា | |
|---|---|
| ក្របខណ្ឌគុណវុឌ្ឍិ | កម្រិត ៧/ កម្រិតសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់អប់រំ |
| មហាវិទ្យាល័យ | មហាវិទ្យាល័យអប់រំ |
| កម្មវិធី | កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន |
| ឯកទេស ឬជំនាញ | (១)ឯកទេសគ្រប់គ្រងអប់រំ និងយុទ្ធសាស្ត្រសហគមន៍សាលារៀនកម្រិតមធ្យមសិក្សា |
| ចំនួនក្រេឌីត | ៤៨ |
| កាលបរិច្ឆេទពិនិត្យឡើងវិញ | ១៧ មីនា ២០២៣ |

## ឈ្មោះកម្មវិធី និងសញ្ញាបត្រ

ឯកទេសបរិញ្ញាបត្រជាន់ខ្ពស់អប់រំសម្រាប់កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន

| កម្រិតសញ្ញាបត្រ | ឯកទេស |
|---|---|
| បរិញ្ញាបត្រជាន់ខ្ពស់អប់រំ<br>Master of Education<br>(M.Ed) | ឯកទេសគ្រប់គ្រងអប់រំ និងយុទ្ធសាស្ត្រសហគមន៍សាលារៀនកម្រិតមធ្យមសិក្សា<br>(Educational Administration and School Community Strategy in Secondary Education) |

## លទ្ធផលសិក្សារំពឹងទុក

ការសិក្សាក្នុងកម្មវិធីនេះគឺផ្តោតលើប្រតិបត្តិជាក់ស្តែងរបស់អ្នកសិក្សាដែលអនុវត្តផ្ទាល់នៅសាលារៀន។ ទាំងអ្នកសិក្សា និងសិស្ស (ដែលអ្នកសិក្សានឹងធ្វើការជាមួយផ្ទាល់) ចាំបាច់មាន (១) ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ (២) ចំណេះដឹងវិធីសាស្ត្រដឹកនាំនិងគ្រប់គ្រងតាមសាលារៀន (៣) ហ្វឹកហាត់កម្មសិក្សា និងដឹកនាំការអនុវត្តជាក់ស្តែង។ កញ្ចប់សមត្ថភាពទាំងបីខាងលើនឹងជួយឱ្យគរុនិស្សិត អភិវឌ្ឍបំណិនចិត្តសង្គម បំណិនពុទ្ធិ និងអភិពង្រឹងសមត្ថភាពផ្នែក (ក) ការសម្រេចចិត្ត ទំនាក់ទំនង សេចក្តីអំណត់ ទឹកចិត្តអាណិតអាសូរ និងការគ្រប់គ្រងខ្លួនឯង ថែមទាំងអាចអនុវត្តការបង្រៀនប្រកបដោយវិជ្ជាជីវៈ និងនវានុវត្តន៍ដោយប្រើប្រាស់ឧត្តមានុវត្តន៍ផ្សេងៗ។ ដូចគ្នាផងដែរ កញ្ចប់សមត្ថភាពបីខាងលើ នឹងនាំឱ្យអ្នកសិក្សាអភិវឌ្ឍសមត្ថភាពផ្នែក (ខ) ការដោះស្រាយបញ្ហា និង ការរៀបចំនិងការចាត់ចែង (គ) បច្ចេកទេសកម្រិតមធ្យម និងកម្រិតខ្ពស់។




## សម្រាប់ឯកទេសគ្រប់គ្រងអប់រំ និងយុទ្ធសាស្ត្រសហគមន៍សាលារៀន (មធ្យមសិក្សា)

លទ្ធផលសិក្សារំពឹងទុកសម្រាប់បរិញ្ញាបត្រជាន់ខ្ពស់អប់រំឯកទេសគ្រប់គ្រងអប់រំ និងយុទ្ធសាស្ត្រសហគមន៍ សាលារៀនត្រូវបានកំណត់ដូចខាងក្រោម៖

***ចំណេះដឹង/វិជ្ជាសម្បទា***

PLO1-A ពន្យល់ស៊ីជម្រៅអំពីទ្រឹស្តី ទស្សនាទាន និងគោលការណ៍នៃការអប់រំក្នុងបរិបទសាកលលោក និងបរិបទប្រទេសដើម្បីឆ្លុះបញ្ចាំងទៅនឹងការអនុវត្តជាក់ស្តែង។

PLO2-A បកស្រាយស៊ីជម្រៅអំពីដំណើរការអនុវត្តកិច្ចការសម្រាប់ការបង្វឹកសាលារៀនឱ្យមានសមត្ថភាពអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀនប្រកបដោយប្រសិទ្ធភាព។

PLO3-A យល់ដឹងស៊ីជម្រៅអំពីបំណិនចិត្តសង្គម និងបច្ចេកវិទ្យាឌីជីថលសម្រាប់បង្កើនការប្រាស្រ័យទាក់ទងគ្នាក្នុងការងារ និងជីវភាពប្រកបដោយវិជ្ជាជីវៈ និងដោះស្រាយបញ្ហាប្រកបដោយភាពច្នៃប្រឌិត និងការទទួលខុសត្រូវ។

PLO4- ប្រើប្រាស់យន្តការ និងមធ្យោបាយសម្រាប់ដឹកនាំ និងគ្រប់គ្រងសាលារៀនដោយផ្តោតលើផលសម្រេចនៃការសិក្សារបស់សិស្សឆ្ពោះទៅរកស្តង់ដាសាលារៀនមានប្រសិទ្ធភាព និងនិរន្តភាពសាលារៀនតាមរយៈការសិក្សា និងការអនុវត្តជាក់ស្តែង។

PLO5- អនុវត្តការងារដឹកនាំ ការងារគ្រប់គ្រង ការងារប្រឹក្សាគរុកោសល្យ កម្មវិធីរកចំណូល និងកម្មវិធីជានាវ៉ាប់រងសង្គមសម្រាប់សាលារៀនប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

***ឥរិយាបថ/ចរិយាសម្បទា***

PLO6-A មានឥរិយាបថវិជ្ជមាន និងវប្បធម៌រៀនពេញមួយជីវិតសម្រាប់បំពេញការងារ និងទាក់ទងជាមួយអ្នកដទៃប្រកបដោយគុណតម្លៃ មនុស្សធម៌ សាមគ្គីភាព និងការចែករំលែកគ្នា។

PLO7-A សហការណ៍ជាមួយបណ្តាញសម្រាប់កសាងភ្នាក់ងារពង្រីកឧត្តមានុវត្តន៍សម្រាប់ការគ្រប់គ្រងអប់រំ។

PLO8-A មានជំនាញឌីជីថល និងជំនាញទន់ដទៃទៀត

***ជំនាញ/បំណិនសម្បទា***

...........................................

## អាជីពរំពឹងទុក

ឱកាសការងារសម្រាប់អ្នកដែលបញ្ចប់ការសិក្សាដោយជោគជ័យពីកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់អប់រំសម្រាប់អនុវិស័យមធ្យមសិក្សាតាមការជ្រើសរើសឯកទេសរបស់និស្សិត/អ្នកសិក្សា៖

*សម្រាប់ឯកទេសគ្រប់គ្រងអប់រំ និងយុទ្ធសាស្ត្រសហគមន៍សាលារៀន*

- នាយកសាលារៀន/គណៈគ្រប់គ្រងសាលារៀន
- មន្ត្រីអប់រំផ្នែកដឹកនាំ និងគ្រប់គ្រង
- ទីប្រឹក្សាគរុកោសល្យសម្រាប់គណៈគ្រប់គ្រងសាលារៀន
- អ្នកអប់រំសហគ្រិនភាព
- អ្នកស្រាវជ្រាវផ្នែកភាពអ្នកដឹកនាំ និងការគ្រប់គ្រងអប់រំ

## លក្ខខណ្ឌនៃការជ្រើសរើសចូលសិក្សា

ការដាក់ពាក្យចូលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំដូចបានកំណត់ខាងក្រោម៖

- មានសញ្ញាបត្របរិញ្ញាបត្រអប់រំពីកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន
- មានចំណេះដឹងភាសាអង់គ្លេស
- ទទួលលទ្ធផលជាប់ក្នុងការប្រឡងចូលសិក្សា

## លក្ខខណ្ឌតម្រូវសម្រាប់បញ្ចប់ការសិក្សា និងច្រកចេញដើម្បីទទួលគុណវុឌ្ឍិ

ក្រោយពីបំពេញគ្រប់លក្ខខណ្ឌក្នុងការបញ្ចប់ការសិក្សាដោយជោគជ័យ និស្សិត/អ្នកសិក្សានឹងទទួលបានសញ្ញាបត្រកម្រិតបរិញ្ញាបត្រជាន់ខ្ពស់អប់រំតាមឯកទេសដែលនិស្សិត/អ្នកសិក្សាបានជ្រើសរើសដែលចេញដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

ដើម្បីបញ្ចប់ការសិក្សាដោយជោគជ័យ និស្សិត/អ្នកសិក្សាត្រូវគោរពតាមបញ្ញាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បង្ហាញវត្តមាន (ដោយផ្ទាល់ និងពីចម្ងាយ/អនឡាញ)យ៉ាងតិច ៧០%
- បំពេញការសិក្សាមុខវិជ្ជាឯកទេសកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ២៧ ក្រេឌីត
- បំពេញមុខវិជ្ជាចំណេះដឹងវិធីសាស្ត្រដឹកនាំនិងគ្រប់គ្រងតាមសាលារៀន ៩ (+៣) ក្រេឌីត
- ហ្វឹកហាត់កម្មសិក្សា និងដឹកនាំការអនុវត្តជាក់ស្តែង ៩ ក្រេឌីត

## កញ្ចប់សមត្ថភាព និងរចនាសម្ព័ន្ធកម្មវិធីសិក្សា

កម្មវិធីសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់អប់រំមានចំនួន ៤៨ ក្រេឌីត ដោយបញ្ចូលការសិក្សាលើមុខវិជ្ជាសិក្សា ការចូលរួមវគ្គសិក្ខាសាលាជាបន្តបន្ទាប់ ការអនុវត្តផ្ទាល់ និងការចងក្រងរបាយការណ៍ស្រាវជ្រាវ ឬនិក្ខេបបទ។ អ្នកសិក្សានឹងបញ្ចប់ការសិក្សាតាមរយៈការសិក្សា និងការស្រាវជ្រាវ។ អ្នកសិក្សាតម្រូវឱ្យសិក្សាមុខវិជ្ជាឯកទេសកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ២៧ ក្រេឌីត មុខវិជ្ជាចំណេះដឹងវិធីសាស្ត្រដឹកនាំនិងគ្រប់គ្រងតាមសាលារៀនចំនួន ៩ (+៣) ក្រេឌីត មុខវិជ្ជាហ្វឹកហាត់កម្មសិក្សា និងដឹកនាំការអនុវត្តជាក់ស្តែង ចំនួន ៩ ក្រេឌីត។

ការចូលរួមសិក្ខាសាលាតម្រូវឱ្យនិស្សិត/អ្នកសិក្សារៀនបន្ថែម និងចែករំលែកបទពិសោធអំពីការអនុវត្តការងារនៅសាលារៀន។ ការអនុវត្តផ្ទាល់ គឺភ្ជាប់និស្សិត/អ្នកសិក្សាទៅនឹងការបំពេញកិច្ចការអនុវត្ត ដើម្បីចងក្រងបទពិសោធនៃការបំពេញការងារផ្អែកលើលទ្ធផល។ និក្ខេបបទតម្រូវឱ្យនិស្សិត/អ្នកសិក្សាចងក្រងនូវបទពិសោធដែលអនុវត្តការងារប្រកបដោយផលសម្រេច។

| កញ្ចប់សមត្ថភាព | ចំនួនមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រជាន់ខ្ពស់(៦០%) | ៩ | ២៧ |
| (២)ចំណេះដឹងវិធីសាស្ត្រដឹកនាំនិងគ្រប់គ្រងតាមសាលារៀន (២០%) | ៣(+១) | ៩ (+៣) |
| (៣)ហ្វឹកហាត់កម្មសិក្សានិងការអនុវត្តជាក់ស្តែង (២០%) | ៣ | ៩ |
| សរុប | ១៦ | ៤៨ |

## លំហូរបង្រៀន និងរៀន

**លំហូរបង្រៀននិងរៀន ១មេរៀន ឬកិច្ចការមួយ រួមជាមួយបំណិនមួយ និងចរិយាមួយ**




២. មុខវិជ្ជាសិក្សាសម្រាប់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់អប់រំនេះនឹងជួយឱ្យនិស្សិត/អ្នកសិក្សាបំពេញកញ្ចប់សមត្ថភាពដូចខាងក្រោមដើម្បីឆ្លើយតបនឹងលទ្ធផលសិក្សាកម្មវិធីអប់រំហើយឱ្យនិស្សិត/អ្នកសិក្សាមានសមត្ថភាពសម្រាប់បំពេញការងារប្រកបដោយវិជ្ជាជីវៈ។

| កញ្ចប់សមត្ថភាព | មុខវិជ្ជា | ក្រេឌីត |
|---|---|---|
| (១) ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ (៦០%) ២៧ ក្រេឌីត | ចិត្តវិទ្យាអប់រំកម្រិតខ្ពស់ ១ | ៣ |
| | ចិត្តវិទ្យាអប់រំកម្រិតខ្ពស់ ២ | ៣ |
| | ការគ្រប់គ្រងវង្វាយតម្លៃអប់រំ | ៣ |
| | ភាពជាអ្នកដឹកនាំក្នុងការគ្រប់គ្រងសាលារៀននិងរដ្ឋបាលសាលារៀនកម្រិតខ្ពស់ | ៣ |
| | ការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន និងការគ្រប់គ្រងតាមសាលារៀន សម្រាប់មធ្យមសិក្សា | ៣ |
| | វិធីសាស្ត្រស្រាវជ្រាវ | ៣ |
| | មូលដ្ឋានគ្រឹះការបង្ហឹកសាលារៀនសម្រាប់មធ្យមសិក្សា | ៣ |
| | ការធ្វើផែនការបង្ហឹកសាលារៀនសម្រាប់មធ្យមសិក្សា | ៣ |
| | វិធីសាស្ត្របង្ហឹកសាលារៀនសម្រាប់មធ្យមសិក្សា | ៣ |
| | ការអនុវត្តលើកម្មវិធីរកចំណូលនៅគ្រឹះស្ថានសិក្សា | ៣ |
| | ការអប់រំអំពីបម្រែបម្រួលអាកាសធាតុនៅមធ្យមសិក្សា | ៣ |

| | | |
|---|---|---|
| (២) ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងគ្រប់គ្រងតាមសាលារៀន (២០%) ៩(+៣) ក្រេឌីត | ការគ្រប់គ្រងគុណផលបុគ្គលិកសម្រាប់យុទ្ធសាស្ត្រសហគមន៍សាលារៀន | ៣ |
| | បច្ចេកវិទ្យាឌីជីថលសម្រាប់ការអប់រំ | (+៣) |
| (៣) ហ្វឹកហាត់កម្មសិក្សានិងការអនុវត្តជាក់ស្តែង (២០%) ៩ ក្រេឌីត | កម្មសិក្សាសម្រាប់បទពិសោធវិជ្ជាជីវៈនៅសាលាមធ្យមសិក្សា | ៣ |
| | ការសរសេរនិក្ខេបបទ | ៣ |
| | ការការពារនិក្ខេបបទ | ៣ |
| **សរុប** | | **៤៨** |

## ស្តង់ដាសាលារៀនមានប្រសិទ្ធភាព

ដើម្បីសម្រេចសូចនាករគម្រោង ដែលមានពិន្ទុនៃការកែប្រែរបៀបគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងការបង្រៀន ការបណ្តុះបណ្តាលកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន ក្នុងគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាប្រើប្រាស់ស្តង់ដាទាំងប្រាំដែលមានចែងក្នុង សៀវភៅណែនាំប្រតិបត្តិយុទ្ធសាស្ត្រសហគមន៍សាលារៀន ដែលចុះហត្ថលេខាដោយឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ ជាគោល។

| លរ | ស្តង់ដាសាលារៀនមានប្រសិទ្ធិភាព | ពិន្ទុអប្បបរមា | ពិន្ទុអតិបរមា | អ្នកទទួលបន្ទុកបង្គោល |
|---|---|---|---|---|
| ១ | សាលារៀនមានដំណើរការសម្រេចផលសម្រេចអប់រំ និងការសិក្សារៀនសូត្ររបស់សិស្ស (ទិន្នន័យយេនឌ័រនៅគ្រប់សូចនាករ) | ៣៩ | ៥២ | គណៈគ្រប់គ្រង |
| ២ | ថ្នាក់រៀនដំណើរការសម្រាប់ការបង្រៀន និងការសិក្សារៀនសូត្ររបស់សិស្សម្នាក់ៗ | ៤៧ | ៦៤ | គ្រូបង្រៀន |
| ៣ | ភាពជាម្ចាស់នៃសហគមន៍សាលារៀន | ៤៨ | ៦៤ | គណៈកម្មការគ្រប់គ្រងសាលារៀន |
| ៤ | ដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន | ៤៨ | ៦៤ | គណៈគ្រប់គ្រង |
| ៥ | គណនេយ្យភាពថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ | ២៧ | ៣៦ | ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ |
| ពិន្ទុសរុប | | ២១០ | ២៨០ | |

ក្នុងការបណ្តុះបណ្តាលលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀនទាំងអស់ត្រូវបានណែនាំឱ្យអនុវត្តកិច្ចការដូចតទៅ៖

| ល.រ | កិច្ចការ |
|---|---|
| ១ | តេស្តស្តង់ដាចុងឆ្នាំ និងដើមឆ្នាំ |
| ២ | តេស្តស្តង់ដាប្រចាំខែ និងត្រីមាស |
| ៣ | ប្រមូលសិស្សចូលរៀន (ផែនទីខ្នងផ្ទះ និងស្ថិតិគ្រួសារ) |
| ៤ | គណៈកម្មការគ្រប់គ្រងថ្នាក់រៀន និងសាលារៀន |
| ៥ | ផែនការ៦ឆ្នាំ ៣ឆ្នាំ ១ឆ្នាំ ថ្នាក់រៀន និងសិស្ស |
| ៦ | កិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំរបស់គ្រូបង្រៀន និងគណៈគ្រប់គ្រង |
| ៧ | ប្រជុំពិនិត្យតាមដានប្រចាំខែ និងត្រីមាស |
| ៨ | ពិនិត្យតាមដាន និងគាំទ្រការបង្រៀនរបស់គ្រូបង្រៀន (អធិការកិច្ចការបង្រៀនរបស់គ្រូបង្រៀន) |
| ៩ | វាយតម្លៃសាលារៀនជាប់ស្តង់ដាសាលារៀនមានប្រសិទ្ធភាព |

## ដំណើរការអនុវត្តកម្មវិធីសិក្សា

ក្នុងដំណើរការអនុវត្តកម្មវិធីសិក្សាសម្រាប់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់អប់រំនេះ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តតាមគោលការណ៍ប្រព័ន្ធក្រេឌីត និងគោលការណ៍ច្បាប់របស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលអនុលោមតាមបទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការអនុវត្តកម្មវិធីសិក្សាអាចមានលក្ខណៈបត់បែនដោយឈរលើមូលដ្ឋាននៃការផ្តោតលើផលសម្រេចការសិក្សារបស់និស្សិត/អ្នកសិក្សាជាចម្បង។

## ការអនុវត្តប្រព័ន្ធក្រេឌីត

ការសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់អប់រំនេះមាន៤៨ ក្រេឌីត។ យោងសេចក្តីសម្រេចលេខ ០៤/០៤ គ.ទ.ក.ស.ស.រ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការអនុវត្តកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត និងការផ្ទេរការសិក្សា ការសិក្សា ១ ក្រេឌីតស្មើនឹង ៤៥ ម៉ោងនៃការសិក្សានៅក្នុងថ្នាក់ និងនៅក្រៅថ្នាក់។ ចំនួនម៉ោងសិក្សាអាចប្រែប្រួលទៅតាមនៃមុខវិជ្ជាសិក្សា ដូចបង្ហាញខាងក្រោម៖

- ការឧទ្ទេស៖ ១ ក្រេឌីតសម្រាប់ការឧទ្ទេសមាន ១៥ម៉ោងសិក្សាក្នុងថ្នាក់រៀននិង៣០ម៉ោងសិក្សាក្រៅថ្នាក់
- ការសិក្សាដោយពិសោធន៍/សិក្ខាសាលា៖ ១ ក្រេឌីត សមមូលនឹងការធ្វើពិសោធន៍ ៣០ម៉ោងនៅក្នុងមន្ទីរពិសោធន៍ ឬការបណ្តុះបណ្តាល ៣០ ម៉ោងតាមរយៈសិក្ខាសាលា និង១៥ម៉ោងនៃការសិក្សាក្រៅមន្ទីរពិសោធន៍ ឬចូលរួមសិក្ខាសាលា
- ការធ្វើកម្មសិក្សា៖ ១ ក្រេឌីត មាន ៤៥ម៉ោងនៃការបណ្តុះបណ្តាលដែលបានធ្វើឡើងនៅក្នុងកសិដ្ឋាន/កន្លែងអនុវត្តការងារ និងនៅទីកន្លែងដែលពាក់ព័ន្ធផ្សេងទៀត។

ដោយអនុវត្តតាមប្រព័ន្ធក្រេឌីត និស្សិត/អ្នកសិក្សាអាចជ្រើសរើសមុខវិជ្ជាសិក្សាតាមពេលវេលាជាក់ស្តែងក្នុងរយៈពេលកំណត់នៃកម្មវិធីអប់រំ។

## រយៈពេលសិក្សា

កម្មវិធីអប់រំសម្រាប់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់អប់រំនេះអាចមានរយៈពេលសិក្សារហូតដល់៣៦ ខែ ឬ៣ ឆ្នាំសិក្សា។ និស្សិត/អ្នកសិក្សាអាចបញ្ចប់ការសិក្សាយូរឬឆាប់អាស្រ័យលើការលិខិតបំពេញការសិក្សាតាមចំនួនក្រេឌីតដែលបានកំណត់។

## ការអនុវត្តកម្មវិធីសិក្សា

ដំណើរការសិក្សាអាចធ្វើឡើងនៅក្នុងថ្នាក់ផ្ទាល់ ឬតាមរយៈការសិក្សាពីចម្ងាយឬអនឡាញន៍អាស្រ័យទៅតាមភាពជាក់ស្តែង។ ក្នុងការសិក្សា និស្សិត/អ្នកសិក្សាត្រូវបំពេញឱ្យគ្រប់ ៤៨ ក្រេឌីតសម្រាប់កម្មវិធីទាំងមូល ហើយអាចបំពេញ ១៥ ក្រេឌីតជាមធ្យមសម្រាប់ឆមាសនីមួយៗ។ កាលវិភាគសិក្សាមានលក្ខណៈបត់បែននឹងរៀបចំតាមតម្រូវការជាក់ស្តែង។

ការអនុវត្តកម្មវិធីសិក្សាមានសកម្មភាពដូចខាងក្រោមសម្រាប់សម្របសម្រួលជូននិស្សិត/អ្នកសិក្សា៖

- ការតម្រង់ទិសការសិក្សា និងកិច្ចការសម្រាប់អនុវត្តន៍
- ការសិក្សាមុខវិជ្ជាសិក្សាដែលមានទ្រឹស្តីភ្ជាប់នឹងការអនុវត្ត
- ការពិនិត្យតាមដានដំណើរសិក្សាមុខវិជ្ជាសិក្សា
- ការប្រឹក្សាយោបល់សម្រាប់ជួយដល់ដំណើរការសិក្សា
- ការសម្របសម្រួលដល់ការហាត់ការ/កម្មសិក្សា
- ការណែនាំអំពីនិក្ខេបបទ។

## ការវាយតម្លៃលើការសិក្សា

ការវាយតម្លៃលើការសិក្សារបស់និស្សិត/អ្នកសិក្សាគឺផ្តោតលើលទ្ធផលសិក្សាជាគោល។ ការវាយតម្លៃលើការសិក្សាមានបីដំណាក់កាលធំៗ គឺ (១) ការវាយតម្លៃលើការសិក្សាមុខវិជ្ជា (២) ការវាយតម្លៃលើការសរសេរនិក្ខេបបទ និង (៣) ការវាយតម្លៃសរុបដោយពិនិត្យលើការបំពេញគ្រប់លក្ខខណ្ឌសម្រាប់បញ្ចប់ការសិក្សា។

### ៧.៤.១ គោលការណ៍វាយតម្លៃ

គោលការណ៍រួមសម្រាប់ការវាយតម្លៃលើការសិក្សារបស់និស្សិត/អ្នកសិក្សាមានដូចតទៅ៖

១) និស្សិត/អ្នកសិក្សាតម្រូវឱ្យមានវត្តមានក្នុងការសិក្សាតាមមុខវិជ្ជានីមួយៗ មិនតិចជាង ៧០%។ ក្នុងករណីអ្នកសិក្សាមានវត្តមានតិចជាង៧០% នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រឡងបញ្ចប់មុខវិជ្ជានោះទេ។

២) ក្នុងករណីដែលនិស្សិត/អ្នកសិក្សាធ្លាក់មុខវិជ្ជាណាមួយក្នុងឆមាស នឹងមិនអនុញ្ញាតឱ្យបន្តការសិក្សាទៅឆ្នាំបន្ទាប់ និងប្រឡងបញ្ចប់ឡើយ។

៣) និស្សិត/អ្នកសិក្សាទាំងអស់ត្រូវធ្វើកិច្ចការស្រាវជ្រាវសំខាន់ៗតាមមុខវិជ្ជានីមួយៗ និងប្រគល់ជូនគ្រូឧទ្ទេសតាមមុខវិជ្ជាដែលបានកំណត់។

៤) និស្សិត/អ្នកសិក្សាត្រូវប្រឡងបញ្ចប់ការសិក្សាដែលធ្វើឡើងបន្ទាប់ពីចប់ឆមាសនីមួយៗតាមការកំណត់ក្នុងកម្មវិធីសិក្សា។

៥) និស្សិត/អ្នកសិក្សាត្រូវចងក្រងឯកសារវឌ្ឍនភាពនៃកិច្ចការស្នូលរួមមានការហាត់ការ និងកម្មសិក្សាដែលផ្តោតលើ (ក) សកម្មភាពប្រតិបត្តិ (ខ) លទ្ធផលដែលសម្រេចបាន និង (គ) ការឆ្លុះបញ្ចាំង និងមេរៀនបទពិសោធន៍។

៦) និស្សិត/អ្នកសិក្សាត្រូវតែជាប់មធ្យមភាគនៃការសិក្សាមុខវិជ្ជានិងការធ្វើកម្មសិក្សា ដើម្បីទទួលការអនុញ្ញាតឱ្យការពារនិក្ខេបបទ។

## ការផ្តល់ពិន្ទុ និងប្រព័ន្ធចំណាត់ថ្នាក់

និស្សិត/អ្នកសិក្សាអាចទទួលពិន្ទុចាប់ពី 00 ដល់ 100 ទៅតាមការវាយតម្លៃផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងការសិក្សាមុខវិជ្ជា ការបំពេញកម្មសិក្សា និងការសរសេរនិងការការពារនិក្ខេបបទ។ ពិន្ទុដែលជាប់ត្រូវចាប់ផ្តើមពីមធ្យមភាគពិន្ទុ 50% ឬពិន្ទុនិទ្ទេស 2.00 ឡើងទៅ។

ពិន្ទុគឺកំណត់ពី 00.00 ដល់ 100 (មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប ឬ Grade Point Average – GPA)។ រូបមន្តគណនារកមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) គឺមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ស្មើផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point – P) និងតម្លៃក្រេឌីតដែលត្រូវយកនៃមុខវិជ្ជានីមួយៗ (Attempted Credit Value – C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកគ្រប់មុខវិជ្ជា។

ប្រព័ន្ធចំណាត់ថ្នាក់កម្មវិធី គឺផ្អែកទៅលើតម្លៃនៃពិន្ទុអតិបរមា 100% និង 50% នៃពិន្ទុអប្បបរមា។ ប្រព័ន្ធដាក់ពិន្ទុនេះ ត្រូវបានបកប្រែទៅជា "ពិន្ទុជានិទ្ទេស" និង "ពិន្ទុជាតម្លៃលេខ" ដូចដែលពិពណ៌នាដូចខាងក្រោម៖

| ពិន្ទុជាភាគរយ% | និទ្ទេស | ពិន្ទុនិទ្ទេស | មូលវិចារណ៍ |
|---|---|---|---|
| 85%-100% | A | 4.00 | ល្អប្រសើរ |
| 80%-84% | B+ | 3.50 | ល្អណាស់ |
| 70%-79% | B | 3.00 | ល្អ |
| 65%-69% | C+ | 2.50 | ល្អបង្គួរ |
| 50%-64% | C | 2.00 | មធ្យម |
| <49% | F | 1.50 | ធ្លាក់ |

## គោលការណ៍ប្រតិបត្តិ

ដើម្បីធានានូវការផ្ដល់សេវាអប់រំប្រកបដោយគុណភាព និងភាពស័ក្ដិសិទ្ធ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តតាមគោលការណ៍ បទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះដែរ និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវគោរពតាមបទបញ្ញាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងឈរលើស្មារតីស្មោះត្រង់ ទទួលខុសត្រូវខ្ពស់ និងភាពម្ចាស់ការ និងគោលការណ៍សុចរិតភាពនៃការសិក្សា។ សម្រាប់គោលការណ៍សុចរិតភាពនៃការសិក្សា និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវបានវាយតម្លៃលើចំណុចសំខាន់ៗដូចខាងក្រោម៖

### ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវបានប្រមូលផ្តុំលើការគោរពវិន័យចាត់តាំង ការមករៀនទៀងទាត់ ការយកចិត្តទុកដាក់ក្នុងការសិក្សា ការខិតខំស្រាវជ្រាវ ការអនុវត្តការកិច្ច និងស្មារតីសាមគ្គីភាពនៅក្នុងថ្នាក់ ក្នុងសាលារៀន និងក្រៅសាលារៀន។ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់និស្សិតម្នាក់ៗ ត្រូវបានធ្វើឡើងតាមរយៈយោបល់ឯកភាពពីមតិភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាវិន័យ ដោយផ្អែកលើលក្ខណសម្បត្តិជាក់ស្តែងរបស់និស្សិត/អ្នកសិក្សាម្នាក់ៗ និងបទបញ្ញាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

### ការក្លែងបន្លំឯកសារ

និស្សិត/អ្នកសិក្សាដែលក្លែងបន្លំឯកសារ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតដោយស្វ័យប្រវត្តិ ព្រមទាំងទទួលទោសតាមច្បាប់ជាធរមាន។ និស្សិតត្រូវចាំថា ការលួចចម្លងស្នាដៃ ការលួចកម្មសិទ្ធិបញ្ញា និងគំនិតរបស់អ្នកដទៃគឺជាបទល្មើសសិក្សាធ្ងន់ធ្ងរដែលអាចឈានដល់ការបញ្ឈប់និស្សិតដែលប្រព្រឹត្តបទល្មើសពីកម្មវិធី។ និស្សិត/អ្នកសិក្សានឹងត្រូវធ្លាក់ជាស្ថាពរ បើនិស្សិត/អ្នកសិក្សារូបណាចម្លងដោយផ្ទាល់ពីនិស្សិតដទៃទៀត ឬប្រភពផ្សេងៗ ឬការប្រើសម្ភារៈ ឬឯកសារផ្សេងទៀត ដែលមិនត្រូវបានអនុញ្ញាតក្នុងការប្រឡង។

### របាយការណ៍/កិច្ចការស្រាវជ្រាវ

និស្សិត/អ្នកសិក្សាត្រូវបង្ហាញនូវសុចរិតភាពនៃការស្រាវជ្រាវរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ចាប់តាំងពីពេលចូលរៀនរហូតដល់ចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។ រាល់សំណេរការងារសិក្សាទាំងអស់ មិនត្រូវដកស្រង់គំនិតសរសេរ ឬចម្លងស្នាដៃផ្សេងៗរបស់អ្នកដទៃមកធ្វើជាគំនិតជាស្នាដៃ ឬជាកម្មសិទ្ធិរបស់ខ្លួនដោយគ្មានការបញ្ជាក់ពីប្រភពច្បាស់លាស់នៃឯកសារយោង ឯកសារពិគ្រោះ ឬការអនុញ្ញាតពីម្ចាស់ប្រភព។

ក្នុងករណីរកឃើញមានការលួចចម្លងស្នាដៃអ្នកដទៃ និស្សិត/អ្នកសិក្សានឹងត្រូវប្រឈមមុខចំពោះក្រុមប្រឹក្សា បច្ចេកទេស និងក្រុមប្រឹក្សាវិន័យរបស់មហាវិទ្យាល័យអប់រំ ឬសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយត្រូវទទួលពិន័យឱ្យរៀនត្រួតថ្នាក់ ឬអាចត្រូវបញ្ឈប់ពីកម្មវិធីដោយគ្មានសំណងប្រាក់សិក្សាដែលបានបង់រួចហើយទេ និងមិនមានការចេញលិខិតស្នាមបញ្ជាក់ការសិក្សាអ្វីដែរ។

**សំគាល់៖** កម្មវិធីបណ្តុះបណ្តាលសូមរក្សាសិទ្ធិក្នុងការកែប្រែការអនុវត្តន៍ជាក់ស្តែងដើម្បីឆ្លើយតបទៅនឹងស្ថានភាពការរៀននិងបង្រៀន សមត្ថភាពរៀន និងអនុវត្តជាក់ស្តែងស្ថានភាពរៀននិងបង្រៀនជាក់ស្តែង ដើម្បីសម្រេចបានលទ្ធផលសិក្សាល្អបំផុត និងសម្រេចស្តង់ដាសហគមន៍សាលារៀននៃគម្រោង GEIP ។


ការស្រាវជ្រាវប្រតិបត្តិ
Action Research
Dr. Ke Sambo


បរិវត្តកម្ម/បំលាស់ប្តូរ
Transformation/Change

## «អ្នកសិក្សានៅសវទី២១ ត្រូវការវិធីសាស្ត្ររៀនសវទី២១»

The 21st century learners need 21st century learning approaches!




This Photo by Unknown author is licensed under CC BY-SA-NC.

## «ជាអ្នកប្រតិបត្តិដែលចេះឆ្លុះបញ្ចាំងអំពីកិច្ចការរបស់ខ្លួនឯង» ហេតុអ្វីត្រូវការឆ្លុះបញ្ចាំង?

- ប្រឈមទៅនឹងស្ថានភាពថ្មីៗដែលលើសពីអ្វីដែលយើងបានបណ្តុះបណ្តាល
- រៀនពីកំហុសឆ្គង និងធ្វើឱ្យការប្រតិបត្តិរបស់ខ្លួនប្រសើរឡើង
- ផ្តល់នូវភាពគម្រូដល់សិស្ស
- ក្លាយជាអ្នករៀនពេញមួយជីវិត ជាអ្នកចេះអភិវឌ្ឍវិជ្ជាជីវៈខ្លួនឯង និងបញ្ចៀសពីការធ្វើរឿងដដែលពីមួយឆ្នាំទៅមួយឆ្នាំ

ដើម្បីវិភាគការប្រតិបត្តិរបស់លោកគ្រូអ្នកគ្រូនៅក្នុងឯកទេសរបស់ខ្លួន

ដើម្បីជាជំនួយដល់ការគិតតាមបែបឆ្លុះបញ្ចាំង ដែលនាំទៅរកការធ្វើសកម្មភាព/ការអនុវត្ត

ដើម្បីគាំទ្រទៅដល់សមត្ថភាពវិជ្ជាជីវៈ (Wat Bo)

ដើម្បីបើកច្រកក្នុងការកែប្រែជំនឿ ផ្នត់គំនិត និងទ្រឹស្តីដែលបានប្រើកន្លងមកនៅក្នុងកិច្ចការបង្រៀន និងរៀន

ដើម្បីផ្តល់វិធីសាស្រ្តក្នុងការពង្រីកបទពិសោធន៍រៀនសូត្រ និងលទ្ធផលរៀនសូត្ររបស់សិស្ស (ធ្វើដដែល និបានដដែល)

ដើម្បីជួយធ្វើឱ្យគ្រូបង្កើនចំណេះដឹង ពីការរៀន និងបង្រៀនជាលំដាប់ (CPD)

## គោលបំណងនៃការធ្វើការស្រាវជ្រាវតាមបែបប្រតិបត្តិ

## ប្រភេទនៃការស្រាវជ្រាវតាមបែបប្រតិបត្តិ

ប្រភេទទី១៖ ចង្អុលបង្ហាញដោយទ្រឹស្តី

ប្រភេទទី២៖ ចង្អុលបង្ហាញដោយទ្រឹស្តីតិចតួច

ប្រភេទទី៣៖ ការរិះគន់ទ្រឹស្តីដែលមិនគ្រាន់តែនាំទៅការកែប្រែការប្រតិបត្តិ តែជាការកែប្រែទ្រឹស្តី

# ជំហាននៅក្នុងការធ្វើការស្រាវជ្រាវប្រតិបត្តិ

ជំហានទី១៖ ការសង្កេត (កំណត់បញ្ហាមួយ/រឿងរ៉ាវមួយដែលពិបាកយល់/ភាពមិនប្រក្រតីមួយ/លក្ខណៈណាមួយដែលមិនសមជាកើតឡើងបែបនេះ)

ជំហានទី២៖ ការរៀបចំផែនការ (គិតពីវិធីនានាដើម្បីដោះស្រាយបញ្ហានោះ

ជំហានទី៣៖ ការប្រតិបត្តិ (ធ្វើវា)

ជំហានទី៤៖ ការឆ្លុះបញ្ចាំង៖ (វាយតម្លៃទៅលើលទ្ធផលជាក់ស្តែងដែលរកឃើញ)

ជំហានទី៥៖ ពិនិត្យមើលឡើងវិញ (កែលម្អ ឬពង្រីកបន្ថែមការប្រតិបត្តិនៅថ្ងៃខាងមុខ)

# ចូរឆ្លើយនឹងសំណួរទាំងនេះ!!!

- តើមានរឿងអ្វីមួយដែលកើតឡើងនៅក្នុងការបំពេញកិច្ចការប្រចាំថ្ងៃរបស់លោកគ្រូ អ្នកគ្រូ? ចូររៀបរាប់។
- តើអ្នកគិតថារឿងនោះមានភាពមិនប្រក្រតី ឬចម្លែកដែរឬទេ? មិនប្រក្រតីដូចម្តេច? ចូរពន្យល់?
- តើអ្វីខ្លះជាផលវិបាកដែលអាចបណ្តាលមកពីបញ្ហានោះ? ចូររៀបរាប់ដោយភ្ជាប់ជាមួយអំណះអំណាង?
- តើលោកគ្រូ អ្នកគ្រូបានប្រើប្រាស់វិធីអ្វីខ្លះដើម្បីដោះស្រាយបញ្ហានេះ? តើមានការប្រែប្រួលជាវិជ្ជមានដែរឬទេក្រោយពីប្រើវិធីនោះមួយរយៈមក?
- បើតាមទ្រឹស្តី និងលទ្ធផលនៃការស្រាវជ្រាវមុនៗ តើបញ្ហាដែលកើតមាននោះបណ្តាលមកពីកត្តាអ្វីខ្លះ? ចូរបញ្ជាក់ឈ្មោះទ្រឹស្តី និងអ្នកនិពន្ធអត្ថបទស្រាវជ្រាវនោះ។ តើគេពន្យល់ចំណងទាក់ទងនោះដូចម្តេច?
- តើលោកគ្រូ អ្នកគ្រូនឹងត្រៀមប្រើវិធីថ្មីមួយទៀតដែរឬទេ? វិធីនោះជាអ្វី? បានវិធីនោះពីណាមក? វាមានទម្រង់បែបណា? ចូររៀបរាប់?
- តើអ្វីជាវត្ថុបំណងស្រាវជ្រាវរបស់លោកគ្រូ អ្នកគ្រូ?ចូរសរសេរវាជាទម្រង់សំណួរមួយទៀត។
- តើអ្វីជារចនាបទស្រាវជ្រាវនៅក្នុងការសិក្សានេះ? ហេតុអ្វីបានជាលោកគ្រូ អ្នកគ្រូជ្រើសរើសយករចនាបទមួយនេះ?

## ការសម្រេចចិត្តលើវិធីសាស្រស្រាវជ្រាវនៅក្នុងការស្រាវជ្រាវបែបប្រតិបត្តិ (ឧ.)




### ការរិះគន់ទៅលើការស្រាវជ្រាវប្រតិបត្តិ និងវិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវប្រតិបត្តិហាក់ដូចជាមិនសូវមានភាពល្អប្រសើរដូចការស្រាវជ្រាវមូលដ្ឋាន ដោយសារតែវាជាការអធិប្បាយពីការប្រតិបត្តិដែលគ្មានទ្រឹស្តីគាំទ្រ។



## ការវិភាគពីគំនិតរិះគន់ទៅលើការស្រាវជ្រាវ និងវិធីសាស្ត្រស្រាវជ្រាវ

- ក្របខណ្ឌ/គ្រងឆ្អឹងនៃការស្រាវជ្រាវមានលក្ខណៈប្រហាក់ប្រហែលគ្នា ក្នុងន័យថាការស្រាវជ្រាវទាំងពីរប្រភេទនេះមានគោលបំណងចុងក្រោយដូចគ្នា
- កន្លែងដែលខុសគ្នាគឺវិធីសាស្ត្រស្រាវជ្រាវដែលមិនអាចវាយតម្លៃថាមួយណាល្អជាងមួយណាទេ
- លទ្ធផលនៃការស្រាវជ្រាវគឺជាការយល់ដឹងថ្មី បទពិសោធថ្មី និងការទទួលបានចំណេះដឹងបន្ថែម
- ការស្រាវជ្រាវខ្លះមានវិធីសាស្ត្រស្រាវជ្រាវល្អ តែលទ្ធផលនៃការស្រាវជ្រាវត្រូវបានយកទៅប្រើជាប្រយោជន៍បានតិចតួច

Norton, L. S. (2009) Action research in teaching and learning: a practical guide to conducting pedagogical action research in universities




ដំណើរការនៃការស្រាវជ្រាវ
អ្នកសម្របសម្រួលមុខវិជ្ជា៖ កែ សំបូរ


ដំណើរការ
(PROCESS)?
ចុះដំណើរការនៃ
ការស្រាវជ្រាវ
(RESEARCH
PROCESS)?




## វដ្តនៃដំណើរការស្រាវជ្រាវ (Creswell, 2012)

## ការកំណត់បញ្ហានៃការស្រាវជ្រាវមួយ (Identifying a research problem)

- កំណត់បញ្ហានៃការស្រាវជ្រាវមួយជាក់លាក់ (Specifying a research problem)
- ការបង្ហាញដំណើរដើមទង ហេតុផល ភស្តុតាងបញ្ជាក់ (Justify it)
- បង្ហាញពីតម្រូវការដើម្បីសិក្សាពីបញ្ហានោះសម្រាប់អ្នកដែលពាក់ព័ន្ធ/អ្នកដែលនឹងប្រើប្រាស់លទ្ធផលនៃការស្រាវជ្រាវនោះ (Suggest the need to study it for audiences)



## រំលឹកទ្រឹស្តី (reviewing the literature)

តើមានទ្រឹស្តិពាក់ព័ន្ធណាខ្លះដែលចូលរួមពន្យល់បញ្ហាដែលបានលើកឡើងពីខាងដើម? តើទ្រឹស្តីនោះពន្យល់បញ្ហានោះដូចម្តេច? (ទូលាយ)

តើមានព័ត៌មានអ្វីខ្លះដែលរកបានពីការស្រាវជ្រាវមុនៗហើយដែលចូលរួមស្រាយចម្ងល់របស់លោកគ្រូ អ្នកគ្រូពាក់ព័ន្ធនិងបញ្ហាដែលបានលើកឡើង? (ជាក់លាក់)

តើមានកន្លែងណាខ្លះនៃអត្ថបទស្រាវជ្រាវមុនៗ មិនអាចឆ្លើយ ឬពន្យល់បញ្ហា ឬសំណួរស្រាវជ្រាវរបស់លោកគ្រូ អ្នកគ្រូ បានច្បាស់លាស់នៅឡើយ?

តើការស្រាវជ្រាវរបស់លោកគ្រូ អ្នកគ្រូនឹងសិក្សា ជួយពន្យល់បន្ថែម ឬបំពេញបន្ថែមទៅនឹងចន្លោះប្រហោង ឬភាពមិនច្បាស់លាស់នៃការស្រាវជ្រាវមុនៗដូចម្តេចខ្លះ?

- ស្វែងរកធនធានឯកសាដែលពាក់ព័ន្ធ (locating resources)
- ជ្រើសរើសធនធានឯកសា (selecting resources)
- សង្ខេបព័ត៌មានពីធនធានឯកសាទាំងនោះ (Summarizing the resources)



## កំណត់គោលបំណងនៃការស្រាវជ្រាវមួយ (specifying a purpose for research)

1. កំណត់ និងសរសេរច្បាស់លាស់ពីគោលបំណងនៃការស្រាវជ្រាវ (Identify the purpose statement)
2. បង្រួញគោលបំណងនៃការស្រាវជ្រាវឱ្យទៅជាសំណួរស្រាវជ្រាវ ឬសម្មតិកម្ម (Narrowing the purpose statement to research questions or hypotheses



## ការប្រមូលទិន្នន័យ
## (collecting data)

1. ជ្រើសរើសអ្នកដែលត្រូវផ្តល់ទិន្នន័យនៅក្នុងការស្រាវជ្រាវ (Selecting individuals to study)
2. ទទួលបានការអនុញ្ញាតពីស្ថាប័ន និងអ្នកចូលរួមផ្តល់ទិន្នន័យ (Obtaining permissions)
3. ការចុះប្រមូលទិន្នន័យ (Gathering the data)



## វិភាគ និងបកស្រាយទិន្នន័យ
## (Analyzing and interpreting data)

1. ការបំបែកទិន្នន័យឱ្យទៅជាភាគល្អិត(Breaking down the data)
2. ផ្តល់ទិន្នន័យតំណាង (Representing the data)
3. ពន្យល់ទិន្នន័យ (Explaining the data)




**សរសេររបាយការណ៍ និងស្រាវជ្រាវ និងវាយតម្លៃការស្រាវជ្រាវ**
(reporting and evaluating research)

1. សម្រេចថាតើនរណាដែលត្រូវប្រគល់របាយការណ៍ស្រាវជ្រាវនេះទៅឱ្យ(Deciding on the audiences)
2. រៀបចំរចនាបទរបាយការណ៍តាមតម្រូវការ (Structuring the report)
3. សរសេររបាយការណ៍ឱ្យបានត្រឹមត្រូវតាមតម្រូវការ (Writing the report sensitively

| នៅមានបញ្ហាអ្វី?<br>Research Problem | ចង់សិក្សាពីអ្វី ចង់ដឹងពីអ្វី??<br>Research Objectives/questions/hypotheses | ប្រើរចនាបទស្រាវជ្រាវអ្វី?<br>Research Design |
|---|---|---|
| តើមានរឿងអ្វីកើតឡើងនៅក្នុងការបំពេញកិច្ចការប្រចាំថ្ងៃរបស់លោកគ្រូ អ្នកគ្រូ? រឿងនោះមិនប្រក្រតីដូចម្តេច?<br><br>ឧ. សកម្មភាពបង្រៀនចម្រៀងមួយបទត្រូវបានរៀបចំឡើងដោយប្រើពេលជាមធ្យម ១០ នាទី ដើម្បីឱ្យស្របទៅតាមកម្រិតបម្រុងប្រយ័ត្នរបស់កុមារមត្តេយ្យកម្រិតថ្នាក់ទាប។ ជាក់ស្តែង ពេលអនុវត្ត កុមារ ៨០% មិនអាចផ្ចង់ស្មារតីចូលរួមសកម្មភាពនោះបាន ពួកគេចូលរួមបាន ត្រឹមតែ ៥ នាទី។។ | អ្វី *(Wha)*?>អធិប្បាយ (Descriptive)<br>❑ តើអ្វីលក្ខណៈសម្បត្តិនៃបញ្ហានោះ?<br>❑ តើបញ្ហានោះមានន័យដូចម្តេច?<br>❑ តើគេសម្គាល់ ឬវាស់វែងបញ្ហានេះដូចម្តេច?<br>❑ តើអ្នកដែលពាក់ព័ន្ធទទួលបានបទពិសោធន៍បែបណា?<br>❑ តើមានលក្ខណៈខុសគ្នាដូចម្តេចពីក្រុមមួយទៅក្រុមមួយទៀត? | ករណីសិក្សា (Case study)<br>ការស្ទង់មតិ (Survey)<br>ការសង្កេត (Observation )<br>ការប្រៀបធៀប (Comparative study) |
| | ហេតុអ្វី? >ពន្យល់ពីទំនាក់ទំនង (Explain the relation)<br>❑តើ X មានឥទ្ធិពលលើ Y ដែរឬទេ?<br>❑តើកត្តាអ្វីខ្លះដែលនាំឱ្យកើតមានបញ្ហា?<br>❑តើរឿងមួយមួយកើតឡើង បណ្តាលឱ្យមានលេចចេញរឿងមួយទៀតដូចម្តេច?> | ទំនាក់ទំនងហេតុ និងផល (Correlation; Causal relation)<br><br>ការស្រាវជ្រាវតាមបរិបទ |
| | ចង់ដោះស្រាយបញ្ហា? (solving the problem)<br>❑តើអ្វីខ្លះជាមូលហេតុដែលនាំឱ្យមានបញ្ហា? តើមូលហេតុមួយណាដែលមានអាទិភាពជាងគេ?<br>❑តើអ្វីជាបទអន្តរាគមន៍? អភិវឌ្ឍដូចម្តេច?<br>❑តើបទអន្តរាគមន៍នោះមានឥទ្ធិពលដែរឬទេនៅក្នុងការដោះស្រាយបញ្ហា? | ការធ្វើពិសោធន៍ (Experimental designs) |

## ការផ្តើមគំណិតស្រាវជ្រាវ (Research Conceptualization)

# ចូរឆ្លើយនឹងសំណួរទាំងនេះ!!!

- តើមានរឿងអ្វីកើតឡើងនៅក្នុងការបំពេញកិច្ចការប្រចាំថ្ងៃរបស់លោកគ្រូ អ្នកគ្រូ? ចូររៀបរាប់។
- តើអ្នកគិតថារឿងនោះមានភាពមិនប្រក្រតី ឬចម្លែកដែរឬទេ? មិនប្រក្រតីដូចម្តេច? ចូរពន្យល់?
- តើអ្វីខ្លះជាផលវិបាកដែលអាចបណ្តាលមកពីបញ្ហានោះ? ចូររៀបរាប់ដោយភ្ជាប់ជាមួយអំណះអំណាង?
- តើលោកគ្រូ អ្នកគ្រូបានប្រើប្រាស់វិធីអ្វីខ្លះដើម្បីដោះស្រាយបញ្ហានេះ? តើមានការប្រែប្រួលជាវិជ្ជមានដែរឬទេក្រោយពីប្រើវិធីនោះមួយរយៈមក?
- បើតាមទ្រឹស្តី និងលទ្ធផលនៃការស្រាវជ្រាវមុនៗ តើបញ្ហាដែលកើតមាននោះបណ្តាលមកពីកត្តាអ្វីខ្លះ? ចូរបញ្ជាក់ឈ្មោះទ្រឹស្តី និងអ្នកនិពន្ធអត្ថបទស្រាវជ្រាវនោះ។ តើគេពន្យល់ចំណងទាក់ទងនោះដូចម្តេច?
- តើលោកគ្រូ អ្នកគ្រូនឹងត្រៀមប្រើវិធីថ្មីមួយទៀតដែរឬទេ? វិធីនោះជាអ្វី? បានវិធីនោះពីណាមក? វាមានទម្រង់បែបណា? ចូររៀបរាប់?
- តើអ្វីជាវត្ថុបំណងស្រាវជ្រាវរបស់លោកគ្រូ អ្នកគ្រូ?ចូរសរសេរវាជាទម្រង់សំណួរមួយទៀត។
- តើអ្វីជារចនាបទស្រាវជ្រាវនៅក្នុងការសិក្សានេះ? ហេតុអ្វីបានជាលោកគ្រូ អ្នកគ្រូជ្រើសរើសយករចនាបទមួយនេះ?

# សូមអរគុណ!


សញ្ញាណទូទៅនៃការស្រាវជ្រាវ
វិទ្យាសាស្ត្រនៅក្នុងវិស័យអប់រំ
Introduction to Scientific Research in Education
Ke Sambo, Ph.D.


ការស្រាវជ្រាវ?
ការស្រាវជ្រាវវិទ្យាសាស្ត្រ?

សូមចែករំលែកការយល់ឃើញរបស់លោកគ្រូ អ្នកគ្រូនៅក្នុងស្លាយនេះ

គឺជាការអនុវត្តដែលមានវិធិសាស្រ្តជាប្រព័ន្ធ និងបច្ចេកទេសដែលអាចជួយអ្នកស្រាវជ្រាវ និងអត្តប្រតិបត្តិឱ្យយល់ដឹង និងពង្រឹកការបង្រៀន និងដំណើរការរៀនសូត្រ។

The application of systematic methods and techniques

That Help

researchers and practitioners

understand and enhance

the teaching and learning process

- ជាការស្រាវជ្រាវដែល៖
  - ការរៀបចំ**ផែនការ**ដែលមានលក្ខណៈជាប្រព័ន្ធ (systematically planned before performing them)
  - ការប្រើប្រាស់**វិធីសាស្រ្ត**ច្បាស់លាស់ (guided by scientific methodology)
  - **ការបកស្រាយ និងវាយតម្លៃទិន្នន័យ** ដែលប្រមូលបាន (accurately Interpreted and evaluated the collected data)



# ប្រភេទនៃការស្រាវជ្រាវ Types of Research

| ការស្រាវជ្រាវមូលដ្ឋាន Basic Research | ការស្រាវជ្រាវប្រតិបត្តិ Applied Research |
|---|---|
| ការបង្កើតចំណេះដឹងថ្មីតាមរយៈការបង្កើតទ្រឹស្តី<br>Knowledge creation through theory building | សិក្សាពីប្រសិទ្ធិភាព និងសារៈប្រយោជន៍នៃការប្រតិបត្តិណាមួយ<br>Examine the effectiveness and usefulness of particular educational practices |
| ជាការសិក្សាដែលអាចតេស្ត កែលម្អ ពង្រីក និងអភិវឌ្ឍទ្រឹស្តី<br>Design studies that can test, refine, modify, or develop theories | កំណត់ថាតើទ្រឹស្តីអាចប្រើប្រាស់បានដែរឬទេនៅក្នុងបរិបទជាក់លាក់មួយ<br>Determine the applicability of educational theory and principles by testing hypotheses within specific setting |




## ជំនឿលើទស្សនៈនៃសេចក្តីពិត

(Philosophical Beliefs)

| | Ontological belief<br>ធម្មជាតិនៃសេចក្តីពិត | Epistemological belief<br>វិធីស្គាល់សេចក្តីពិត | Axiological beliefs<br>តួនាទីនៃតម្លៃ |
|---|---|---|---|
| វិជ្ជមានថ្មីនិយម<br>( Post-positivism ) | «សេចក្តីពិតមួយកើតមានលើសពីខ្លួនរបស់យើង»<br>អ្នកស្រាវជ្រាវអាចនឹងមិនមានលទ្ធភាពយល់ពីវាបានទេ ព្រោះតែខ្វះនូវភាពឥតខ្ចោះ។ | សេចក្តីពិតគ្រាន់តែអាចប៉ាន់ប្រមាណបានប៉ុណ្ណោះ ប៉ុន្តែវាអាចសាងឡើងតាមរយៈការស្រាវជ្រាវ និងការសិក្សាស្ថិតិ។ ការទាក់ទងគ្នារវាងអ្នកស្រាវជ្រាវ និងអ្នកចូលរួមត្រូវកាត់បន្ថយឱ្យតិចបំផុត | ភាពលម្អៀងរបស់អ្នកស្រាវជ្រាវត្រូវការការត្រួតពិនិត្យ |
| ស្ថាបនាសង្គមនិយម<br>( Social constructivism ) | សេចក្តីពិតជាច្រើនអាចត្រូវបានសាងឡើងតាមរយៈបទពិសោធរស់នៅរបស់យើង។ | សេចក្តីពិតគឺសាងឡើងរួមគ្នារវាងអ្នកស្រាវជ្រាវ និងអ្នកដែលត្រូវបានគេស្រាវជ្រាវ ហើយវាត្រូវបានកំណត់ទ្រង់ទ្រាយដោយបទពិសោធបុគ្គល | តម្លៃបុគ្គលគឺត្រូវបានផ្តល់ឱ្យ ហើយក៏អាចចរចារបានក្នុងចំណោមបុគ្គលទាំងឡាយ។ |


គោលវិធីនៃការស្រាវជ្រាវ
(Research Approaches)
• ការស្រាវជ្រាវតាមបែបគុណវិស័យ
• ការស្រាវជ្រាវតាមបែបបរិមាណវិស័យ


Quantitative research approaches
• ការស្រាវជ្រាវតាមបែបពិសោធន៍
• ការស្រាវជ្រាវមិនតាមបែបពិសោធន៍

## Types of Quantitative Designs

(Creswell, 2014)

**Posttest-Only Control-Group Design**

This design controls for any confounding effects of a pretest and is a popular experimental design. The participants are randomly assigned to groups, a treatment is given only to the experimental group, and both groups are measured on the posttest.

Group A *R*————*X*————*O*

Group B *R*———————————*O*

**Solomon Four-Group Design**

## Types of Quantitative Designs

(Creswell, 2014)

**Example 8.4** *True Experimental Designs*

**Pretest-Posttest Control-Group Design**

A traditional, classical design, this procedure involves random assignment of participants to two groups. Both groups are administered both a pretest and a posttest, but the treatment is provided only to experimental Group A.

Group A *R*——*O*——*X*——*O*

Group B *R*——*O*————*O*

# Result (Ex.)




# Predictive Study

**Table 2.** Correlations among the Variables

| Variables | AE | RP | RT | RC |
|---|---|---|---|---|
| Academic engagement (AE) | ---- | | | |
| Relationship with parents (RP) | 0.42*** | ---- | | |
| Relationship with teachers (RT) | 0.70*** | 0.41*** | ---- | |
| Relationship with classmates (RC) | 0.56*** | 0.23** | 0.432*** | ---- |

****p*<.001, ***p*<.01

**Table 3.** Results of Multiple Regression Predicting Academic Engagement

| Predictor | B | SE | ß | t | p |
|---|---|---|---|---|---|
| Relationship with parents | 0.10 | 0.05 | 0.14 | 1.92 | .058 |
| Relationship with teacher | 0.43 | 0.04 | 0.51 | 6.75 | .000 |
| Relationship with classmates | 0.22 | 0.05 | 0.31 | 4.28 | .000 |

# ការប្រៀបធៀបវិធីសាស្ត្រស្រាវជ្រាវ

| បរិមាណ | គុណភាព |
|---|---|
| ត្រូវបានកំណត់ពីដើមទី | វិធីសាស្ត្រលេចចេញ/ផុសចេញ |
| សំណួរដែលមានមូលដ្ឋានលើឧបករណ៍វាស់វែង | សំណួរបើក |
| ទិន្នន័យជាប្រភេទផលនៃការសម្តែង ទិន្នន័យជាឥរិយាបទ ទិន្នន័យពីការសង្កេត និងទិន្នន័យជម្រឿន | ទិន្នន័យសម្ភាសន៍ ទិន្នន័យពីការសង្កេត ទិន្នន័យពីឯកសានានា និងទិន្នន័យពីការថត |
| ការវិភាគទិន្នន័យជាលក្ខណៈស្ថិតិ | ការវិភាគអត្ថបទ និងរូបភាព |
| ការបកប្រែស្ថិតិ | ការបកប្រែជាទិដ្ឋភាព និងភាពជាគម្រូ |

## ការស្រាវជ្រាវបែបបរិមាណវិស័យ

ការស្រាវជ្រាវបែបបរិមាណវិស័យគឺជាវិធីសាស្ត្រមួយដែលផ្តោតលើការតែស្តមើលទ្រឹស្តីដែលមានស្រាប់ដោយពិនិត្យមើលទៅលើចំណងទាក់ទងរវាងអថេរ។ អថេរនេះអាចត្រូវបានគេវាស់វែងបានជាលេខ ដោយប្រើឧបករណ៍វាស់ ហើយទិន្នន័យជាលេខនេះអាចត្រូវបានគេវិភាគដោយប្រើស្ថិតិដែលមានលក្ខណៈជាលំដាប់លំដោយ។

# អ្វីទៅជាទ្រឹស្តី


Cultural Milieu
1. Gender and other social role systems
2. Stereotypes of activities and the nature of abilities
3. Family Demographics
Perception of...
1. Socializer's beliefs and behaviors
2. Gender and other social roles
3. Activity characteristics and demands
4. Possible activities
Goals and General Self-Schemata
1. Self-concept of one's abilities
2. Self-schemata
3. Personal and social identities
4. Short-term goals
5. Long-term goals
Expectation of Success
Achievement-Related Choices and Performance
Socializer's Beliefs and Behaviors
Person Characteristics
1. Aptitudes
2. Temperaments
3. Sex
4. Ethnic group
Affective Reactions and Memories
Subjective Task Value
1. Interest -enjoyment value
2. Attainment value
3. Utility value
4. Relative cost
Interpretation of Experience
Previous Achievement-Related Experiences

## Qualitative Research approaches

- ❑ ការស្រាវជ្រាវដំណើររឿង Narrative
- ❑ ការស្រាវជ្រាវបាតុភូតវិទ្យា Phenomenology
- ❑ ការស្រាវជ្រាវដោយផ្ដោតលើបរិបទ Grounded theory
- ❑ ការស្រាវជ្រាវជាតិពន្ធវិទ្យា Ethnographies
- ❑ ការស្រាវជ្រាវតាមបែបករណីសិក្សា Case study

## A written Sample

Case 1 (CILNF). She is a female student who selected biology—a natural science discipline—as a study major, enrolled in a statistics course, and ultimately received lower total scores in this subject (52 points out of 100). She was a student from Pursat province, the north-west part of Cambodia. The student is in her second semester of college studies as is taking the course in Statistics along with other required subjects in her program. She claims that the course is valuable and important for her because it allows her to use and enhance her comprehension skills, critical thinking, and analytical skills. Because she values the subject, she engages in in-class activities by focusing on the teacher's explanation, avoiding to talk about other things aside from the study lesson in this class, taking note of the key points, and asking for clarification to obtain basic information for further searches *"...liked thinking and analyzing ... statistics can bring me to obtain these skills, thus I tried to listen to the teacher and clarify with him. focus more on it."* She enjoys analyzing the meanings of concepts, and thinks that how she engages in the course are instrumental to the enhancement of her desired skills.



EXHIBIT 1.2 Women's Ways of Knowing: An Example of Qualitative Findings

*Silence:* A position in which women experience themselves as mindless and voiceless and subject to the whims of external authority.

*Received knowledge:* Women conceive of themselves as capable of receiving, even reproducing knowledge from external authorities, but not capable of creating knowledge on their own.

*Subjective knowledge:* A perspective from which truth and knowledge are conceived as personal, private, and subjectively known or intuited.

*Procedural knowledge:* Women are invested in learning and apply objective procedures for obtaining and communicating knowledge.

*Constructed knowledge:* Women view all knowledge as contextual, experience themselves as creators of knowledge, and value both subjective and objective strategies for knowing.

## A Sample of Thematic Analysis Outputs

As cited in Patton, 2002)

## A Sample of Thematic Analysis Outputs for a Comparative Case Study

(Ke, 2019)



*Table 4.*

Summary of the Emerging Themes on Motivation and SRL by Performance Levels


សូមអរគុណ!


សញ្ញាណទូទៅនៃការស្រាវជ្រាវវិទ្យាសាស្ត្រនៅក្នុងវិស័យអប់រំ
Introduction to Scientific Research in Education
Ke Sambo, Ph.D.


ការស្រាវជ្រាវ?
ការស្រាវជ្រាវវិទ្យាសាស្ត្រ?

សូមចែករំលែកការយល់ឃើញរបស់លោកគ្រូ អ្នកគ្រូនៅក្នុងស្លាយនេះ

**គឺជាការអនុវត្តដែលមានវិធិសាស្ត្រជាប្រព័ន្ធ និងបច្ចេកទេសដែលអាចជួយអ្នកស្រាវជ្រាវ និងអ្នកប្រតិបត្តិឱ្យយល់ដឹង និងពង្រីកការបង្រៀន និងដំណើរការរៀនសូត្រ។**

The **application of systematic methods and** techniques

**That Help**

researchers **and** practitioners

**understand and enhance**

**the** teaching **and** learning **process**

- ជាការស្រាវជ្រាវដែល៖
  - ការរៀបចំ**ផែនការ**ដែលមានលក្ខណៈជាប្រព័ន្ធ (systematically planned before performing them)
  - ការប្រើប្រាស់**វិធីសាស្រ្ត**ច្បាស់លាស់ (guided by scientific methodology)
  - **ការបកស្រាយ និងវាយតម្លៃទិន្នន័យ**

    ដែលប្រមូលបាន (accurately Interpreted and evaluated the collected data)



# ប្រភេទនៃការស្រាវជ្រាវ Types of Research

| ការស្រាវជ្រាវមូលដ្ឋាន Basic Research | ការស្រាវជ្រាវប្រតិបត្តិ Applied Research |
|---|---|
| ការបង្កើតចំណេះដឹងថ្មីតាមរយៈការបង្កើតទ្រឹស្តី<br>Knowledge creation through theory building | សិក្សាពីប្រសិទ្ធិភាព និងសារៈប្រយោជន៍នៃការប្រតិបត្តិណាមួយ<br>Examine the effectiveness and usefulness of particular educational practices |
| ជាការសិក្សាដែលអាចតេស្ត កែលម្អ ពង្រីក និងអភិវឌ្ឍទ្រឹស្តី<br>Design studies that can test, refine, modify, or develop theories | កំណត់ថាតើទ្រឹស្តីអាចប្រើប្រាស់បានដែរឬទេនៅក្នុងបរិបទជាក់លាក់មួយ<br>Determine the applicability of educational theory and principles by testing hypotheses within specific setting |

# គោលវិធីនៃការស្រាវជ្រាវ
# (Research Approaches)

- ការស្រាវជ្រាវតាមបែបគុណវិស័យ
- ការស្រាវជ្រាវតាមបែបបរិមាណវិស័យ

# Quantitative research approaches

- ការស្រាវជ្រាវតាមបែបពិសោធន៍
- ការស្រាវជ្រាវមិនតាមបែបពិសោធន៍

# Types of Quantitative Designs

(Creswell, 2014)

**Posttest-Only Control-Group Design**

This design controls for any confounding effects of a pretest and is a popular experimental design. The participants are randomly assigned to groups, a treatment is given only to the experimental group, and both groups are measured on the posttest.

Group A *R*————————*X*————————*O*

Group B *R*——————————————————*O*

**Solomon Four-Group Design**

# Types of Quantitative Designs

(Creswell, 2014)

**Example 8.4** *True Experimental Designs*

**Pretest-Posttest Control-Group Design**

A traditional, classical design, this procedure involves random assignment of participants to two groups. Both groups are administered both a pretest and a posttest, but the treatment is provided only to experimental Group A.

Group A *R*————*O*————*X*————*O*

Group B *R*————*O*——————————*O*

# Result (Ex.)




# Predictive Study

**Table 2.** Correlations among the Variables

| Variables | AE | RP | RT | RC |
|---|---|---|---|---|
| Academic engagement (AE) | ---- | | | |
| Relationship with parents (RP) | 0.42*** | ---- | | |
| Relationship with teachers (RT) | 0.70*** | 0.41*** | ---- | |
| Relationship with classmates (RC) | 0.56*** | 0.23** | 0.432*** | ---- |

***$p$<.001, **$p$<.01

**Table 3.** Results of Multiple Regression Predicting Academic Engagement

| Predictor | B | SE | ß | t | p |
|---|---|---|---|---|---|
| Relationship with parents | 0.10 | 0.05 | 0.14 | 1.92 | .058 |
| Relationship with teacher | 0.43 | 0.04 | 0.51 | 6.75 | .000 |
| Relationship with classmates | 0.22 | 0.05 | 0.31 | 4.28 | .000 |

# Qualitative Research approaches

- ការស្រាវជ្រាវដំណើររឿង Narrative
- ការស្រាវជ្រាវបាតុភូតវិទ្យា Phenomenology
- ការស្រាវជ្រាវដោយផ្តោតលើបរិបទ Grounded theory
- ការស្រាវជ្រាវជាតិពន្ធុវិទ្យា Ethnographies
- ការស្រាវជ្រាវតាមបែបករណីសិក្សា Case study

## A written Sample

**Case 1 (C1LNF).** She is a female student who selected biology—a natural science discipline—as a study major, enrolled in a statistics course, and ultimately received lower total scores in this subject (52 points out of 100). She was a student from Pursat province, the north-west part of Cambodia. The student is in her second semester of college studies as is taking the course in Statistics along with other required subjects in her program. She claims that the course is valuable and important for her because it allows her to use and enhance her comprehension skills, critical thinking, and analytical skills. Because she values the subject, she engages in in-class activities by focusing on the teacher's explanation, avoiding to talk about other things aside from the study lesson in this class, taking note of the key points, and asking for clarification to obtain basic information for further searches "*...liked thinking and analyzing ... statistics can bring me to obtain these skills, thus I tried to listen to the teacher and clarify with him, focus more on it.*" She enjoys analyzing the meanings of concepts, and thinks that how she engages in the course are instrumental to the enhancement of her desired skills.

# A Sample of Thematic Analysis Outputs

**EXHIBIT 1.2** Women's Ways of Knowing: An Example of Qualitative Findings

*Silence:* A position in which women experience themselves as mindless and voiceless and subject to the whims of external authority.

*Received knowledge:* Women conceive of themselves as capable of receiving, even reproducing knowledge from external authorities, but not capable of creating knowledge on their own.

*Subjective knowledge:* A perspective from which truth and knowledge are conceived as personal, private, and subjectively known or intuited.

*Procedural knowledge:* Women are invested in learning and apply objective procedures for obtaining and communicating knowledge.

*Constructed knowledge:* Women view all knowledge as contextual, experience themselves as creators of knowledge, and value both subjective and objective strategies for knowing.

SOURCE: Belenky et al. (1986:15).

As cited in Patton, 2002)

# A Sample of Thematic Analysis Outputs for a Comparative Case Study

*Table 4.*

Summary of the Emerging Themes on Motivation and SRL by Performance Levels

| Themes | Lower Performance | | | | Higher Performance | | | |
|---|---|---|---|---|---|---|---|---|
| | C1 LNF | C2 LNM | C7 LSF | C8 LSM | C3 HNM | C4 HNF | C5 HSF | C6 HSM |
| **Motivations** | | | | | | | | |
| Self-efficacy for learning in the subject | Self-confidence in learning | Perceived working knowledge<br><br>Self-confidence in learning | X | Encouragement received from other people | Encouragement received from other people | Concern deterioration of ability<br><br>Self-confidence in learning | Self-confidence in learning | Encouragement received from other people |
| Perceived utility value of the subject | Tasks as applicable to daily life | Tasks as beneficial to future careers | Tasks as useful in other areas of study | Tasks as applicable to daily life | Tasks as beneficial to future careers | Tasks as useful in other areas of study | Tasks as instrumental to understanding society | Tasks as applicable to daily life |
| Intrinsic interest in the subject | Subject as congruence to personal interest | Skills of subject as congruence to personal preference | X | X | Skills of subject as congruence to personal preference | Subject as important to self | Contents of subject that are in the line with internal interest | X |
| Intrinsic goal orientation | Wanting to acquire quality of learning in the subject | Wanting to master the subject well | X | X | Wanting to learn new things in statistic | Being curious to acquire real knowledge and skills | Wanting to earn applied knowledge | Wanting to earn applied knowledge |
| **Self-regulated Learning** | | | | | | | | |
| Use of critical analysis strategies | Solving problem in statistics exercises<br><br>Analyzing concepts of statistics | Creating new problem tasks<br><br>Solving problem in statistics exercises | X | X | Solving problem in statistics exercises<br><br>Analyzing concepts of statistics | Analyzing concepts of statistics<br><br>Solving problem in statistics exercises | Analyzing concepts of statistics<br><br>Solving problem in statistics exercises | Solving problem in statistics exercises |
| Use of elaboration strategies | Searching for additional information | Searching for additional information | X | X | Summarizing lessons during review | Comprehending concepts | Searching for additional information | Summarizing lessons during review |
| Use of rehearsal strategies | X | X | Using only teacher-provided content | Memorizing the learning content | Memorizing the learning content | Memorizing the learning content | Memorizing the learning content | Memorizing the learning content |
| Metacognitive in learning in the course | Self-checking of learning progress | Self-checking of learning progress | X | X | Organizing cognitive tasks to perform learning activities | Organizing cognitive tasks to perform learning activities | Organizing cognitive tasks to perform learning activities | Self-checking of learning progress |
| Effort regulation in learning in the course | Involvement in course activities<br><br>Organization of behavioral engagement on the learning tasks. | Persistence in spending time to study | X | Involvement in course activities<br><br>Seeking help from others<br><br>Collaboration with classmates | Collaboration with classmates<br><br>Time management<br><br>Seeking help from others | Management of study situation<br><br>Seeking help from others | Organization of behavioral engagement on the learning tasks.<br><br>Seeking help from others<br><br>Collaboration with classmates | Seeking help from others |

(Ke, 2019)

# សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
មហាវិទ្យាល័យអប់រំ

## កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន ជំនាន់ទី២

# របាយការណ៍ស្រាវជ្រាវស្តីអំពីលទ្ធផលសម្រេចបានក្នុងការអនុវត្តការងារកន្លងមករបស់អនុវិទ្យាល័យសំបាន

ដោយលោក **លី យ៉ានី នាយកអនុវិទ្យាល័យសំប៉ាន ស្រុកកោះធំ**
ខេត្ត កណ្តាល

**ថ្នាក់** LUP2A **ក្រុម** B

**ខែមករា ឆ្នាំ២០២២**

ផ្នែកទី១ សេចក្តីផ្តើម

- សាវតា

អនុវិទ្យាល័យសំប៉ាន ស្ថិតនៅភូមិសំប៉ាន ឃុំកោះធំខ ស្រុកកោះធំ ខេត្តកណ្តាលមុនពេលចូលរៀនកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន LUP2 អនុវិទ្យាល័យសំប៉ានបានជួបប្រទះបញ្ហាដូចតទៅ៖

ការចូលរៀនជាក់ស្តែងរបស់សិស្សអនុវិទ្យាល័យសំប៉ានបានតែ៩០% សិស្សសុំប្តូរសាលា នៅចុងឆ្នាំសិក្សាសិស្សបោះបង់ការសិក្សាចំនួន ៧,៤៣% លទ្ធផលសិក្សារបស់សិស្សនៅមានកម្រិត គ្រូបង្រៀនរៀបចំវិញ្ញាសាតេស្ត និងការប្រឡងតេស្តនីមួយៗដោយខ្លួនឯងការជាប់មធ្យមភាគបានតែ៧០% ការបង្រៀនរបស់គ្រូ មិនសូវគោរពេលវេលាចេញ និងចូល ភាគច្រើនសិស្សចូលចិត្តរៀនតែមុខវិជ្ជា គណិតវិទ្យា និង វិទ្យាសាស្រ្តពិតភាគច្រើន សិស្សមិនចេះអាន មិនចេះសរសេរ មិនសូវមានការគោរពដល់គ្រូបង្រៀនមុខវិជ្ជាណាដែលខ្លួនមិនចូលចិត្ត សិស្សគេចម៉ោងមិនចូលសាលា ពេលគ្រូខ្មែរសួរសំណួរច្រើន ។

មាតាបិតាមិនសូវបានចូលរួមជួយដល់ការសិក្សារបស់កូនដែលដឹងថាកូនគាត់កំពង់តែរៀនខ្សោយ ហើយនឹងមិនមានជំនឿមកលើការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ សហគមន៍គ្មានទំនាក់ទំនងជាមួយសាលាដោយពួកគាត់គិតថាសាលារៀនគឺជារបស់លោកនាយកនិងជារបស់លោកគ្រូ អ្នកគ្រូ សហគមន៍មានការចូលរួមតិចតួចភាគច្រើនមិនមានការចូលរួមថែមទាំងបន្ទះបង្អាប់មកលើគណៈគ្រប់គ្រងក្នុងការអភិវឌ្ឍ។

ក្រោយពីទទួលបានការបណ្តុះបណ្តាលកម្មវិធីលើកកម្ពស់គិណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀនមក សាលាមានការផ្លាស់ប្តូរខ្លាំង សិស្សចូលរៀនបាន១០០% កម្រិតនៃការបោះបង់ការសិក្សាមានការថយចុះ សិស្សសម្រុករៀនភាសាខ្មែរច្រើន សិស្សរៀនពីចម្ងាយបានទាំងអស់ គ្រូទទួលបន្ទុកថ្នាក់ប្រើកុំព្យូទ័រគ្រប់គ្នា សហគមន៍ជឿជាក់មកលើសាលារៀន ជាពិសេសជឿជាក់មកលើការដឹកនាំរបស់លោកនាយក សហគមន៍ចូលរួមអភិវឌ្ឍន៍សាលាយ៉ាងផុលផុស នឹងមានការចូលរួមទទួលខុសនឹង ទទួលត្រូវគ្រប់បញ្ហាទាំងអស់ជាមួយលោកនាយកនិងលោកគ្រូ អ្នកគ្រូ។

- ចក្ខុវិស័យសហគមន៍សាលារៀន
  - ➢ បេសកកម្ម
    - ▪ បណ្តុះសិស្សឲ្យមានបំណិនខ្ពស់សម្រាប់ជីវិត និងការងារ និងត្រៀមរួចជាស្រេចដើម្បីចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សា ឬ ចូលរួមទីផ្សារការងារ និង
    - ▪ កែលម្អការអនុវត្តរបស់សាលារៀនឲ្យបំពេញស្តង់ដាសាលារៀនមានប្រសិទ្ធភាព ។ សាលារៀននឹងជួយដល់សិស្សទាំងអស់ដោយគ្មានការរើសអើង លើភាពក្រីក្រ យេនឌ័រ ពិការភាព ឬជនជាតិភាគតិច

    (បរិយាប័ន្ន សមធម៌)។
  - ➢ គោលបំណង
    - ▪ សិស្ស៨០ទៅ៨៥% មានបំណិនខ្ពស់សម្រាប់ជីវិត និងការងារ និងត្រៀមរួចជាស្រេចដើម្បីចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សា ឬ ចូលរួមក្នុងទីផ្សារការងារ នៅឆ្នាំ២០៣០
    - ▪ សាលារៀនបំពេញនូវស្តង់ដាយុទ្ធសាស្រ្តសហគមន៍សាលារៀននៅ៦ឆ្នាំក្រោយ ។ សាលារៀននឹងជួយដល់សិស្សទាំងអស់ដោយគ្មានការរើសអើងលើភាពក្រីក្រ យេនឌ័រ  ពិការភាព ឬជនជាតិភាគតិច( បរិយាប័ន្ន សមធម៌ ) ។

- យុទ្ធសាស្ត្រ និងការផ្លាស់ប្តូរ
  - យុទ្ធសាស្ត្រសហគមន៍សាលារៀន(ឯអា)




- ការអនុវត្តយុទ្ធសាស្ត្រឲ្យមានការផ្លាស់ប្តូរ
  - ការធ្វើតេស្តស្តង់ដាសិស្សវាស់សមត្ថភាពសិស្ស
  - សហគមន៍ប្រើអំណាចសម្រេចចិត្តលើផែនការ ថវិកា និងកិច្ចការសាលារៀន
  - នាយកសាលាប្រើសិទ្ធប្រតិបត្តិជានាកិច្ចការរដ្ឋបាលសាលារៀន និងបង្ហាញលទ្ធផលសិក្សា ចំណូល ចំណាយ និងការរីចចម្រើនស្តង់ដាសាលារៀន
  - យកចិត្តទុកដាក់ថែរក្សាគ្រូបង្រៀន ទាំងសមត្ថភាព និងការរស់នៅ
  - ការអនុវត្តវប្បធម៌គឺ នាំឲ្យបុគ្គលិកអប់រំទាំងអស់ក្នុងសាលារៀន ដោយប្រើអំណាចសម្រាប់ធ្វើតែកិច្ចការដែលត្រូវ
  - ការយកចិត្តទុកដាក់លើការអប់រំថែទាំកុមារតូច ជាកត្តាគន្លឹះនាំឲ្យកុមារមានសមត្ថភាពគ្រឹះ

- វប្បធម៌សហគមន៍សាលារៀន

  ជារបៀបធ្វើកិច្ចការតាមបែបវិមជ្ឈការអំណាចទៅសហគមន៍ និងសាលារៀន ដែលនាំឲ្យគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន សិស្ស និងសហគមន៍ មានកិច្ចការច្បាស់លាស់ និងទទួលខុសត្រូវជាមួយកិច្ចការរបស់ខ្លួន ។

- គុណតម្លៃសហគមន៍សាលារៀន

  ជាការអនុវត្តគំនិតល្អដែលព្រមព្រៀងគ្នាក្នុងរយៈពេលកំណត់គំនិតល្អនោះនឹងក្លាយជាគុណតម្លៃ ។

  សាលារៀន និងសហគមន៍៖

  - នឹងបម្រើប្រយោជន៍រួម និងប្រសើរបំផុតសម្រាប់ប្រជាជន និងសិស្ស
  - គោរព និងថែនាំគ្នាទៅវិញទៅមក
  - រៀនសូត្រ និងធ្វើការងារជាក្រុមជាប់ជាប្រចាំ
  - ផ្តួចផ្តើមគំនិតថ្មីសម្រាប់អភិវឌ្ឍន៍សាលារៀន និងសហគមន៍
  - ធ្វើឲ្យមាននិរន្តរភាពដំណើរការសាលារៀន និងរៀបចំសិស្សសាលារៀនរបស់យើងសម្រាប់រស់ជាមួយជីវិត និងការងារដែលប្រសើរ ។

## ផ្នែកទី២ ផលសម្រេចគោលនយោបាយ

- **ការសិក្សារបស់សិស្ស**






**ក្រាបលទ្ធផលសិស្សរៀនចេះ A,B,C,D,E,F**




| និទ្ទេសរួម | ថ្នាក់ទី៧ | | ថ្នាក់ទី៨ | | ថ្នាក់ទី៩ | | សរុប | | ភាគរយ | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| A | 12 | 5 | 2 | 2 | 4 | 3 | 18 | 10 | 6.67% | 7.41% |
| B | 34 | 24 | 18 | 7 | 32 | 18 | 84 | 49 | 31.11% | 36.30 % |
| C | 43 | 19 | 21 | 11 | 11 | 5 | 75 | 35 | 27.78% | 25.93 % |
| D | 13 | 6 | 25 | 14 | 11 | 4 | 49 | 24 | 18.15% | 17.78 % |
| E | 12 | 4 | 19 | 8 | 4 | 0 | 35 | 12 | 12.96% | 8.89% |
| F | 6 | 4 | 3 | 1 | | 0 | 9 | 5 | 3.33% | 3.70% |
| សរុប | 120 | 62 | 88 | 43 | 62 | 30 | 270 | 135 | 100% | 100% |

## ➢ ការចូលរួមរបស់សហគមន៍

ក្រាបចំនួនថ្នាក់រៀនមានគណៈកម្មការគ្រប់គ្រងថ្នាក់រៀន








## ក្រាបចំនួនសមាសភាពគណៈកម្មការគ្រប់គ្រងសាលារៀន











## ក្រាបលទ្ធផលសិស្សបោះបង់ការសិក្សា










## ក្រាបចំនួនថវិកាសរុបដែលបានមកពីសហគមន៍ និងប្រភពផ្សេងៗ












## ➢ ការគាំទ្ររបស់អ្នកពាក់ព័ន្ធ

### ក្រាបចំនួនសាលារៀន( មត្តេយ្យ បឋម មធ្យម )និងកម្រិតផលៈបានពីសាលាគោលដៅ






## កិច្ចការសំខាន់ៗសាលារៀនគោលដៅបានជួយដល់ប្រជាជន និងស្ថាប័នពាក់ព័ន្ធ មូលដ្ឋាន កម្រិតឧត្តម កម្រិតក្រសួង




## ផ្នែកទី៣ ការផ្លាស់ប្តូរនៅសាលារៀន

១. ១.ក.សាលរៀនអនុវត្តតេស្តស្តង់ដាដើមឆ្នាំ (ថ្នាក់ទី៧)








១.ខ. សាលរៀនអនុវត្តតេស្តស្តង់ដាដើមឆ្នាំ (ថ្នាក់ទី៨)





១.គ. សាលរៀនអនុវត្តតេស្តស្តង់ដាដើមឆ្នាំ (ថ្នាក់ទី៩)





១.២. សាលរៀនអនុវត្តតេស្តស្តង់ដាប្រចាំខែ













## ២.បង្កើត ឬធ្វើបច្ចុប្បន្នភាពគណៈកម្មការគ្រប់គ្រងថ្នាក់រៀន


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និង កីឡា ខេត្តកណ្ដាល
ឯកសារ
គណៈកម្មការគ្រប់គ្រងថ្នាក់រៀន
អនុវិទ្យាល័យសំប៉ាន
ថ្នាក់ទី ៧ "ក"
គណៈកម្មការគ្រប់គ្រង
ថ្នាក់ទី ៧ "ក"
អនុវិទ្យាល័យសំប៉ាន
ឆ្នាំសិក្សា ២០២១ ២០២២
*****






## ២.បង្កើត ឬធ្វើបច្ចុប្បន្នភាពគណៈកម្មការគ្រប់គ្រងថ្នាក់រៀន(ត)













## ៣.១.បង្កើត ឬធ្វើបច្ចុប្បន្នភាពគណៈកម្មការគ្រប់គ្រងសាលារៀនមានសសមាសភាពចំនួន៦នាក់










## ៣.២.បង្កើត ឬធ្វើបច្ចុប្បន្នភាពគណៈកម្មការគ្រប់គ្រងសាលារៀនមានសមាសភាពចំនួន១១នាក់







## ៤.១.ធ្វើផែនការកែលម្អសាលារៀន(រួមជាមួយយុទ្ធសាស្ត្រសាលារៀនសហគមន៍)




## ៣.២.ផ្សព្វផ្សាយផែនការកែលម្អសាលារៀនដល់គណៈកម្មការគ្រប់គ្រងសាលារៀន មាតាបិតា និងសហគមន៍








## ៥.ការបង្រៀន និងរៀន









## ៦.ក.ធ្វើកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំរបស់គ្រូបង្រៀន








## ៦.ខ. ធ្វើកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំរបស់នាយក



## ៧. ប្រជុំពិនិត្យតាមដានប្រចាំខែដឹកនាំដោយនាយកសាលារៀន និងប្រចាំត្រីមាសដឹកនាំដោយគណៈកម្មការគ្រប់គ្រងសាលារៀន




នៅឆ្នាំ ២០២១-២០២២ ក្រុមសាលាក្រៅគោលដៅពួកយើងខ្ញុំនឹងប្តេជ្ញាចិត្តថា  សម្រេចឱ្យបានជាប់ស្តង់ដា ៥
អរគុណ

**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

**មហាវិទ្យាល័យអប់រំ**

**គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា**

# របាយការណ៍ស្រាវជ្រាវអំពី
# ការអនុវត្ត និងផលសម្រេចនៃការគ្រប់គ្រងតាមសាលារៀន
# នៅអនុវិទ្យាល័យ………

**នាមត្រកូល នាមខ្លួនអ្នកសិក្សា**

**របាយការណ៍ស្រាវជ្រាវសម្រាប់បំពេញ**
**លក្ខខណ្ឌតម្រូវក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន**
**កម្រិតបរិញ្ញាបត្រអប់រំ ឯកទេសគ្រប់គ្រងសាលារៀន**

**ជំនាន់ទី២ ឆ្នាំ២០២២**

តាមរយៈការសិក្សា និងអនុវត្តការគ្រប់គ្រងតាមសាលារៀននេះ
ខ្ញុំ/យើងខ្ញុំបានរកឃើញថា ..........................................
............................ ...................................... (ចំណុចសំខាន់ៗ យ៉ាងច្រើន៣ ចំណុច)។

ជាមួយគ្នានេះដែរ ខ្ញុំ/យើងខ្ញុំយល់ឃើញថា .......... ......................................
...................................... ...................................... (ចំណាប់អារម្មណ៍)។

ខ្ញុំ/យើងខ្ញុំសូមឧទ្ទិសស្នាដៃនេះជូន ....... (បើមាន/ បើមិនមានទេ សូមលុបចេញ)

# សង្ខិត្តន័យ

ការស្រាវជ្រាវអំពី "ការអនុវត្ត និងផលសម្រេចនៃការគ្រប់គ្រងតាមសាលារៀននៅ ......" មានចំណោទសួរថា តើការអនុវត្តការគ្រប់គ្រងតាមសាលារៀនតម្រូវឱ្យគណៈគ្រប់គ្រង និងគ្រូបង្រៀនបំពេញកិច្ចការអ្វីខ្លះ និងយ៉ាងដូចម្តេចដើម្បីឱ្យមានផលសម្រេចនៅសាលារៀន ហើយផលសម្រេចនោះបង្ហាញឱ្យឃើញលទ្ធផលសិក្សារបស់សិស្ស ការចូលរួមរបស់សហគមន៍ និងផលជះយ៉ាងណា។ វាមានគោលបំណងចងក្រងបទពិសោធនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន ហើយបន្តស្វែងរកមធ្យោបាយបំពេញការងារឱ្យទទួលផលសម្រេចការសិក្សារបស់សិស្សកាន់តែប្រសើរឡើងឆ្ពោះទៅនិរន្តរភាពសាលារៀន។ វត្ថុបំណងនៃការស្រាវជ្រាវនេះគឺៈ (១) ពន្យល់អំពីលទ្ធផលនៃការសិក្សារបស់សិស្សនៅពេលដែលសាលារៀនបានអនុវត្តការគ្រប់គ្រងតាមសាលារៀន (២) ឆ្លុះបញ្ចាំងអំពីការចូលរួមរបស់សហគមន៍ក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀន (៣) បង្ហាញអំពីផលជះនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនទៅសាលារៀន និងសហគមន៍ផ្សេងទៀត។ ដើម្បីឆ្លើយតបនឹងវត្ថុបំណងនេះ ការស្រាវជ្រាវនេះបានប្រើការរៀបចំការស្រាវជ្រាវប្រតិបត្តិបែបចូលរួមដែលយកជ្រើសយកវិធីសាស្ត្រស្រាវជ្រាវបែបបន្សំរវាង បរិមាណវិស័យ និងគុណវិស័យ។ អ្នកស្រាវជ្រាវបានអនុវត្តការធ្វើតេស្តដើម្បីវាស់សមត្ថភាពរបស់សិស្ស ការសង្កេតដោយចូលរួមផ្ទាល់ ហើយការសម្ភាសជាមួយអ្នកពាក់ព័ន្ធផង និងក្រុមការងារអនុវត្តផងដោយការឆ្លុះបញ្ចាំងបទពិសោធ។

ជាលទ្ធផល ការស្រាវជ្រាវប្រតិបត្តិបានរកឃើញថាៈ

- ការសិក្សារបស់សិស្សៈ
- ការចូលរួមរបស់សហគមន៍ៈ
- ផលជះទៅសាលារៀននិងសហគមន៍ផ្សេងទៀតៈ

ការស្រាវជ្រាវនេះមានអនុសាសន៍ ..................។

# សេចក្តីអះអាង

(សរសេរសេចក្តីអះអាងថារបាយការណ៍ស្រាវជ្រាវនេះជាស្នាដៃដើមរបស់អ្នកសរសេរ រួចហើយសូមលុបការណែនាំនេះចេញ)

ខ្ញុំ/យើងខ្ញុំ ………………………………… សូមធានាអះអាងថា របាយការណ៍ដែលមានចំណងជើងថា "ការអនុវត្ត និងផលសម្រេចនៃការគ្រប់គ្រងតាមសាលារៀននៅអនុវិទ្យាល័យ ………" គឺជាស្នាដៃដើមរបស់ខ្ញុំ/យើងខ្ញុំផ្ទាល់ដែលឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែង ហើយមិនធ្លាប់បានយកទៅប្រើប្រាស់ក្នុងការសិក្សាដើម្បីទទួលសញ្ញាបត្រកម្រិតណាមួយផ្សេងទៀតឡើយ។

| ឈ្មោះ | ហត្ថលេខា | កាលបរិច្ឆេទ |
|---|---|---|

# សេចក្តីថ្លែងអំណរគុណ

(សរសេរសេចក្តីថ្លែងអំណរគុណដល់អ្នកដែលជួយអ្នកដោយផ្ទាល់ក្នុងកិច្ចការស្រាវជ្រាវនេះទាំងផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងស្មារតី យ៉ាងច្រើន ១ទំព័រ រួចហើយសូមលុបការណែនាំនេះចេញ)

ខ្ញុំ/យើងខ្ញុំមានកិត្តិយសបានសរសេររបាយការណ៍ស្រាវជ្រាវនេះក្រោមការសហការ និងគាំទ្រពីគ្រឹះស្ថានស្ថាប័ន សហគមន៍ និងមជ្ឈដ្ឋាននានាដែលខ្ញុំសូមសំដែងនូវអំណរគុណជូនចំពោះ។

ជាដំបូង ខ្ញុំ/យើងខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួងអប់រំ យុវជន និងកីឡា ដែលបានផ្តល់ឱកាស និងការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ដំណើរការអនុវត្តសកម្មភាពនៃការគ្រប់គ្រងតាមសាលារៀនដើម្បីធ្វើការស្រាវជ្រាវនេះ ………

បន្ទាប់មក ខ្ញុំ/យើងខ្ញុំមិននូវការដឹងគុណចំពោះ …… ដែលបាន ……
………

ការស្រាវជ្រាវនេះមិនអាចកើតឡើងបានទេ បើពុំមានការផ្តល់ការគាំទ្រ និងសហការពី …..

ជាចុងក្រោយ ខ្ញុំ/យើងខ្ញុំសូមអរគុណ ……… ចំពោះ ………

# មាតិកា

(សរសេរចំណងជើង/ប្រធានបទខ្លឹមសារនៃមាតិកា និងលេខទំព័រ។ នៅពេលបញ្ចូលទិន្នន័យនិងព័ត៌មានពីដើមដល់ចប់សព្វគ្រប់ សូមចុចលើបញ្ជីមាតិកាខាងក្រោម និងចុចត្រង់ Update Table ហើយជ្រើសយក Update page number only និងចុច OK ជាការស្រេច រួចហើយសូមលុបការណែនាំនេះចេញ)

**សង្ខិត្តន័យ** II
**សេចក្តីអះអាង** III
**សេចក្តីថ្លែងអំណរគុណ** IV
**មាតិកា** V
**បញ្ជីពាក្យកាត់** VII
**បញ្ជីតារាង និងក្រាហ្វ** VIII

**ជំពូក ១ សេចក្តីផ្តើម** 1
១.១ សាវតា 1
១.២ ចំណោទបញ្ហា 2
១.៣ គោលបំណង/វត្ថុបំណងស្រាវជ្រាវ 2
១.៤ សំណួរស្រាវជ្រាវ 2
១.៥ សារៈសំខាន់នៃការស្រាវជ្រាវ 3

**ជំពូក ២ យុទ្ធសាស្ត្រសហគមន៍សាលារៀន និងការគ្រប់គ្រងតាមសាលារៀន** 4
២.១. សហគមន៍សាលារៀន 4
២.២. ការគ្រប់គ្រងតាមសាលារៀន 4
២.៣. ស្តង់ដា និងសូចនាករសាលារៀនមានប្រសិទ្ធភាព 11
២.៤. ការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន និងការគ្រប់គ្រងតាមសាលារៀន 15

**ជំពូក ៣ វិធីសាស្ត្រស្រាវជ្រាវ និងប្រតិបត្តិ** 16
៣.១ ការរៀបចំ និងវិធីសាស្ត្រស្រាវជ្រាវ 16
៣.២ ទីកន្លែងប្រតិបត្តិ 17
៣.៣ វិធីសាស្ត្រប្រមូលទិន្នន័យ និងព័ត៌មាន 18
៣.៥ ការវិភាគទិន្នន័យ 19
៣.៦ សកម្មភាពប្រតិបត្តិ 19

**ជំពូក ៤ ផលសម្រេច និងការឆ្លុះបញ្ចាំង** 23
៤.១ ការបង្ហាញលទ្ធផល 23

៤.២ ការឆ្លុះបញ្ចាំងលើលទ្ធផល 27

**ជំពូក ៥ សេចក្តីសន្និដ្ឋាន និងអនុសាសន៍** 29
៥.១ ការកត់សម្គាល់ភាពប្រែប្រួល 29
៥.២ សេចក្តីសន្និដ្ឋានលើលទ្ធផល 29
៥.៣ អនុសាសន៍សម្រាប់ជាមេរៀនបទពិសោធ 29
៥.៤ កិច្ចការអនុវត្តបន្ត និងការប្តេជ្ញាចិត្ត 29

**ឯកសារយោង** 30
**ឧបសម្ព័ន្ធ** 31
**ប្រវត្តិរូបសង្ខេប** 32

# បញ្ជីពាក្យកាត់

(បើមាន សូមសរសេរពាក្យកាត់ និងពាក្យពេញដែលបានប្រើប្រាស់ក្នុងរបាយការណ៍ស្រាវជ្រាវនេះតាមលំដាប់អក្ខរក្រម រួចហើយសូមលុបការណែនាំនេះចេញ)

| ពាក្យកាត់ | ពាក្យពេញ |
|---|---|
| ក.គ.គ.ស | កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន |
| ស.គ | សៀវភៅគ្រូ |
| ស.ស | សៀវភៅសិស្ស |
| អ.យ.ក | អប់រំ យុវជន និងកីឡា |

# បញ្ជីតារាង និងក្រាហ្វ

(រាយតារាង និងក្រាហ្វដែលបានប្រើប្រាស់ក្នុងរបាយការណ៍ស្រាវជ្រាវនេះ ព្រមទាំងដាក់ទំព័រ រួចហើយសូមលុបការណែនាំនេះចេញ)

តារាង ១.១
តារាង ១.២

ក្រាហ្វ ១.១
ក្រាហ្វ ១.២

# ជំពូក ១
# សេចក្តីផ្តើម

ជំពូកនេះនឹងរៀបរាប់អំពីសាវតានៃការស្រាវជ្រាវនេះ ចំណោទបញ្ហា គោលបំណងស្រាវជ្រាវ សំណួរស្រាវជ្រាវ និងសារៈសំខាន់នៃការស្រាវជ្រាវ ដូចមានសេចក្តីអធិប្បាយដូចខាងក្រោម។

## ១.១ សាវតា

### ១.១.១ គោលនយោបាយអភិវឌ្ឍន៍ជាតិ និងកំណែទម្រង់ការអប់រំ

គោលដៅអភិវឌ្ឍន៍ជាតិឆ្នាំ២០៣០ របស់ប្រទេសកម្ពុជា ........ (រាជរដ្ឋាភិបាលកម្ពុជា ២០១៩)។ សម្រាប់ឆ្នាំ២០៥០ ប្រទេសកម្ពុជា ......... (រាជរដ្ឋាភិបាលកម្ពុជា ២០១៩)។

ដើម្បីឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍ឆ្នាំ២០៣០ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់វិស័យយ៉ាងដូចម្តេច?

### ១.១.២ ការចូលរួមចំណែករបស់សាលារៀន

សាលារៀនអាចចូលរួមចំណែកអ្វីខ្លះឆ្លើយតបនឹងកំណែទម្រង់វិស័យអប់រំផង និងគោលដៅអភិវឌ្ឍន៍ជាតិឆ្នាំ ២០៣០?

បច្ចុប្បន្នបញ្ហាប្រឈមក្នុងវិស័យអប់រំនៅកម្រិតសាលារៀនមានអ្វីខ្លះដែលត្រូវដោះស្រាយជាទិភាព?

### ១.១.៣ សាវតាសាលារៀន

ចូររៀបរាប់អំពីសាវតាសាលារៀន

### ១.១.៤ ស្ថានភាពគ្រូបង្រៀន និងសិស្សតាមឆ្នាំសិក្សា

ចូរបង្ហាញអំពីស្ថានភាព និងស្ថិតិគ្រូបង្រៀន និងសិស្ស

### ១.១.៤ ស្ថានភាព និងការអនុវត្តការងារនៅមុនអនុវត្តការគ្រប់គ្រងតាមសាលារៀន

*ការចូលរៀន និងការបោះការសិក្សារបស់សិស្ស*

*លទ្ធផលសិក្សារបស់សិស្ស*

*ការបង្រៀនរបស់គ្រូបង្រៀន*

*ការងារសហគមន៍*

## ១.២ ចំណោទបញ្ហា

ផ្អែកតាមសាវតា និងស្ថានភាពរបស់សាលារៀន វាបង្ហាញឱ្យឃើញនូវបញ្ហាចន្លោះប្រហោងមួយចំនួនសម្រាប់អនុវិទ្យាល័យ/វិទ្យាល័យ ..... ក្នុងការចូលរួមចំណែកបំពេញការងារឱ្យឆ្លើយតបនឹងកំណែទម្រង់វិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងគោលដៅអភិវឌ្ឍន៍ជាតិឆ្នាំ២០៣០របស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងន័យនេះ សាលារៀនចាំបាច់ផ្លាស់ប្តូររបៀបប្រតិបត្តិការដែលនាំទៅការប្រែប្រួលលើផលសម្រេចរបស់សាលារៀនដើម្បីការសិក្សារបស់សិស្ស។

ដូចនេះ វាមានចំណោទសួរថាតើការអនុវត្តការគ្រប់គ្រងតាមសាលារៀនតម្រូវឱ្យគណៈគ្រប់គ្រង និងគ្រូបង្រៀនបំពេញកិច្ចការអ្វីខ្លះ និងយ៉ាងដូចម្តេច ដើម្បីឱ្យមានផលសម្រេចនៅសាលារៀន ហើយផលសម្រេចនោះបង្ហាញឱ្យឃើញលទ្ធផលសិក្សារបស់សិស្ស ការចូលរួមរបស់សហគមន៍ និងផលជះយ៉ាងណា។ ហេតុនេះ វាជាចាំបាច់ក្នុងការធ្វើការស្រាវជ្រាវមួយនៅសាលារៀនជាក់ស្តែង។

## ១.៣ គោលបំណង/វត្ថុបំណងស្រាវជ្រាវ

ការស្រាវជ្រាវប្រតិបត្តិនេះមានគោលបំណងចម្បងគឺចងក្រងបទពិសោធនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន ហើយបន្តស្វែងរកមធ្យោបាយបំពេញការងារឱ្យទទួលផលសម្រេចការសិក្សារបស់សិស្សកាន់តែប្រសើរឡើងឆ្ពោះទៅនិរន្តរភាពសាលារៀន។ វត្ថុបំណងនៃការស្រាវជ្រាវនេះគឺៈ

(១) ពន្យល់អំពីលទ្ធផលនៃការសិក្សារបស់សិស្សនៅពេលដែលសាលារៀនបានអនុវត្តការគ្រប់គ្រងតាមសាលារៀនដើម្បីស្វែងរកវិធីជួយសិស្សរៀន

(២) ឆ្លុះបញ្ចាំងអំពីការចូលរួមរបស់សហគមន៍ក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀន ដើម្បីរកវិធីបង្កើនការគាំទ្រឱ្យសាលារៀនមានដំណើរការយ៉ាងសកម្ម

(៣) បង្ហាញអំពីផលជះនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនទៅសាលារៀន និងសហគមន៍ផ្សេងទៀត ដើម្បីរកវិធីអនុវត្តឱ្យឈានឆ្ពោះក្នុងការអភិវឌ្ឍសហគមន៍សាលារៀន

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបនឹងវត្ថុបំណងស្រាវជ្រាវប្រតិបត្តិនេះ អ្នកស្រាវជ្រាវបានរៀបចំសំណួរស្រាវជ្រាវចំនួន៣ ដូចខាងក្រោមៈ

(១) តើការអនុវត្តការគ្រប់គ្រងតាមសាលារៀននាំឱ្យការសិក្សារបស់សិស្សប្រែប្រួលយ៉ាងដូចម្តេច?

(២) តើសហគមន៍ចូលរួមចំណែកធ្វើអ្វីខ្លះក្នុងដំណើរការអនុវត្តការគ្រប់គ្រងតាមសាលារៀន? ហើយបង្ហាញចំណាប់អារម្មណ៍យ៉ាងណា?

(៣) តើការអនុវត្តការគ្រប់គ្រងតាមសាលារៀននាំឱ្យមានផលជះអ្វីខ្លះទៅដល់សាលារៀន និងសហគមន៍ផ្សេងទៀត? ហើយមានផលជះកម្រិតណា?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវប្រតិបត្តិនេះមានសារៈសំខាន់ជាចម្បងដល់សាលារៀនដែលបានអនុវត្តផ្ទាល់។ វាបានឆ្លុះបញ្ចាំងឱ្យឃើញទិន្នន័យនិងព័ត៌មានជាក់ស្តែងនៃការសិក្សារបស់សិស្ស និងដំណើរការសាលារៀនដើម្បីរកមធ្យោបាយកែលម្អឱ្យសមស្របតាមបរិបទសាលារៀន។ វាបានធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សប្រសើរឡើង ហើយទទួលការចាប់អារម្មណ៍ខ្លាំងនិងការគាំទ្រពីអាណាព្យាបាលសិស្ស និងសហគមន៍។

អ្នកស្រាវជ្រាវបានរកឃើញគន្លឹះសំខាន់សម្រាប់ធ្វើឱ្យសាលារៀនមានដំណើរការផ្អែកលើផលសម្រេច។ វាប្រាប់ពីរបៀបបំពេញការងារ និងរបៀបសហការគ្នារបស់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន បុគ្គលិកគាំទ្រ គណៈកម្មការសាលារៀន និងសហគមន៍។ គន្លឹះនេះអាចនាំជាបាននូវការដឹកនាំ និងការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាពចំពោះសិស្ស។

លទ្ធផលនៃការស្រាវជ្រាវប្រតិបត្តិនេះអាចរក្សាទុកជាឯកសារបទពិសោធនៃការអនុវត្តការស្រាវជ្រាវប្រតិបត្តិបែបចូលរួម និងការអនុវត្តការគ្រប់គ្រងតាមសាលារៀនក្នុងបរិបទសាលារៀនជាក់ស្តែង។ វាអាចមានប្រយោជន៍ជាមេរៀនបទពិសោធដល់អ្នកអប់រំ អ្នកស្រាវជ្រាវ និងមន្ត្រីនៃការិយាល័យ មន្ទីរ និងក្រសួងអប់រំ យុវជន និងកីឡា ក្នុងការជួយសាលារៀនមានដំណើរការកាន់តែប្រសើរ។

# ជំពូក ២
# យុទ្ធសាស្ត្រសហគមន៍សាលារៀន និងការគ្រប់គ្រងតាមសាលារៀន

ក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងអធិប្បាយអំពីទ្រឹស្តី គំនិត និងការអនុវត្តអំពីយុទ្ធសាស្ត្រសហគមន៍សាលារៀន ការគ្រប់គ្រងតាមសាលារៀន និងស្តង់ដាសាលារៀនមានប្រសិទ្ធភាព ដូចមានសេចក្តីពន្យល់ដូចខាងក្រោម។

## ២.១. សហគមន៍សាលារៀន

### ២.១.១ ចក្ខុវិស័យសហគមន៍សាលារៀន

### ២.១.២ បេសកកម្ម

### ២.១.៣ គោលបំណង

### ២.១.៤ យុទ្ធសាស្ត្រ និងការផ្លាស់ប្តូរ

### ២.១.៥ វប្បធម៌សហគមន៍សាលារៀន

### ២.១.៦ គុណតម្លៃសហគមន៍សាលារៀន

## ២.២. ការគ្រប់គ្រងតាមសាលារៀន

### ២.២.១ អត្ថន័យនៃការគ្រប់គ្រងតាមសាលារៀន

ការគ្រប់គ្រងតាមសាលារៀនមានន័យថា ................

### ២.២.២ តួនាទីរបស់គណៈគ្រប់គ្រង គ្រូបង្រៀន និងបុគ្គលិកគាំទ្រ

ក្នុងការគ្រប់គ្រងតាមសាលារៀន តួអង្គសំខាន់ៗនៅសាលារៀនមានតួនាទីដូចខាងក្រោម៖

តួនាទីរបស់គណៈគ្រប់គ្រងសាលារៀន

- 

តួនាទីរបស់គ្រូបង្រៀន

- 

តួនាទីរបស់គ្រូបន្ទុកថ្នាក់

- 

តួនាទីរបស់បុគ្គលិកទីចាត់ការ

- 

### ២.២.៣ កិច្ចការចម្បងសម្រាប់អនុវត្តនៅសាលារៀន

ក្នុងដំណើរការគ្រប់គ្រងតាមសាលារៀន គណៈគ្រប់គ្រងសាលារៀនត្រូវអនុវត្តកិច្ចការចំនួន៩ ដោយដឹកនាំ សម្របសម្រួល និងពិនិត្យតាមដានជាប្រចាំ។ សកម្មភាពលម្អិតសម្រាប់កិច្ចការនីមួយៗ ត្រូវបានពន្យល់តារាង ២.១។ កិច្ចការទាំង៩នោះរួមមានៈ

១) អនុវត្តតេស្តស្តង់ដា (ដើមឆ្នាំ ប្រចាំខែ និងប្រចាំត្រីមាស)
២) បង្កើត ឬធ្វើបច្ចុប្បន្នភាពគណៈកម្មការគ្រប់គ្រងថ្នាក់រៀន
៣) បង្កើត ឬធ្វើបច្ចុប្បន្នភាព គណៈកម្មការគ្រប់គ្រងសាលារៀន
៤) ធ្វើផែនការកែលម្អសាលារៀន (រួមជាមួយយុទ្ធសាស្ត្រសាលារៀនសហគមន៍)
៥) អនុវត្តការងាររៀន និងបង្រៀន
៦) ធ្វើកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំរបស់គ្រូបង្រៀន បុគ្គលិកទីចាត់ការ និងគណៈគ្រប់គ្រងសាលារៀន
៧) ប្រជុំពិនិត្យតាមដានប្រចាំខែ ដឹកនាំដោយនាយកសាលារៀន និងប្រចាំត្រីមាសដឹកនាំដោយគណៈកម្មការគ្រប់គ្រងសាលារៀន
៨) ស្វ័យវាយតម្លៃសាលារៀនមានប្រសិទ្ធភាព
៨) អធិការកិច្ចវាយតម្លៃការបង្រៀនរបស់គ្រូបង្រៀន ការគ្រប់គ្រងថ្នាក់ និងការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន

*តារាង ២.១៖ សេចក្តីលម្អិតសម្រាប់អនុវត្តកិច្ចការទាំង៩*

| កិច្ចការចម្បង | សកម្មភាពរបស់សាលារៀន | កាលបរិច្ឆេទ |
|---|---|---|
| **១. សាលារៀនអនុវត្តតេស្តស្តង់ដា**<br>(ក)ដើមឆ្នាំ<br>(ខ)ប្រចាំខែ និង<br>(គ)ត្រីមាស | ១.១ គណៈគ្រប់គ្រងដឹកនាំសកម្មភាព ធ្វើតេស្តស្តង់ដាដើមឆ្នាំតាមការណែនាំ៖ រួមមានវិញ្ញាសា ដំណើរការធ្វើតេស្ត ដោយមានការចូលរួមពីមាតាបិតា សហគមន៍ និងអ្នកពាក់ព័ន្ធ និងការផ្សព្វផ្សាយលទ្ធផលជាសាធារណៈក្នុង និងក្រៅសាលារៀន<br><br>១.២ គណៈគ្រប់គ្រង និងក្រុមបច្ចេកទេសរៀបចំថ្នាក់រៀន តាមកម្រិតសមត្ថភាពសិស្ស ក្នុងនោះមានការរៀបចំគ្រូបង្រៀនសម្រាប់បង្រៀនថ្នាក់(AB) (CD) និង(EF)។ ចំពោះគ្រូបង្រៀនថ្នាក់សិស្សរៀនយឺតច្រើន ត្រូវមានការគាំទ្របន្ថែម តាមរយៈការពិភាក្សា និងការផ្តល់យោបល់ ពីគ្រូបង្រៀន ប្រធានក្រុមបច្ចេកទេស គណៈកម្មការគ្រប់គ្រងថ្នាក់រៀន សាលារៀន និងអាជ្ញាធរដែនដី | មករា<br><br>ប្រចាំខែ<br><br>ប្រចាំត្រីមាស |
| **២. បង្កើត ឬធ្វើបច្ចុប្បន្នភាព គណៈកម្មការគ្រប់គ្រងថ្នាក់រៀន** | ២.១ គណៈគ្រប់គ្រង និងក្រុមបច្ចេកទេស ជួយគ្រូបន្ទុកថ្នាក់នីមួយៗ ធ្វើកិច្ចការជាមួយគ្រូមុខវិជ្ជា ដើម្បីដឹកនាំសកម្មភាពបង្កើតគណៈកម្មការគ្រប់គ្រងថ្នាក់រៀន ដែលមានសកម្មភាពសំខាន់ៗដូចខាងក្រោម៖<br>• សកម្មភាពទី១៖ ប្រជុំជាមួយសិស្សក្នុងថ្នាក់ ដោយមានការចូលរួមពីអ្នកអាណាព្យាបាល ដើម្បីឱ្យគាត់បានដឹង និងគាំទ្រចំពោះផែនការរៀនប្រចាំឆ្នាំ ៣ខែ និងប្រចាំខែរបស់កូនរបស់គាត់ផ្ទាល់។ ផែនការរៀនរបស់សិស្សនេះ គឺធ្វើដោយផ្អែកលើលទ្ធផលតេស្តដើមឆ្នាំ ដើម្បីជួយឱ្យសិស្សម្នាក់ៗធ្វើការប្តេជ្ញាចិត្តនៅចំពោះមុខមាតាបិតាខ្លួន និងគ្រូបង្រៀន និងក៏ | មករា |

| | | |
|---|---|---|
| | មានការសួរបញ្ជាក់ពីគ្រូបន្ទុកថ្នាក់ ទៅមាតាបិតាសិស្ស អំពីការការគាំទ្រដល់ការសិក្សារបស់កូន តាមផែនការ<br>• សកម្មភាពទី២៖ បន្តប្រជុំជាមួយអ្នកអាណាព្យាបាលសិស្សក្នុងថ្នាក់ ដើម្បីជ្រើសរើសតំណាងមាតាបិតាសិស្ស សម្រាប់បង្កើតគណៈកម្មការគ្រប់គ្រងថ្នាក់រៀន ដើម្បីជួយគាំទ្រសកម្មភាពបង្រៀនរបស់គ្រូ ការរៀនរបស់សិស្ស ជាពិសេសសិស្សមកពីគ្រួសារជួបការលំបាក និងការជួយកែលម្អបរិស្ថានថ្នាក់រៀន។ល។<br>• សកម្មភាពទី៣៖ បន្តប្រជុំជាមួយអ្នកអាណាព្យាបាលសិស្ស ដើម្បីសុំយោបល់គាំទ្រ អំពីការបង្កើតក្រុមសន្សំប្រាក់តាមថ្នាក់រៀន សម្រាប់ជួយកូនៗឱ្យចេះសន្សំសំចៃលុយកាក់ក្នុងការចាយវាយប្រចាំថ្ងៃ និងឱ្យចេះជួយគ្រួសារតាមរយៈកម្មវិធីរកចំណូល។ សកម្មភាពនេះនឹងភ្ជាប់ជាមួយ ផែនការវិនិយោគរបស់សិស្ស អាចម្នាក់ៗ ក្រុមតូច ឬក្រុមធំ<br><br>២.២ សាលារៀនរៀបចំឯកសារគណៈកម្មការថ្នាក់រៀន និងមានការឯកភាពពី (ក)ប្រធានក្រុមបច្ចេកទេស / នាយករង (ខ)នាយក (គ)គណៈកម្មការគ្រប់គ្រងសាលារៀន និងអាចមានអាជ្ញាធរដែនដីផងដែរកាន់តែប្រសើរ<br><br>២.៣ សាលារៀនផ្សព្វផ្សាយឯកសារគណៈកម្មការគ្រប់គ្រងថ្នាក់រៀន ដល់មេភូមិ និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន ដើម្បីអាចជួយឱ្យសកម្មភាពជួយសិស្សតាមថ្នាក់ ជាយុទ្ធនាការនៃការពង្រឹងកម្លាំងសហគមន៍ចូលរួម ក្នុងការអនុវត្តកំណែទម្រង់វិស័យអប់រំ | |
| **៣. បង្កើត ឬធ្វើបច្ចុប្បន្នភាពគណៈកម្មការគ្រប់គ្រងសាលារៀន** | ៣.១ សាលារៀនរៀបចំសកម្មភាពជ្រើសរើសគណៈកម្មការគ្រប់គ្រងសាលារៀន ដោយមានការបោះឆ្នោត ដូចមានណែនាំក្នុង «សេចក្តីណែនាំប្រតិបត្តិ យុទ្ធសាស្ត្រសហគមន៍សាលារៀន» តាមស្ថានភាព និងតម្រូវការជាក់ស្តែងរបស់សាលារៀននីមួយៗ សាលារៀនអាចបន្ថែមសមាសភាពមួយចំនួនទៀត ទៅលើចំនួនគណៈកម្មការគ្រប់គ្រងសាលារៀន ដែលបានជ្រើសរើសតាមការបោះឆ្នោត ដូចជាបន្ថែម៖<br>• មេភូមិទាំងអស់ក្នុងមូលដ្ឋាន និងអ្នកពាក់ព័ន្ធសំខាន់ៗមួយចំនួនទៀត ជាសមាជិកសកម្មក្នុងការជួយសិស្ស និង<u>អភិវឌ្ឍសាលារៀន</u><br>• ប្រធានគណៈកម្មការគ្រប់គ្រងថ្នាក់រៀនទាំងអស់ ក្នុងសាលារៀន ឱ្យទៅជាសមាជិកសកម្មផងដែរ ក្នុងការជួយសិស្ស និង<u>អភិវឌ្ឍថ្នាក់រៀន</u><br><br>៣.២ សាលារៀនរៀបចំកម្មវិធីឥណទានសម្រាប់ជួយគ្រូក្នុងសាលារៀន ដោយផ្សារភ្ជាប់កម្មវិធីសិស្សសន្សំប្រាក់តាមថ្នាក់ និងកម្មវិធីវិនិយោគរបស់សាលារៀន<br><br>៣.៣ គណៈគ្រប់គ្រងដឹកនាំធ្វើផែនការវិនិយោគរបស់សាលារៀន ដោយមានការចូលរួមជាគំនិតជាបច្ចេកទេស និងជាធនធានផ្សេងទៀតដែលមូលដ្ឋានមាន និងការគាំទ្រ សម្រាប់ធ្វើឱ្យសាលារៀនក្លាយទៅជាមជ្ឈមណ្ឌលអភិវឌ្ឍសហគមន៍ សម្រាប់ជួយសិស្ស ជួយគ្រូ និងជួយគ្រួសារជួបការលំបាក | មករា |
| **៤. ធ្វើផែនការកែលម្អសាលារៀន (រួមជាមួយយុទ្ធសាស្ត្រសាលារៀនសហគមន៍)** | ៤.១ គណៈគ្រប់គ្រងធ្វើការជាមួយប្រធានក្រុមបច្ចេកទេស តាក់តែងសេចក្តីព្រាងយុទ្ធសាស្ត្រសហគមន៍សាលារៀន រួមមាន៖<br>• ក្របខណ្ឌផលសម្រេចរយៈពេល៦ឆ្នាំ៖ ផែនការសមិទ្ធិកម្មសូចនាករគន្លឹះ ឆ្នាំ២០២២ ដល់ ២០២៦ (ទំព័រ៣១)<br>• ផលសម្រេចអប់រំ និងក្រុមគោលដៅសិក្សារៀនសូត្រ៣ឆ្នាំ<br>• ផែនការកែលម្អសាលារៀនប្រចាំឆ្នាំ | មករា |

| | | |
|---|---|---|
| | ៤.២ គណៈគ្រប់គ្រងប្រជុំឆ្លងសេចក្តីព្រាង យុទ្ធសាស្ត្រសហគមន៍សាលារៀន ជាមួយគ្រូបង្រៀន ប្រធានក្រុមបច្ចេកទេស គណៈកម្មការគ្រប់គ្រងសាលារៀន និងសមាជិកសកម្មទាំងអស់ ដើម្បីសុំយោបល់បន្ថែម និងការគាំទ្រក្នុងការអនុវត្តយុទ្ធសាស្ត្រ<br><br>៤.៣ គ្រូបន្ទុកថ្នាក់ និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន រួមជាមួយក្រុមប្រឹក្សាកុមារថ្នាក់រៀន ទៅសហការណ៍ជាមួយមេភូមិ ដើម្បីយកសេចក្តីព្រាងផែនការទាំងនេះ ទៅពិគ្រោះយោបល់បន្ថែម ជាមួយអ្នកភូមិ ឬអ្នកជិតខាងមួយចំនួន ដែលមិនបានចូលរួមក្នុងសកម្មភាពខាងលើ ដើម្បីបានជាតុចូលបន្ថែម<br><br>៤.៤ គណៈគ្រប់គ្រងធ្វើការជាមួយប្រធានក្រុមបច្ចេកទេស កែលម្អសេចក្តីព្រាងយុទ្ធសាស្ត្រសហគមន៍សាលារៀន សម្រេចចុងក្រោយ រួមមាន៖<br>• ក្របខណ្ឌផលសម្រេចរយៈពេល៦ឆ្នាំ៖ ផែនការសមិទ្ធិកម្មសូចនាកគន្លឹ ឆ្នាំ២០២២ ដល់ ២០២៦ (ទំព័រ៣១)<br>• ផលសម្រេចអប់រំ និងក្រុមគោលដៅសិក្សារៀនសូត្រ៣ឆ្នាំ<br>• ផែនការកែលម្អសាលារៀនប្រចាំឆ្នាំ<br>៤.៥ គណៈគ្រប់គ្រង និងគណៈកម្មការគ្រប់គ្រងសាលារៀន ផ្សព្វផ្សាយយុទ្ធសាស្ត្រសហគមន៍សាលារៀន ដល់ផ្នែកពាក់ព័ន្ធក្នុងមូលដ្ឋាន។ រីឯក្រុមប្រឹក្សាកុមារ និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន ជួយផ្សព្វផ្សាយយុទ្ធសាស្ត្រសហគមន៍សាលារៀន ដល់អ្នកភូមិ និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន | |
| **៥ ការងាររៀន និងបង្រៀន** | ៥.១ គណៈគ្រប់គ្រង និងក្រុមបច្ចេកទេស ជួយក្រុមគ្រូដែលបង្រៀនជាមួយគ្នា តាមកម្រិតថ្នាក់ និងមុខវិជ្ជា ឱ្យធ្វើផែនការបង្រៀន៦ឆ្នាំ ៣ឆ្នាំ និង១ឆ្នាំសម្រាប់គ្រូបង្រៀនម្នាក់ៗ (ដោយកំណត់ចំនួនសិស្ស ABCកើនឡើង និងDEF ថយចុះ អាស្រ័យលើកម្រិតសមត្ថភាពសិស្សជាក់ស្តែង ដែលសាលារៀនបានរៀបចំតាមកម្រិតសមត្ថភាព)។ ទិន្នន័យក្នុងផែនការបង្រៀនរបស់គ្រូបង្រៀនម្នាក់ៗ ត្រូវធ្វើឡើងដោយផ្អែកលើ ទិន្នន័យលទ្ធផលសិក្សារបស់សិស្ស ABCកើនឡើង និង DEF ថយចុះ ដូចបានកំណត់ក្នុងយុទ្ធសាស្ត្រសហគមន៍សាលារៀន និងព័ត៌មានបន្ថែមមានក្នុងផែនការកែលម្អសាលារៀនឆ្នាំ២០២២របស់សាលារៀននីមួយៗ<br><br>៥.២ គណៈគ្រប់គ្រង និងក្រុមបច្ចេកទេស ដឹកនាំគ្រូបង្រៀនតាមកម្រិតថ្នាក់ និងតាមមុខវិជ្ជា រៀបចំកិច្ចការរៀន និងបង្រៀនសំខាន់ៗមួយចំនួនដូចខាងក្រោម៖<br>• ធ្វើថ្មី ឬធ្វើបច្ចុប្បន្នភាព <u>បំណែងចែកកម្មវិធីសិក្សាសម្រាប់បង្រៀនប្រចាំសប្តាហ៍</u> ក្នុងឆ្នាំសិក្សានីមួយៗ ទៅតាមស្ថានភាពការសិក្សាជាក់ស្តែងរបស់សិស្សក្នុងសាលារៀន<br>• ធ្វើថ្មី ឬធ្វើបច្ចុប្បន្នភាព <u>គម្រោងបង្រៀនមួយមេរៀន មានច្រើនម៉ោងសិក្សា</u> សម្រាប់ជួយឱ្យគ្រូបង្រៀនម្នាក់ៗ អាចយកទៅច្នៃប្រឌិត និងបំពេញបន្ថែមទៅតាមស្ថានភាពសិក្សារបស់សិស្ស និងទេព្យកោសល្យបង្រៀនរបស់គ្រូ តាមរយៈការរៀបចំកិច្ចតែងការបង្រៀន ដោយអនុវត្តការបង្រៀនតាមគន្លងជីវិតថ្មី បង្កើនការប្រើប្រាស់បច្ចេកវិទ្យាក្នុងការរៀន និងបង្រៀន<br>• ធ្វើថ្មី ឬធ្វើបច្ចុប្បន្នភាព<u>កាលវិភាគបង្រៀន</u> ផ្តោតតាមលំនាំបង្រៀនខាងក្រោម តាមរយៈការប្រើប្រាស់សកម្មភាពរៀន និងបង្រៀនតាមគន្លងជីវិតថ្មី ដោយបន្តពង្រឹងការអនុវត្តការរៀន និងបង្រៀនដោយប្រើបច្ចេកវិទ្យា ឱ្យកាន់តែច្រើនឡើង (រៀន/បង្រៀនពីចម្ងាយ) និងកាត់បន្ថយ (រៀន/ការបង្រៀនទល់មុខ) ដោយប្រើឯកសារខាងក្រោម ដែលសាលារៀនទាំងអស់ទទួលបានពី ក្រុមការងាររបស់ក្រសួងអប់រំ រួមមានជានាគុណភាព មជ្ឈមសិក្សា និងបណ្តុះបណ្តាល។ល។ ដឹកនាំបច្ចេកទេស ដោយសាកលវិទ្យាល័យភ្នំពេញ ដែលឯកសារនេះមានទាំងផ្នែករឹង និងទន់៖<br>    ◦ <u>សន្លឹកកិច្ចការទី១</u> (សម្រាប់សិស្សស្វ័យសិក្សាព័ត៌មានលម្អិតក្នុងមេរៀនមួយ)<br>    ◦ <u>សន្លឹកកិច្ចការទី២</u> (សម្រាប់សិស្សស្វ័យសិក្សាខ្លឹមសារមេរៀនសង្ខេបផ្តោតលើបញ្ញត្តិ) | កុម្ភៈ |

| | | |
|---|---|---|
| | ○ សន្លឹកកិច្ចការទី៣ (សម្រាប់សិស្សស្វ័យហ្វឹកហាត់ អអនុវត្តធ្វើលំហាត់ ឆ្លើយសំណួរ និងដោះស្រាយចំណោទ ដើម្បីសិស្សអាចយល់ដឹងកាន់តែស៊ីជម្រៅចំពោះបញ្ញត្តិខ្លឹមសារមេរៀននីមួយៗ) និង<br>○ សន្លឹកកិច្ចការទី៤ (សម្រាប់សិស្សស្វ័យវាយតម្លៃចំណេះដឹងមួយមេរៀន ដោយខ្លួនឯង)<br>• ផ្ដល់ឱ្យគ្រូម្នាក់ៗ សម្រាប់ប្រើជាជំនួយ ក្នុងការបង្រៀនសិស្សប្រចាំថ្ងៃ រាល់ឯកសារតេស្តស្ដង់ដាកម្រិតជាតិ និងអន្តរជាតិ រួមមានៈ<br>○ តេស្តដើមឆ្នាំ<br>○ តេស្តប្រចាំខែ<br>○ តេស្តប្រចាំត្រីមាស / ឆមាស | |
| **៦ ធ្វើកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំរបស់គ្រូបង្រៀន បុគ្គលិកទីចាត់ការ និងគណៈគ្រប់គ្រងសាលារៀន** | ៦.១ គណៈគ្រប់គ្រងសាលារៀន ប្រជុំជាមួយក្រុមបច្ចេកទេសទាំងអស់ ដើម្បីប្រាប់ពីគោលបំណង សារៈសំខាន់ សកម្មភាព និងដំណើរការធ្វើកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ របស់គ្រូបង្រៀន បុគ្គលិកទីចាត់ការ និងរបស់គណៈគ្រប់គ្រងសាលារៀន និងឯកភាពគ្នាអំពីរចនាសម្ព័ន្ធគ្រប់គ្រង និងសម្រេចលើកិច្ចព្រមព្រៀង ដែលអាចមាននាយករង និងក្រុមបច្ចេកទេស ជាអ្នកទទួលបន្ទុកក្នុងកម្រិតណាមួយនៃការកំណត់សូចនាករ និងសកម្មភាពកិច្ចព្រមព្រៀងរបស់គ្រូបង្រៀន និងបុគ្គលិកទីចាត់ការ។ល។<br><br>៦.២ នាយករង / ក្រុមបច្ចេកទេស ដឹកនាំគ្រូបង្រៀនតាមកម្រិតក្រុមមុខវិជ្ជា / តាមកម្រិតថ្នាក់ និងបុគ្គលិកទីចាត់ការ តាក់តែងកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំជាមួយគ្នា ដើម្បីអាចឱ្យគ្រូបង្រៀនម្នាក់ៗបានផ្ទៀងផ្ទាត់ និងប្រៀបធៀបកម្រិតសូចនាករ រវាងគ្រូបង្រៀនម្នាក់ ទៅគ្រូបង្រៀនផ្សេងទៀតក្នុងក្រុមជាមួយគ្នា តាមកម្រិតថ្នាក់ របស់មុខវិជ្ជានីមួយៗ ដែលទទួលបន្ទុកបង្រៀនសិស្ស តាមកម្រិតសមត្ថភាពផ្សេងៗគ្នា AB CD និងEF<br><br>៦.៣ គណៈនាយក និងបុគ្គលិកទីចាត់ការ ធ្វើកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ ជាមួយគ្នាសម្រាប់បង្ហាញ និងទទួលការឯកភាពពីគណៈកម្មការគ្រប់គ្រងសាលារៀន<br><br>៦.៤ គ្រូបង្រៀនផ្សព្វផ្សាយ កិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំរបស់ខ្លួន ដល់សិស្ស មាតាបិតាសិស្សក្នុងថ្នាក់ និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន។ រីឯគណៈនាយក និងបុគ្គលិកទីចាត់ការផ្សព្វផ្សាយកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ ដល់គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងសាលារៀន សហគមន៍ និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន<br><br>៦.៥ សាលារៀនរៀបចំការធ្វើស្វ័យវាយតម្លៃកិច្ចលទ្ធផលប្រចាំឆ្នាំ នៅពាក់កណ្ដាលឆ្នាំ និងចុងឆ្នាំតាមគម្រូណែនាំ។ លទ្ធផលដែលបានពីការស្វ័យវាយតម្លៃ សាលារៀនអាចប្រើសម្រាប់រៀបចំពិធីអប់រំសោទរ និងលើកទឹកចិត្តដល់គ្រូបង្រៀន / គណៈនាយក ដែលបានធ្វើកិច្ចការល្អជាងគេប្រចាំឆ្នាំ នៅកម្រិតថ្នាក់រៀន និងកម្រិតសាលារៀនតាមបែបប្រពៃណី ដូចជាការជូនវត្ថុអនុស្សាវរីយ៍ដល់គ្រូបង្រៀន មានដូចជាៈ សំបុត្រថ្លែងអំណរគុណ សាប៊ូ ក្រមា ថ្នាំដុសធ្មេញ កន្សែងដៃ ផ្លែឈើជ្រក់ បន្លែ មាន់ និងទាសម្រាប់ចិញ្ចឹម។ល។ រាល់អ្វីណាដែលសិស្ស និងមាតាបិតាសិស្សមានស្រាប់ និងងាយរកក្នុងមូលដ្ឋាន។ | កុម្ភៈ |
| **៧ ប្រជុំពិនិត្យតាមដានប្រចាំខែដឹកនាំដោយនាយកសាលារៀន និងប្រចាំត្រីមាសដឹកនាំដោយគណៈកម្មការគ្រប់គ្រងសាលារៀន** | ៧.១ គណៈគ្រប់គ្រងសាលា ក្រុមបច្ចេកទេស និងគណៈកម្មការគ្រប់គ្រងសាលារៀន កំណត់កាលវិភាគ និងរបៀបវារៈសំខាន់ៗសម្រាប់ជ្រើសរើសបន្ថែម ក្រៅពីការ**<u>បង្ហាញលទ្ធផលសិក្សារបស់សិស្ស និងការបង្រៀនរបស់គ្រូ</u>**ម្នាក់ៗតាមក្រុមមុខវិជ្ជា ក្នុងការប្រជុំពិនិត្យតាមដានប្រចាំខែ និងត្រីមាសសម្រាប់ឆ្នាំ២០២២ ក្នុងនោះមានសកម្មភាពមួយចំនួនដូចជាៈ<br>• ការធ្វើតេស្ត (ដើមឆ្នាំ ប្រចាំខែ និងត្រីមាស/ឆមស) | មីនា<br>ប្រចាំខែ<br>ប្រចាំត្រីមាស |

| | | |
|---|---|---|
| | • បង្កើត / ធ្វើបច្ចុប្បន្នភាពគណៈកម្មការគ្រប់គ្រងថ្នាក់រៀន ផ្សារភ្ជាប់ជាមួយផែនការរៀនសូត្រសិស្សប្រចាំឆ្នាំ ៣ខែ និងប្រចាំខែនៃឆ្នាំសិក្សា<br>• បង្កើត / ធ្វើបច្ចុប្បន្នភាពគណៈកម្មការគ្រប់គ្រងសាលារៀន ក្នុងការគ្រប់គ្រងការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន<br>• ធ្វើផែនការកែលម្អសាលារៀន ផ្អែកលើៈ<br>    ○ ក្របខណ្ឌផលសម្រេចរយៈពេល៦ឆ្នាំៈ ផែនការសមិទ្ធិកម្មសូចនាកគន្លឹ ឆ្នាំ ២០២២ ដល់២០២៦ ( ទំព័រ៣១ )<br>    ○ ផលសម្រេចអប់រំ និងក្រុមគោលដៅសិក្សារៀនសូត្រ៣ឆ្នាំ<br>• ជួយគ្រូអនុវត្តកិច្ចការរៀន និងបង្រៀនតាមគន្លងជីវិតថ្មី រួមជាមួយៈ<br>    ○ ការជួយសិស្សរៀនយឺត ដោយផ្សារភ្ជាប់សកម្មភាពប្រកួតមុខវិជ្ជាគោល<br>    ○ ការរៀបចំព្រឹត្តិការណ៍បង្ហាញ ឬជាពិព័ណស្នាដៃសិស្ស អំពីផលសម្រេចពីការអនុវត្តបំណិនរកចំណូលអនុវត្តនៅតាមផ្ទះ និងការរៀបចំផ្ទះបៃតង ផ្អែកលើកម្មវិធីវិនិយោគរបស់សិស្សជាបុគ្គល ក្រុមតូច និងឬក្រុមធំ<br>• ជួយគ្រូបង្រៀន បុគ្គលិកទីចាត់ការ និងគណៈគ្រប់គ្រងធ្វើកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ និងស្វ័យវាយតម្លៃពាក់កណ្ដាលឆ្នាំ និងដំណាច់ឆ្នាំ<br>• អនុវត្តផែនការអធិការកិច្ចវាយតម្លៃការបង្រៀនរបស់គ្រូ និងការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀនរបស់គណៈគ្រប់គ្រង<br><br>៧.២ គណៈនាយក ដឹកនាំសកម្មភាពប្រជុំពិនិត្យតាមដានប្រចាំខែ តាមកាលវិភាគ និងរបៀបវារៈដែលបានកំណត់ក្នុងផែនការប្រជុំពិនិត្យតាមដានឆ្នាំ និងមានរបាយការណ៍ប្រជុំ តាមគម្រូណែនាំ។ របាយការណ៍ប្រជុំប្រចាំខែ អាចផ្សព្វផ្សាយដល់គណៈកម្មការគ្រប់គ្រងថ្នាក់រៀន និងក្រុមប្រឹក្សាកុមារសាលារៀន។<br><br>៧.៣ គណៈនាយក ជួយគណៈកម្មការគ្រប់គ្រងសាលារៀន ដឹកនាំសកម្មភាពប្រជុំពិនិត្យតាមដានប្រចាំត្រីមាស តាមកាលវិភាគ និងរបៀបវារៈដែលបានកំណត់ក្នុងផែនការប្រជុំពិនិត្យតាមដានឆ្នាំ និងមានរបាយការណ៍ប្រជុំ តាមគម្រូណែនាំ។ របាយការណ៍ប្រជុំពិនិត្យតាមដាន នឹងត្រូវបញ្ជូនទៅការិយាល័យអប់រំ រៀងតាល់៣ខែ ( មានគម្រូរបាយការណ៍ ក្នុងឯកសារសេចក្ដីណែនាំការគ្រប់គ្រងតាមសាលារៀន ) | |
| **៨. អធិការកិច្ចវាយតម្លៃការបង្រៀនរបស់គ្រូបង្រៀន ការគ្រប់គ្រងថ្នាក់ និងការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន** | ៨.១ គណៈគ្រប់គ្រង ធ្វើកិច្ចការជាមួយក្រុមបច្ចេកទេស អំពីដំណើរការអធិការកិច្ចវាយតម្លៃ (ក) ការបង្រៀន (ខ)ការគ្រប់គ្រងថ្នាក់ និង(គ)ការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន ដើម្បីរៀបចំ (ក)គោលបំណង (ខ)កំណត់សកម្មភាព និង(គ)ការចូលរួមរបស់សហគមន៍ ក្នុងនោះមានៈ<br>__**សម្រាប់គ្រូបង្រៀនៈ**__<br>• គ្រូបង្រៀនម្នាក់ៗធ្វើសំណើរមកគណៈកម្មការគ្រប់គ្រងថ្នាក់រៀន និងគណៈគ្រប់គ្រងសាលារៀន សុំឱ្យមានការធ្វើអធិការកិច្ច ដោយគ្រូជាអ្នកកំណត់ប្រធានបទ និងពេលវេលាសម្រាប់ (ក)ការបង្រៀន និង(ខ)ការគ្រប់គ្រងថ្នាក់រៀន។ បញ្ជាក់ថា គ្រូបង្រៀនត្រូវធ្វើសំណើរសុំអធិការកិច្ចវាយតម្លៃនេះ រួមគ្នាជាមួយលោកគ្រូ និងអ្នកគ្រូផ្សេងទៀត របស់ក្រុមបច្ចេកទេសងាយស្រួលក្នុងការរៀនពីគ្នា និងបានព្រមព្រៀងគ្នា អំពីប្រធានបទ និងពេលវេលាវាយតម្លៃ<br>• គណៈគ្រប់គ្រង / នាយករងយកសំណើររបស់គ្រូបង្រៀនទាំងអស់មករៀបចំ ចងក្រងជាកាលវិភាគ កម្មវិធីអធិការកិច្ចវាយតម្លៃការបង្រៀន និងការគ្រប់គ្រងថ្នាក់រៀនសម្រាប់សាលារៀនទាំងមូល | មីនា<br><br>ប្រចាំខែ<br>ឬប្រចាំត្រីមាស |

| | | |
|---|---|---|
| | • គណៈគ្រប់គ្រងសាលា / នាយករងផ្សព្វផ្សាយផែនការ និងកាលវិភាគអធិការកិច្ចវាយតម្លៃការបង្រៀនរបស់គ្រូ និងការគ្រប់គ្រងថ្នាក់រៀន ដល់គ្រូបង្រៀនទាំងអស់ គណៈកម្មការគ្រប់គ្រងថ្នាក់រៀន សាលារៀន និងក្រុមប្រឹក្សាកុមារយុវជន<br>• ក្នុងដំណើរការអធិការកិច្ចវាយតម្លៃ ការបង្រៀន ឬការគ្រប់គ្រងថ្នាក់តាមប្រធានបទ និងពេលវេលា ដែលគ្រូស្នើសុំ គណៈគ្រប់គ្រងអាចរៀបចំជាក្រុមតូចៗ សម្រាប់អនុវត្តកិច្ចការនេះ ជៀសវាងការមិនបានអនុវត្ត ឬដោយសាររង់ចាំតែនាយកសាលា។ល។ ដូចនេះក្រុមអ្នកវាយតម្លៃអាចមានៈ (ក)នាយក ឬនាយករង (ខ)គ្រូបង្រៀនមុខវិជ្ជាដូចគ្នា និងកម្រិតថ្នាក់ដូចគ្នា នៅក្នុងសាលា ឬមកពីសាលារៀនជិតខាង (គ)ប្រធាន / អនុប្រធាន / សមាជិក...គណៈកម្មការគ្រប់គ្រងថ្នាក់រៀន (ឃ)គណៈកម្មការគ្រប់គ្រងសាលារៀន ក្នុងករណីគាត់ចាប់អារម្មណ៍ និងចង់ចូលរួម (ឃ) មេភូមិ មេឃុំ នគរបាលប៉ុស្តិ៍ មណ្ឌលសុខភាព វត្ត... និង(ង)មាតាបិតាសិស្សដែលមានកូនរៀនក្នុងថ្នាក់ និងស្ម័គ្រចិត្តចូលរួម។ល។<br>• យក / នាយករងធ្វើសេចក្តីព្រាង របាយការណ៍អធិការកិច្ចវាយតម្លៃ ការបង្រៀន និងគ្រប់គ្រងថ្នាក់រៀន សម្រាប់ឱ្យគ្រូបង្រៀនបានពិនិត្យ និងឯកភាពមុនពេលអនុម័តសម្រេច ផ្សព្វផ្សាយ និងរក្សាទុកសម្រាប់ប្រើប្រាស់បន្តនៅពេលក្រោយទៀត<br><u>**សម្រាប់សាលារៀន**</u><br>• គណៈគ្រប់គ្រងសាលារៀនទាំងអស់ ក្នុងមូលដ្ឋានឃុំ ឬស្រុក រួមមាន(ក)សាលាមតេយ្យ (ខ)សាលាបឋម និង(គ)សាលាមធ្យម ប្រជុំគ្នាធ្វើផែនការអធិការកិច្ចវាយតម្លៃប្រចាំឆ្នាំ ដោយមានការកំណត់ប្រធានបទ និងពេលវេលាសមស្រប ដែលអាចអនុវត្តទៅបាន។ ចំពោះប្រធានបទ សាលារៀននីមួយៗ អាចជ្រើសរើសស្តង់ដា និងសូចនាករដែលសាលារៀនគិតថានឹងអនុវត្តឱ្យបានលទ្ធផលល្អសម្រាប់ឱ្យក្រុមការងារធ្វើអធិការកិច្ចវាយតម្លៃ រួមជាមួយពេលវេលា អាច១ដង ឬ២ដង ឬ៣ដងក្នុង១ឆ្នាំ តាមស្ថានភាពជាក់ស្តែង<br>• ផែនការ និងកាលវិភាគអធិការកិច្ចវាយតម្លៃនេះ នឹងត្រូវផ្សព្វផ្សាយដល់សាលារៀនទាំងអស់ ជាពិសេសដល់គណៈកម្មការគ្រប់គ្រងសាលារៀន និងអាជ្ញាធរដែនដី<br>• ក្នុងដំណើរការអធិការកិច្ចវាយតម្លៃ សាលារៀនតាមប្រធានបទ មានការរៀបចំក្រុមការងារដែលមានសមាសភាព ទាំងបីចូលរួម មានសាលាមតេយ្យ សាលាបឋម និងសាលាមធ្យម សម្រាប់អនុវត្តកិច្ចការនេះ។ ដូចនេះក្រុមអ្នកវាយតម្លៃអាចមានសមាសភាពៈ (ក) ការិយាល័យអប់រំ (ខ)នាយក / នាយករង (គ)ប្រធានក្រុមបច្ចេកទេស (ឃ)គ្រូបង្រៀន (គ)ប្រធាន / អនុប្រធាន / សមាជិក...គណៈកម្មការគ្រប់គ្រងថ្នាក់រៀន / សាលារៀន (ង) មេភូមិ មេឃុំ នគរបាលប៉ុស្តិ៍ មណ្ឌលសុខភាព វត្ត...។ល។<br>• ការិយាល័យអប់រំ / នាយកសាលា / នាយករងធ្វើសេចក្តីព្រាង របាយការណ៍អធិការកិច្ចវាយតម្លៃសាលារៀនតាមប្រធានបទ សម្រាប់ឆ្លងជាមួយម្ចាស់សាលា និងអាចឱ្យម្ចាស់សាលាបានបំពេញបន្ថែម និងកែតម្រូវលើខ្លឹមសារ ទិន្នន័យ ព័ត៌មានចាំបាច់មួយចំនួន មុននឹងឯកភាពសម្រាប់អនុម័តចុងក្រោយ ដែលអាចផ្សព្វផ្សាយ និងរក្សាទុកសម្រាប់ប្រើប្រាស់បន្តនៅពេលក្រោយទៀត | |
| **៩. ស្វ័យវាយតម្លៃសាលារៀនមានប្រសិទ្ធភាព** | ៩.១ បុគ្គលិកទីចាត់ការ នាយករងរដ្ឋបាល នាយករងបច្ចេកទេស និងប្រធានក្រុមបច្ចេកទេស ដែលទទួលបន្ទុកគ្រប់គ្រងទិន្នន័យស្តង់ដាសាលារៀន <u>រៀបចំបទបង្ហាញ</u>អំពីទិន្នន័យនីមួយៗ ទៅតាមប្រភេទសូចនាកនៃស្តង់ដាទាំង៥ អំពីសាលារៀនមានប្រសិទ្ធភាព<br>• ពាក់កណ្តាលឆ្នាំ<br>• ដំណាច់ឆ្នាំ<br><br>៩.២ បុគ្គលិកទីចាត់ការ នាយករងរដ្ឋបាល នាយករងបច្ចេកទេស និងប្រធានក្រុមបច្ចេកទេស ដែលទទួលបន្ទុកគ្រប់គ្រងទិន្នន័យស្តង់ដាសាលារៀន <u>ធ្វើបទបង្ហាញ</u>អំពីទិន្នន័យនីមួយៗ ទៅតាមប្រភេទសូចនាកនៃស្តង់ដាទាំង៥ អំពីសាលារៀនមានប្រសិទ្ធភាព ដល់ក្រុមប្រឹក្សាកុមារយុវ | មីនា<br><br>ប្រចាំឆមាស<br><br>ប្រចាំឆ្នាំ |

| | | |
|---|---|---|
| | ជន គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងថ្នាក់រៀន និងសាលារៀន ដើម្បីពិភាក្សារិះរកមធ្យោបាយកែលម្អរបៀបធ្វើកិច្ចការ ប្រសិនលទ្ធផលកន្លងមកមានការខ្វះខាត<br>• ពាក់កណ្ដាលឆ្នាំ<br>• ដំណាច់ឆ្នាំ<br><br>៩.៣ គណៈគ្រប់គ្រងសាលា ធ្វើរបាយការណ៍ស្វ័យវាយតម្លៃសាលារៀនមានប្រសិទ្ធភាព (មាន៥ស្តង់ដា) ពាក់កណ្ដាលឆ្នាំ និងដំណាច់ឆ្នាំ សម្រាប់ផ្ញើជូនការិយាល័យអប់រំ និងផ្សព្វផ្សាយក្នុងសហគមន៍ | |

## ២.៣. ស្តង់ដា និងសូចនាករសាលារៀនមានប្រសិទ្ធភាព

យោងតាមយុទ្ធសាស្ត្រសហគមន៍សាលារៀន ស្តង់ដាសាលារៀនមានប្រសិទ្ធភាពមានចំនួន៥ ស្តង់ដាដែលរួមមាន៖ (១) សាលារៀនដំណើរការសម្រាប់ផលសម្រេចការអប់រំ និងការសិក្សារបស់សិស្ស (២) ថ្នាក់រៀនដំណើរការសម្រាប់ការបង្រៀន និងការរៀនរបស់សិស្សម្នាក់ៗ (៣) ភាពជាម្ចាស់នៃសាលារៀនសហគមន៍ (៤) ដំណើរប្រតិបត្តិការសាលារៀន និង (៥) គណនេយ្យភាពថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។

សាលារៀនមួយអាចចាត់ទុកថាបំពេញបាននូវស្តង់ដាអប្បរមា លុះណាសាលារៀននោះមានពិន្ទុសរុបយ៉ាងតិច ២១០ ពិន្ទុ ហើយស្តង់ដានីមួយៗត្រូវបំពេញបាននូវពិន្ទុអប្បរមារបស់ខ្លួន ដូចតារាង ២.២។ ទោះបីសាលារៀនមានពិន្ទុ២១០ ឬច្រើនជាងក៏ដោយ បើស្តង់ដាណាមួយទទួលបានពិន្ទុអប្បរមាទេ សាលារៀននោះមិនជាប់ស្តង់ដាអប្បរមាឡើយ។

*តារាង ២.២៖ ពិន្ទុអប្បរមា និងពិន្ទុអតិបរមាសម្រាប់ស្តង់ដានីមួយៗ*

| | ស្តង់ដាទី១ | ស្តង់ដាទី២ | ស្តង់ដាទី៣ | ស្តង់ដាទី៤ | ស្តង់ដាទី៥ | ពិន្ទុសរុប |
|---|---|---|---|---|---|---|
| ពិន្ទុអប្បរមា | ៣៩ | ៤៨ | ៤៨ | ៤៨ | ២៧ | ២១០ |
| ពិន្ទុអតិបរមា | ៥២ | ៦៤ | ៦៤ | ៦៤ | ៣៦ | ២៨០ |

ដើម្បីឱ្យសាលារៀនបំពេញស្តង់ដាសាលារៀនមានប្រសិទ្ធភាពសម្រាប់អនុវិស័យអប់រំកុមារតូច/បឋមសិក្សា/មធ្យមសិក្សា សាលារៀននិងភាគីពាក់ព័ន្ធចាំបាច់ត្រូវខិតខំប្រតិបត្តិការងារឱ្យសម្រេចសូចនាករក្នុងស្តង់ដានីមួយៗ ដូចខាងក្រោម៖

*តារាង ២.៣៖ សូចនាករសម្រាប់ស្តង់ទី១*

| ស្តង់ដាទី១៖ សាលារៀនដំណើរការសម្រាប់ផលសម្រេចការអប់រំ និងការសិក្សារបស់សិស្ស | |
|---|---|
| ល.រ | សូចនាករ |
| ១.១ | |
| ១.២ | |
| ១.៣ | |
| ១.៤ | |
| ១.៥ | |

| | |
|---|---|
| ១.៦ | |
| ១.៧ | |
| ១.៨ | |
| ១.៩ | |
| ១.១០ | |
| ១.១១ | |
| ១.១២ | |
| ១.១៣ | |

ស្តង់ដាទី១នេះ គឺផ្តោតលើបំពេញតួនាទីរបស់គណៈគ្រប់គ្រងសាលារៀនក្នុងការសម្រេចទិន្នន័យសម្រាប់សូចនាករក្នុងស្តង់ដាទី១នេះ។

*តារាង ២.៤៖ សូចនាករសម្រាប់ស្តង់ទី២*

| ស្តង់ដាទី២៖ ថ្នាក់រៀនដំណើរការសម្រាប់ការបង្រៀន និងការរៀនរបស់សិស្សម្នាក់ៗ | |
|---|---|
| ល.រ | សូចនាករ |
| ២.១ | |
| ២.២ | |
| ២.៣ | |
| ២.៤ | |
| ២.៥ | |
| ២.៦ | |
| ២.៧ | |
| ២.៨ | |
| ២.៩ | |
| ២.១០ | |
| ២.១១ | |
| ២.១២ | |
| ២.១៣ | |
| ២.១៤ | |
| ២.១៥ | |
| ២.១៦ | |

ស្តង់ដាទី២នេះ គឺផ្តោតលើបំពេញតួនាទីរបស់គ្រូបង្រៀនក្នុងការសម្រេចទិន្នន័យសម្រាប់សូចនាករក្នុងស្តង់ដាទី២នេះ។

*តារាង ២.៥៖ សូចនាករសម្រាប់ស្តង់ទី៣*

| ស្តង់ដាទី៣៖ ភាពជាម្ចាស់នៃសាលារៀនសហគមន៍ | |
|---|---|
| ល.រ | សូចនាករ |
| ៣.១ | |
| ៣.២ | |
| ៣.៣ | |
| ៣.៤ | |
| ៣.៥ | |
| ៣.៦ | |
| ៣.៧ | |
| ៣.៨ | |
| ៣.៩ | |
| ៣.១០ | |
| ៣.១១ | |
| ៣.១២ | |
| ៣.១៣ | |
| ៣.១៤ | |
| ៣.១៥ | |
| ៣.១៦ | |

ស្តង់ដាទី៣នេះ គឺផ្តោតលើបំពេញតួនាទីរបស់គណៈកម្មការគ្រប់គ្រងសាលារៀនក្នុងការសម្រេចទិន្នន័យសម្រាប់សូចនាករក្នុងស្តង់ដាទី៣នេះ។

*តារាង ២.៦៖ សូចនាករសម្រាប់ស្តង់ទី៤*

| ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការសាលារៀន | |
|---|---|
| ល.រ | សូចនាករ |
| ៤.១ | |
| ៤.២ | |

| | |
|---|---|
| ៤.៣ | |
| ៤.៤ | |
| ៤.៥ | |
| ៤.៦ | |
| ៤.៧ | |
| ៤.៨ | |
| ៤.៩ | |
| ៤.១០ | |
| ៤.១១ | |
| ៤.១២ | |
| ៤.១៣ | |
| ៤.១៤ | |
| ៤.១៥ | |
| ៤.១៦ | |

ស្តង់ដាទី៤នេះ គឺផ្តោតលើបំពេញតួនាទីរបស់គណៈគ្រប់គ្រងសាលារៀនក្នុងការសម្រេចទិន្នន័យសម្រាប់សូចនាករក្នុងស្តង់ដាទី៤នេះ។

*តារាង ២.៧ សូចនាករសម្រាប់ស្តង់ដ៍ទី៥*

| ស្តង់ដាទី៥៖ គណនេយ្យភាពថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ | |
|---|---|
| ល.រ | សូចនាករ |
| ៥.១ | |
| ៥.២ | |
| ៥.៣ | |
| ៥.៤ | |
| ៥.៥ | |
| ៥.៦ | |
| ៥.៧ | |
| ៥.៨ | |
| ៥.៩ | |

ស្តង់ដាទី៥នេះ គឺផ្តោតលើបំពេញតួនាទីរបស់ថ្នាក់ជាតិ និងក្រោមជាតិក្នុងការសម្រេចទិន្នន័យសម្រាប់សូចនាករក្នុងស្តង់ដាទី៥នេះ។

## ២.៤. ការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន និងការគ្រប់គ្រងតាមសាលារៀន

ក្នុងការអនុវត្តដើម្បីឱ្យសម្រេចនូវដំណាក់កាលអភិវឌ្ឍសហគមន៍សាលារៀន នាយកសាលា គណៈកម្មការគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនត្រូវទទួលខុសត្រូវរួមគ្នា។ សាលារៀនមានដំណាក់អភិវឌ្ឍចំនួន៤ ដូចខាងក្រោម (ក្រសួងអ.យ.ក ២០២១ ទំ.១១)៖

- ដំណាក់កាលទី១ នៅឆ្នាំទី១ គឺការធ្វើឱ្យសាលារៀន និងថ្នាក់រៀនមានដំណើរការសម្រាប់ការសិក្សារៀនសូត្ររបស់សិស្ស
- ដំណាក់កាលទី២ នៅឆ្នាំទី២ គឺការធ្វើឱ្យសាលារៀនបំពេញស្តង់ដាអប្បរមានៃសាលារៀនមានប្រសិទ្ធភាព
- ដំណាក់កាលទី៣ នៅឆ្នាំទី៣ គឺការធ្វើឱ្យសាលារៀនឆ្ពោះទៅរកការរក្សានិរន្តរភាពជាមួយកម្មវិធីបំណិនរកចំណូល
- ដំណាក់កាលទី៤ នៅឆ្នាំទី៤ គឺ សាលារៀនមានដំណើរការប្រកបដោយនិរន្តរភាព និងឈានឆ្ពោះទៅដូចសាលារៀននៃប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់។

ការអនុវត្តឱ្យកើតផលសម្រេចពិតជាអាចទៅរួច នៅពេលដែលមានការចូលរួមនិងប្តេជ្ញាចិត្តរបស់គណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនមុនគេ។ ភាគីពាក់ព័ន្ធដទៃទៀតនឹងចូលរួមជាបន្តបន្ទាប់។ ដូចនេះ ចាប់ផ្តើមចេញពីគណៈគ្រប់គ្រងសាលាដែលត្រូវបំពេញការងារផ្អែកលើលទ្ធផល និងដឹកនាំគណៈកម្មការគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងអ្នកពាក់ព័ន្ធដទៃទៀតឱ្យធ្វើកិច្ចការផ្តោតលទ្ធផលដូចគ្នាដែរ។ គ្រប់តួអង្គគប្បីសួរថា កិច្ចការដែលខ្លួនកំពុងធ្វើបានជួយអ្វីខ្លះដល់ភាពប្រសើរនៃការសិក្សារបស់សិស្ស។

# ជំពូក ៣
# វិធីសាស្ត្រស្រាវជ្រាវ និងប្រតិបត្តិ

ជំពូកនេះនឹងពន្យល់អំពីការរៀបចំនិងវិធីសាស្ត្រស្រាវជ្រាវ ទីកន្លែងប្រតិបត្តិ វិធីប្រមូលព័ត៌មានសកម្មភាពប្រតិបត្តិ និង ការវិភាគទិន្នន័យដើម្បីរកលទ្ធផលតបតាមវត្ថុបំណង និងសំណួរស្រាវជ្រាវនេះ។ ក្នុងការស្រាវជ្រាវ អ្នកស្រាវជ្រាវបានវិភាគបញ្ហាសាលារៀន រៀបចំសកម្មភាពប្រតិបត្តិដោយផ្អែកលើកិច្ចការចម្បងទាំង៩ និងប្រមូលទិន្នន័យនិងព័ត៌មានដោយផ្តោតលើលទ្ធផលលើការសិក្សារបស់សិស្ស ការចូលរបស់សហគមន៍ និងផលជះទៅសាលារៀន និងសហគមន៍ផ្សេងទៀត។

សំណួរស្រាវជ្រាវមាន (១) តើការអនុវត្តការគ្រប់គ្រងតាមសាលារៀននាំឱ្យការសិក្សារបស់សិស្សប្រែប្រួលយ៉ាងដូចម្តេច? (២) តើសហគមន៍ចូលរួមចំណែកធ្វើអ្វីខ្លះក្នុងដំណើរការអនុវត្តការគ្រប់គ្រងតាមសាលារៀន? ហើយបង្ហាញចំណាប់អារម្មណ៍យ៉ាងណា? (៣) តើការអនុវត្តការគ្រប់គ្រងតាមសាលារៀននាំឱ្យមានផលជះអ្វីខ្លះទៅដល់សាលារៀន និងសហគមន៍ផ្សេងទៀត? ហើយមានផលជះកម្រិតណា?

## ៣.១ ការរៀបចំ និងវិធីសាស្ត្រស្រាវជ្រាវ

អ្នកស្រាវជ្រាវបានរៀបចំការស្រាវជ្រាវប្រតិបត្តិបែបចូលរួម។ ក្នុងន័យនេះ អ្នកស្រាវជ្រាវជាអ្នកចូលរួមអនុវត្តដោយផ្ទាល់នៅសាលារៀនជាមួយអ្នកពាក់ព័ន្ធ ហើយប្រមូលទិន្នន័យនិងព័ត៌មានដោយខ្លួនឯង។ ទិន្នន័យនិងព័ត៌មានមួយភាគទទួលបានតាមរយៈការឆ្លុះបញ្ចាំងលើការចូលរួមដោយផ្ទាល់ និងមួយភាគទៀតទទួលបានពីប្រមូលទិន្នន័យពីអ្នកពាក់ព័ន្ធ។

ដើម្បីឆ្លើយនឹងសំណួរស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានជ្រើសរើសយកវិធីសាស្ត្រស្រាវជ្រាវបែបបន្សំរវាងបរិមាណវិស័យ (ដែលត្រូវការទិន្នន័យទាំងជាតួលេខ) និងគុណវិស័យ (ដែលត្រូវការទិន្នន័យ និងព័ត៌មានជាអក្សររូបភាព)។ ការស្រាវជ្រាវនេះបានផ្តោតលើការសិក្សាបែបបរិមាណវិស័យដែលគាំទ្រដោយគុណវិស័យ។

### ៣.១.១ បរិមាណវិស័យ

ការស្រាវជ្រាវត្រូវការទិន្នន័យជាតួលេខអំពី (១) ការសិក្សារបស់សិស្ស (២) ការចូលរួមរបស់សហគមន៍ និង (៣) ផលជះទៅសាលារៀន និងសហគមន៍ផ្សេងទៀត (ដូចបង្ហាញក្នុងតារាង ៣.១)។ ដើម្បីទទួលទិន្នន័យតួលេខទាំងនេះ អ្នកស្រាវជ្រាវបានធ្វើតេស្តនៅសាលារៀន ពិនិត្យបញ្ជីឈ្មោះសិស្ស ពិនិត្យបញ្ជីគណៈកម្មការគ្រប់គ្រងថ្នាក់រៀននិងសាលារៀន បញ្ជីចំណូលចវិកា និងរបាយការណ៍លទ្ធផលការងាររបស់សាលារៀន។

*តារាង ៣.១៖ ទិន្នន័យសម្រាប់បរិមាណវិស័យ*

| ទិន្នន័យដែលត្រូវការ | ទិន្នន័យតួលេខ |
|---|---|
| ការសិក្សារបស់សិស្ស | • ចំនួនសិស្សចូលរៀន<br>• ចំនួនសិស្សបោះបង់ការសិក្សា<br>• ចំនួនសិស្សរៀនចេះនិងទទួលនិទ្ទេស ABCD EF |

| | |
|---|---|
| ការចូលរួមរបស់សហគមន៍ | • ចំនួនថ្នាក់រៀនមានគណៈកម្មការគ្រប់គ្រងថ្នាក់រៀន<br>• ចំនួនសមាសភាពគណៈកម្មការគ្រប់គ្រងសាលារៀន<br>• ចំនួនថវិកាសរុបដែលបានពីសហគមន៍ និងប្រភពផ្សេងៗ (គ្រប់ប្រភព និងប្រភេទ) |
| ផលជះទៅសាលារៀន និងសហគមន៍ផ្សេងទៀត | • ចំនួនសាលារៀន (មត្តេយ្យ បឋម និងមធ្យម) និងកម្រិតផលជះបានពីសាលាគោលដៅ/ក្រៅគោលដៅ |

### ៣.១.២ គុណវិស័យ

ក្នុងការបំពេញសេចក្តីបន្ថែមលើការសិក្សាបែបបរិមាណវិស័យខាងលើ ការស្រាវជ្រាវក៏ត្រូវការទិន្នន័យនិងព័ត៌មានជាពាក្យពេចន៍និងរូបភាពអំពី (១) ការសិក្សារបស់សិស្ស (២) ការចូលរួមរបស់សហគមន៍ និង (៣) ផលជះទៅសាលារៀន និងសហគមន៍ផ្សេងទៀតដែរ (ដូចបង្ហាញក្នុងតារាង ៣.២)។ ដើម្បីទទួលទិន្នន័យនិងព័ត៌មានទាំងនេះ អ្នកស្រាវជ្រាវបានសង្កេត និងសម្ភាសដោយកត់ត្រាសកម្មភាព និងថតយករូបភាពអំពីសកម្មភាព។

*តារាង ៣.២៖ ទិន្នន័យសម្រាប់គុណវិស័យ*

| ទិន្នន័យដែលត្រូវការ | ទិន្នន័យនិងព័ត៌មានជាពាក្យពេចន៍/រូបភាព |
|---|---|
| ការសិក្សារបស់សិស្ស | • សកម្មភាពសិស្សចូលរៀន<br>• ហេតុនាំឱ្យសិស្សបោះបង់ការសិក្សា<br>• សកម្មភាពនាំឱ្យសិស្សរៀនចេះ |
| ការចូលរួមរបស់សហគមន៍ | • សកម្មភាពចូលរួមរបស់គណៈកម្មការគ្រប់គ្រងថ្នាក់រៀន<br>• សកម្មភាពចូលរួមរបស់គណៈកម្មការគ្រប់គ្រងសាលារៀន<br>• សកម្មភាពចូលរួមរបស់សហគមន៍ |
| ផលជះទៅសាលារៀន និងសហគមន៍ផ្សេងទៀត | • ការពិពណ៌នាអំពីសាលារៀន (មត្តេយ្យ បឋម និងមធ្យមសិក្សា) និងកម្រិតផលជះបានពីសាលាគោលដៅ/ក្រៅគោលដៅ<br>• សកម្មភាព/កិច្ចការសំខាន់ៗដែលសាលារៀន បានជួយដល់ប្រជាជន និងស្ថាប័នពាក់ព័ន្ធក្នុងកម្រិតមូលដ្ឋាន/កម្រិតខេត្ត/និងកម្រិតក្រសួង |

## ៣.២ ទីកន្លែងប្រតិបត្តិ

### ៣.២.១ ទីកន្លែងអនុវត្តន៍ដោយផ្ទាល់

ការស្រាវជ្រាវនេះបានធ្វើឡើងនៅសាលារៀនចំនួន ... គឺអនុវិទ្យាល័យ/វិទ្យាល័យ .... ដែលមានទីតាំងក្នុងខណ្ឌ/ស្រុក .... រាជធានី/ខេត្ត ............. ចាប់ពីខែ ....ឆ្នាំ២០២១ ដល់ខែ ... ឆ្នាំ២០២២។ សាលារៀននេះ/ទាំង

នេះត្រូវយកមកធ្វើជាកន្លែងអនុវត្តន៍ផ្ទាល់ផង និងប្រមូលទិន្នន័យនិងព័ត៌មានផងដែរ។ (បើមានច្រើន អាចរៀបចំជាតារាងបាន)

### ៣.២.២ ទីកន្លែងអនុវត្តន៍ដោយប្រយោល

សាលារៀនចំនួន ..... ផ្សេងទៀតក៏បានអនុវត្តតាមលំនាំដូចគ្នានេះដែរ (ដូចបង្ហាញក្នុងតារាង ...)។ អ្នកស្រាវជ្រាវបានជួយសាលារៀនទាំងនោះដោយប្រយោលតាមរយៈការសហការអនុវត្តកិច្ចការជាមួយគណៈគ្រប់គ្រងសាលារៀនទាំងនោះ។

*តារាង ៣.៣៖ បញ្ជីឈ្មោះសាលារៀនដែលបានអនុវត្តកិច្ចការដោយប្រយោល*

| ល.រ | ឈ្មោះសាលារៀន | ខណ្ឌ/ស្រុក | រាជធានី/ខេត្ត |
|---|---|---|---|
| | | | |
| | | | |
| | | | |

## ៣.៣ វិធីសាស្រ្តប្រមូលទិន្នន័យ និងព័ត៌មាន

ការប្រមូលទិន្នន័យសម្រាប់ការស្រាវជ្រាវនេះបានធ្វើឡើងវិធីសាស្រ្តខាងក្រោម៖

### ៣.៣.១ ការធ្វើតេស្ត

អ្នកស្រាវជ្រាវបានអនុវត្តការធ្វើតេស្តយ៉ាងយកចិត្តទុកដាក់ និងហ្មត់ចត់ ដើម្បីវាស់សមត្ថភាពរបស់សិស្ស។ ការធ្វើតេស្តគឺធ្វើឡើងនៅដើមគ្រា និងនៅចុងគ្រា ដើម្បីកំណត់ភាពប្រែប្រួលលើការសិក្សារបស់សិស្ស។ អ្នកស្រាវជ្រាវបានយកលទ្ធផលនៃការធ្វើតេស្តជាទិន្នន័យតួលេខសម្រាប់វិភាគ និងបកស្រាយ។ លទ្ធផលការសិក្សារបស់សិស្សដែលចូលរួមប្រឡងថ្នាក់ខេត្តនិងថ្នាក់ជាតិក៏យកមកប្រើប្រាស់ដែរ។

ជាក់ស្តែង ការធ្វើតេស្តនៅអនុវិទ្យាល័យ/វិទ្យាល័យបានធ្វើឡើងចំនួន ...... ដង គឺលើកទី១នៅខែ ..... លើកទី២ នៅខែ .... ។

### ៣.៣.២ ការសង្កេត

អ្នកស្រាវជ្រាវបានសង្កេតជាប្រចាំនូវសកម្មភាពនានាពាក់ការសិក្សារបស់សិស្ស ការចូលរួមរបស់សហគមន៍ និងការសហការជាមួយសាលាដទៃទៀតដែលនាំឱ្យមានផលជះក្នុងពេលអនុវត្តការគ្រប់គ្រងតាមសាលារៀន។ ការសង្កេតនេះគឺធ្វើឡើងបែបការសង្កេតដោយចូលរួមផ្ទាល់។ អ្នកស្រាវជ្រាវបានកត់ត្រា និងថតរូបសកម្មភាពទាំងនោះដោយរួមទាំងទិន្នន័យតួលេខ ពាក្យពេចន៍ និងរូបភាព។ ការសង្កេតនេះក៏ចងក្រងទិន្នន័យ និងព័ត៌មាននៅមុនពេល និងនៅពេលអនុវត្តការគ្រប់គ្រងតាមសាលារៀនផងដែរដើម្បីកំណត់ឱ្យឃើញភាពប្រែប្រួល។

### ៣.៣.៣ ការសម្ភាស

ដើម្បីបំពេញបន្ថែមដែលទទួលបានពីការធ្វើតេស្ត និងការសង្កេត អ្នកស្រាវជ្រាវបានសម្ភាសសិស្ស គ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន និងអាណាព្យាបាលសិស្សដើម្បីទទួល

ទិន្នន័យនិងព័ត៌មានក្នុងតារាង ៣.២។ អ្នកស្រាវជ្រាវបានអនុវត្តកិច្ចការផង និងប្រមូលទិន្នន័យផង។ ចំណែកខ្លះនៃទិន្នន័យនិងព័ត៌មានគឺបានមកពីការឆ្លុះបញ្ចាំងរបស់អ្នកស្រាវជ្រាវ។

## ៣.៥ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យនេះមានពីរផ្នែក។ ផ្នែកទី១ ទិន្នន័យបរិមាណវិស័យដូចក្នុងតារាង ៣.១ ត្រូវបានវិភាគរកចំនួនសរុប មធ្យមភាគ និងភាគរយ ដោយប្រើ Microsoft Excel។ ការបកស្រាយគឺពន្យល់ន័យទៅលទ្ធផលនៃតួលេខ។ ផ្នែកទី២ ទិន្នន័យគុណវិស័យដូចតារាង ៣.២ ត្រូវបានប្រើការវិភាគខ្លឹមសារលើពាក្យពេចន៍ និងរូបភាពដែលទទួលបាន។ ការវិភាគខ្លឹមសារនេះមាន ៥ ជំហាន៖ (១) រៀបចំប្រមូលទិន្នន័យ/ព័ត៌មានចូលគ្នា (២) កំណត់ប្រធានបទដែលពាក់ព័ន្ធនឹងការសិក្សារបស់សិស្ស ការចូលរួមរបស់សហគមន៍ និងផលជះទៅសាលារៀននិងសហគមន៍ផ្សេងទៀត (៣) រៀបចំកូដសម្គាល់ទៅតាមប្រធានបទនោះ (៤) កំណត់សុពលភាពនិងភាពជឿជាក់បានក្នុងពេលស្រាវជ្រាវ (៥) ពន្យល់ន័យសេចក្ដីតាមប្រធានបទទាំងនោះ ហើយបង្ហាញលទ្ធផល។

## ៣.៦ សកម្មភាពប្រតិបត្តិ

- ចំណងជើងកិច្ចការនីមួយៗនៃកិច្ចការទាំង៩
- រូបភាព/រូបថតបង្ហាញអំពីលំដាប់លំដោយសកម្មភាពនៃកិច្ចការនីមួយៗ
- ពិពណ៌នាអំពីរូបភាពនីមួយៗ ដោយបញ្ជាក់អំពីគោលបំណង

### ៣.៥.១ សកម្មភាពប្រតិបត្តិទី១ អំពីការអនុវត្តតេស្តស្តង់ដា

| | |
|---|---|
|  សកម្មភាព ........ (កុម្ភៈ ២០២២) | រូបភាពនេះបង្ហាញអំពីសកម្មភាពចូលរួមរបស់សហគមន៍ក្នុងការចូលរួមធ្វើជា .....................។<br><br>គោលបំណងនៃសកម្មភាពនេះគឺ ...... |

| | |
|---|---|
|  | រូបភាពនេះបង្ហាញអំពីសកម្មភាព .......<br>គោលបំណងនៃសកម្មភាពនេះគឺ ...... |
| សកម្មភាព ....<br>( កុម្ភៈ ២០២២ ) | |
| | រូបភាពនេះបង្ហាញអំពីសកម្មភាព .......<br>គោលបំណងនៃសកម្មភាពនេះគឺ ...... |
| | |
| | រូបភាពនេះបង្ហាញអំពីសកម្មភាព .......<br>គោលបំណងនៃសកម្មភាពនេះគឺ ...... |
| | |

### ៣.៥.២ សកម្មភាពប្រតិបត្តិទី២

| | |
|---|---|
|  | រូបភាពនេះបង្ហាញអំពីសកម្មភាពចូលរួមរបស់សហគមន៍ក្នុងការចូលរួមធ្វើជា .....................។<br><br>គោលបំណងនៃសកម្មភាពនេះគឺ ...... |
| សកម្មភាព ........<br>( កុម្ភៈ ២០២២ ) | |

<table>
<tr><td></td><td rowspan="2">រូបភាពនេះបង្ហាញអំពីសកម្មភាព .......<br>គោលបំណងនៃសកម្មភាពនេះគឺ ......</td></tr>
<tr><td>សកម្មភាព ....<br>( កុម្ភៈ ២០២២ )</td></tr>
<tr><td></td><td rowspan="2">រូបភាពនេះបង្ហាញអំពីសកម្មភាព .......<br>គោលបំណងនៃសកម្មភាពនេះគឺ ......</td></tr>
<tr><td></td></tr>
<tr><td></td><td rowspan="2">រូបភាពនេះបង្ហាញអំពីសកម្មភាព .......<br>គោលបំណងនៃសកម្មភាពនេះគឺ ......</td></tr>
<tr><td></td></tr>
</table>

### ៣.៥.២ សកម្មភាពប្រតិបត្តិទី៣

<table>
<tr><td></td><td rowspan="2">រូបភាពនេះបង្ហាញអំពីសកម្មភាពចូលរួមរបស់សហគមន៍ក្នុងការចូលរួមធ្វើជា .....................។<br><br>គោលបំណងនៃសកម្មភាពនេះគឺ ......</td></tr>
<tr><td>សកម្មភាព ........<br>( កុម្ភៈ ២០២២ )</td></tr>
</table>

| | |
|---|---|
|  | រូបភាពនេះបង្ហាញអំពីសកម្មភាព .......<br>គោលបំណងនៃសកម្មភាពនេះគឺ ...... |
| សកម្មភាព ....<br>( កុម្ភៈ ២០២២ ) | |
| | រូបភាពនេះបង្ហាញអំពីសកម្មភាព .......<br>គោលបំណងនៃសកម្មភាពនេះគឺ ...... |
| | |
| | រូបភាពនេះបង្ហាញអំពីសកម្មភាព .......<br>គោលបំណងនៃសកម្មភាពនេះគឺ ...... |
| | |

### ៣.៥.២ សកម្មភាពប្រតិបត្តិទី៤

### ៣.៥.២ សកម្មភាពប្រតិបត្តិទី៥

# ជំពូក ៤
# ផលសម្រេច និងការឆ្លុះបញ្ចាំង

ក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងបង្ហាញលទ្ធផលស្រាវជ្រាវដែលរកឃើញតាមរយៈការស្រាវជ្រាវនេះ និងធ្វើការឆ្លុះបញ្ចាំងលើលទ្ធផលស្រាវជ្រាវនេះ។

## ៤.១ ការបង្ហាញលទ្ធផល

(សរសេរលទ្ធផលស្រាវជ្រាវដោយបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យតាមសំណួរស្រាវជ្រាវនីមួយៗ ដែលអាចមានសេចក្តីពន្យល់ជាពាក្យ/អក្សរ តួលេខ តារាង ក្រាហ្វ ជាដើម។ ក្នុងនោះ អ្នកស្រាវជ្រាវគប្បីបង្ហាញនិងសង្កត់ធ្ងន់លើខ្លឹមសារសំខាន់ ឬចំណុចគួរឱ្យចាប់អារម្មណ៍លើលទ្ធផលស្រាវជ្រាវដែលបានបង្ហាញក្នុងតារាង ឬក្រាហ្វទាំងនោះ។ ជាការប្រសើរ សូមសង្ខេបលទ្ធផលស្រាវជ្រាវឱ្យបានមួយកថាខណ្ឌចុងក្រោយសម្រាប់សំណួរស្រាវជ្រាវនីមួយៗ រួចហើយសូមលុបការណែនាំនេះចេញ)

ការស្រាវជ្រាវនេះបង្ហាញនូវលទ្ធផលអំពីការសិក្សារបស់សិស្ស ការចូលរួមរបស់សហគមន៍ និងផលជះទៅសាលារៀន និងសហគមន៍ផ្សេងទៀត។

### ៤.១.១ ការសិក្សារបស់សិស្ស

ផ្អែកតាមរបាយការណ៍សាលារៀន អត្រាសិស្សចូលរៀនបានបង្ហាញដូចក្រាហ្វ ៤.១។ សិស្សចូលរៀនតាមកម្រិតថ្នាក់នីមួយៗ មានការកើន/អត្រាសិស្សចូលរៀនថ្នាក់ទី៧ នៅឆ្នាំសិក្សា..... មានចំនួនប្រហាក់ប្រហែលនឹង/អត្រាសិស្សចូលរៀនថ្នាក់ទី៨ និងថ្នាក់ទី៩ ដែរ។ វាមានន័យថា ....



*ក្រាហ្វ ៤.១៖ លទ្ធផលសិស្សចូលរៀនក្នុងឆ្នាំសិក្សា ...*

ចំពោះអត្រាសិស្សបោះបង់ការសិក្សាវិញ ក្នុងចំណោមកម្រិតទាំងអស់វាមានច្រើនបំផុតនៅត្រឹមតែ ... % ក្នុងឆ្នាំសិក្សា ..... (ដូចបង្ហាញក្នុងតារាង/ក្រាហ្វ ៤.២)។ នៅថ្នាក់ទី៧ ឡើងថ្នាក់ទី៨ មានអត្រា .....

*តារាង/ក្រាហ្វ ៤.២ លទ្ធផលសិស្សបោះបង់ការសិក្សាក្នុងឆ្នាំសិក្សា*

ផ្អែកលើការធ្វើតេស្ត ការស្រាវជ្រាវនេះបានរកឃើញថា លទ្ធផលសិក្សារបស់សិស្សថ្នាក់ទី ..... បានជាប់មធ្យមភាគមានការកើនឡើងពី .... % ដល់ ....% (ដូចបង្ហាញក្នុងក្រាហ្វ ៤.៣)។ ក្នុងនោះភាគរយសិស្សដែលទទួលបាននិទ្ទេស A B C មាន .... % និងនិទ្ទេស F មាន ... %។ វាមានន័យថា ការសិក្សារបស់សិស្ស .......




*ក្រាហ្វ ៤.៣ លទ្ធផលសិក្សារបស់សិស្សក្នុងឆ្នាំសិក្សា ....*

ផ្អែកលើការសង្កេត ការស្រាវជ្រាវនេះបានរកឃើញថា សិស្សបានបង្ហាញការចូលរួមយ៉ាងសកម្មក្នុងការសិក្សា ដូចបង្ហាញក្នុងរូបភាពខាងក្រោម។ សិស្សអានសៀវភៅក្នុង និងក្រៅថ្នាក់។ (សកម្មភាពសិក្សារបស់សិស្ស ......)

| | |
|---|---|
|  |  |
| សកម្មភាព ............................ (កុម្ភៈ ២០២២) | សកម្មភាព ............................ (កុម្ភៈ ២០២២) |
| | |
| | |
| | |

ជារួម ការសិក្សារបស់សិស្ស .......

### ៤.១.២ ការចូលរួមរបស់សហគមន៍

*ក្រាហ្វ ៤. .... ចំនួនថ្នាក់រៀនមានគណៈកម្មការគ្រប់គ្រងថ្នាក់រៀនក្នុងឆ្នាំសិក្សា ....*

*ក្រាហ្វ ៤. .... ចំនួនសមាសភាពគណៈកម្មការគ្រប់គ្រងសាលារៀនក្នុងឆ្នាំសិក្សា ....*

*ក្រាហ្វ ៤. .... ចំនួនថវិកាសរុបដែលបានពីសហគមន៍ និងប្រភពផ្សេងៗ (គ្រប់ប្រភព និងប្រភេទ)*

តាមរយៈការសង្កេត ការស្រាវជ្រាវនេះបានរកឃើញថា ការចូលរួមរបស់សហគមន៍ ....... ដូចបង្ហាញក្នុងរូបភាពខាងក្រោម។

| | |
|---|---|
|  |  |
| សកម្មភាព ............................. (កុម្ភៈ ២០២២) | សកម្មភាព ............................. (កុម្ភៈ ២០២២) |
| | |
| | |
| | |

ខាងក្រោមនេះគឺពាក្យពេចន៍ដែលបង្ហាញចំណាប់អារម្មណ៍របស់អាព្យាបាលសិស្ស និងសហគមន៍។

“....................................” សំដីរបស់លោក ...............
“....................................” សំដីរបស់លោកស្រី ...............

សរុបសេចក្តីមក ការចូលរួមរបស់សហគមន៍ ......

### ៤.១.៣ ផលជះទៅសាលារៀន និងសហគមន៍ផ្សេងទៀត

តាមរយៈការសម្ភាស និងការសង្កេតផ្ទាល់ សាលារៀនមត្តេយ្យចំនួន .... សាលាបឋមសិក្សាចំនួន .... និង សាលាអនុវិទ្យាល័យ/វិទ្យាល័យចំនួន .... បានទទួលផលជះពីការអនុវត្តការងារគ្រប់គ្រងតាមសាលារៀននៅអនុវិទ្យាល័យ/វិទ្យាល័យ .... (ដូចបង្ហាញក្នុងក្រាហ្វ ៤. .....)

*ក្រាហ្វ ៤. .... ចំនួនសាលារៀន (មត្តេយ្យ បឋម និងមធ្យម) និងកម្រិតផលជះ*

ជាមួយគ្នានេះដែរ ក្នុងនាមជាសាលារៀនក្នុងគោលដៅ/ក្រៅគោលដៅ កិច្ចការសំខាន់ៗដែលអនុវិទ្យាល័យ/វិទ្យាល័យ .... បានជួយដល់ប្រជាជន និងស្ថាប័នពាក់ព័ន្ធក្នុងកម្រិតមូលដ្ឋាន/កម្រិតខេត្ត/និងកម្រិតក្រសួងរួមមាន៖

- សដ
- សដថ

រូបភាពខាងក្រោមបង្ហាញអំពីសកម្មភាពនិងលទ្ធផលដែលជាផលជះនៃការបំពេញការងារគ្រប់គ្រងតាមសាលារៀន។

| | |
|---|---|
|  |  |
| សកម្មភាព ............................ (កុម្ភៈ ២០២២) | សកម្មភាព ............................ (កុម្ភៈ ២០២២) |
| | |
| | |
| | |

និយាយឱ្យខ្លី ផលជះទៅសាលារៀននិងសហគមន៍ផ្សេងទៀតគឺ .....

ជាការសង្ខេប លទ្ធផលនៃការស្រាវជ្រាវនេះបានបង្ហាញថា ......

## ៤.២ ការឆ្លុះបញ្ចាំងលើលទ្ធផល

ដោយពិនិត្យលើលទ្ធផលស្រាវជ្រាវដែលបានរកឃើញខាងលើ ខ្ញុំ/យើងខ្ញុំសូមបង្ហាញចំណាប់អារម្មណ៍ ទស្សនៈផ្ទាល់ខ្លួន និងមេរៀនបទពិសោធដែលមានលក្ខណៈប្រែប្រួលនៅមុនពេល និងនៅពេលអនុវត្តការគ្រប់គ្រងតាមសាលារៀនដូចខាងក្រោម៖

### ៤.២.១ ការសិក្សារបស់សិស្ស

| ការសិក្សារបស់សិស្ស | នៅមុនពេលអនុវត្តការគ្រប់គ្រងតាមសាលារៀន | នៅពេលអនុវត្តការគ្រប់គ្រងតាមសាលារៀន |
|---|---|---|
| សិស្សចូលរៀន | | |
| សិស្សបោះបង់ការសិក្សា | | |
| សិស្សរៀនចេះ | | |
| សកម្មភាពសិក្សារបស់សិស្ស | | |

មេរៀនបទពិសោធ .....
ចំណាប់អារម្មណ៍ ......

### ៤.២.២ ការចូលរួមរបស់សហគមន៍

| ការចូលរួមរបស់សហគមន៍ | នៅមុនពេលអនុវត្តការគ្រប់គ្រងតាមសាលារៀន | នៅពេលអនុវត្តការគ្រប់គ្រងតាមសាលារៀន |
|---|---|---|
| គណៈកម្មការគ្រប់គ្រងថ្នាក់រៀន | | |
| គណៈកម្មការគ្រប់គ្រងសាលារៀន | | |
| ថវិកាពីសហគមន៍ និងប្រភពផ្សេងៗ | | |
| សកម្មភាពចូលរួមរបស់សហគមន៍ | | |

មេរៀនបទពិសោធ .....
ចំណាប់អារម្មណ៍ ......

### ៤.២.៣ ផលជះទៅសាលារៀន និងសហគមន៍ផ្សេងទៀត

| ផលជះទៅសាលារៀន និង សហគមន៍ផ្សេងទៀត | នៅមុនពេលអនុវត្តការគ្រប់គ្រងតាមសាលារៀន | នៅពេលអនុវត្តការគ្រប់គ្រងតាមសាលារៀន |
|---|---|---|
| សាលារៀនផ្សេងទៀត និងកម្រិតផលជះ | | |
| ការជួយដល់ប្រជាជន និងស្ថាប័នពាក់ព័ន្ធ | | |

មេរៀនបទពិសោធ .....
ចំណាប់អារម្មណ៍ ......

ជារួម លទ្ធផលខាងលើបានឆ្លុះបញ្ចាំងឱ្យឃើញថា ....

# ជំពូក ៥
# សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

ជំពូកនេះនឹងសរុបលទ្ធផលស្រាវជ្រាវដោយសង្ខេបដើម្បីធ្វើសេចក្ដីសន្និដ្ឋាន និងផ្ដល់អនុសាសន៍សម្រាប់ជាបទពិសោធនៃការអនុវត្តការងារគ្រប់គ្រងតាមសាលារៀន និងចង្អុលបង្ហាញទិសដៅសម្រាប់កិច្ចការអនុវត្តបន្ត។

## ៥.១ ការកត់សម្គាល់នាពប្រែប្រួល

### *៥.១.១ មុនពេលសិក្សា និងអនុវត្តការគ្រប់គ្រងតាមសាលារៀន*

- ការសិក្សារបស់សិស្ស
- ការចូលរួមរបស់សហគមន៍
- ផលជះទៅសាលារៀន និងសហគមន៍ផ្សេងទៀត
- ដំណើរការសាលារៀន

### *៥.១.២ ពេលសិក្សា និងអនុវត្តការគ្រប់គ្រងតាមសាលារៀន*

- ការសិក្សារបស់សិស្ស
- ការចូលរួមរបស់សហគមន៍
- ផលជះទៅសាលារៀន និងសហគមន៍ផ្សេងទៀត
- ដំណើរការសាលារៀន

## ៥.២ សេចក្ដីសន្និដ្ឋានលើលទ្ធផល

## ៥.៣ អនុសាសន៍សម្រាប់ជាមេរៀនបទពិសោធ

## ៥.៤ កិច្ចការអនុវត្តបន្ត និងការប្ដេជ្ញាចិត្ត

សម្រាប់ឆ្នាំ២០២២ នេះ កិច្ចការបន្តសម្រាប់អនុវត្តនៅសាលារៀននេះ/ទាំងនេះរួមមាន៖

- កក
- កក

ក្នុងនាមខ្ញុំ/យើងខ្ញុំជាអ្នកស្រាវជ្រាវផង និងអនុវត្តផ្ទាល់ផង ខ្ញុំ/យើងខ្ញុំសូមប្ដេជ្ញាចិត្ត......

# ឯកសារយោង

(រៀបចំបញ្ជីឯកសារយោង (សៀវភៅ របាយការណ៍ ....) ឬប្រភពនៃការទទួលទិន្នន័យ (ដូចជាវេបសាយត៍) តាមអក្ខរក្រម។ ឈ្មោះអ្នកនិពន្ធ (ឆ្នាំបោះពុម្ពផ្សាយ) *ចំណងជើងសៀវភៅ/ឯកសារ*។ ទីកន្លែងបោះពុម្ពផ្សាយ៖ គ្រឹះស្ថានបោះពុម្ពផ្សាយ។ រួចហើយសូមលុបការណែនាំនេះចេញ)

ក្រសួងអប់រំ យុវជន និងកីឡា [ក្រសួង អ.យ.ក] (២០១៨) *សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០១៥-២០១៦ និងទិសដៅឆ្នាំសិក្សា២០១៦-២០១៧*។ រាជធានីភ្នំពេញ៖ អ្នកនិពន្ធ។

ក្រសួងអប់រំ យុវជន និងកីឡា [ក្រសួង អ.យ.ក] (២០១៨) *ឯកសារស្តីពីយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨-២០២៣*។ រាជធានីភ្នំពេញ៖ អ្នកនិពន្ធ។ អាចទាញយកតាមតំណ៖ https://www.moeys.gov.kh/index.php/kh/policies-and-strategies/3206.html#.YE3B6igzY2w

ក្រសួងអប់រំ យុវជន និងកីឡា [ក្រសួង អ.យ.ក] (២០១៨) *សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន*។ រាជធានីភ្នំពេញ៖ អ្នកនិពន្ធ។ អាចទាញយកតាមតំណ៖ https://www.moeys.gov.kh/index.php/kh/dge/3487.html#.X34KCpMzYUo

ក្រសួងអប់រំ យុវជន និងកីឡា [ក្រសួង អ.យ.ក] (២០២១) *សេចក្តីណែនាំប្រតិបត្តិយុទ្ធសាស្ត្រសហគមន៍សាលារៀន*។ រាជធានីភ្នំពេញ៖ អ្នកនិពន្ធ។

ក្រសួងអប់រំ យុវជន និងកីឡា [ក្រសួង អ.យ.ក] (២០២១) *យុទ្ធសាស្ត្រអនុវិស័យការអប់រំមធ្យមសិក្សា*។ រាជធានីភ្នំពេញ៖ អ្នកនិពន្ធ។

រាជរដ្ឋាភិបាលកម្ពុជា (២០១៨) *យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤៖ ដើម្បីកំណើន បង្កើតការងារ ជានាសមធម៌ និងប្រសិទ្ធភាព កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០*។ រាជធានីភ្នំពេញ៖ អ្នកនិពន្ធ។ អាចទាញយកតាមតំណ៖ http://www.mcs.gov.kh/?p=14985

រាជរដ្ឋាភិបាលកម្ពុជា (២០១៩) *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣៖ ដើម្បីកំណើន បង្កើតការងារ ជានាសមធម៌ និងប្រសិទ្ធភាពឆ្ពោះទៅកែប្រទេសចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ២០៣០*។ រាជធានីភ្នំពេញ៖ អ្នកនិពន្ធ។ អាចទាញយកតាមតំណ៖ https://www.moeys.gov.kh/index.php/kh/policies-and-strategies/3179.html#.YE2k8vkzbTA

ហង់ជួន ណ.រ (២០១៥) *សេដ្ឋកិច្ចកម្ពុជា៖ មាគ៌ាឆ្ពោះទៅកែអនាគតដ៏ភ្លឺស្វាង វឌ្ឍនភាព បញ្ហាប្រឈម និងទស្សនវិស័យអនាគត*។ រាជធានីភ្នំពេញ៖ អ្នកនិពន្ធ។

# ឧបសម្ព័ន្ធ

(ចូរភ្ជាប់ឯកសារគាំទ្រ និងឯកសារភស្តុតាងផ្សេងៗ រូបភាពពាក់ព័ន្ធ និងឯកសាររដ្ឋបាល ទៅតាមភាពជាក់ស្តែងនៃការស្រាវជ្រាវ រួចហើយសូមលុបការណែនាំនេះចេញ)

ឧបសម្ព័ន្ធទី១៖ (ចំណងជើង) វិញ្ញាសាប្រឡង

ឧបសម្ព័ន្ធទី២៖ (ចំណងជើង)

ឧបសម្ព័ន្ធទី២៖ រូបភាពអំពីសកម្មភាព និងបរិស្ថានសាលារៀន ....

| | |
|---|---|
|  | |
| សកម្មភាពប្រជុំចែករំលែកបទពិសោធរបស់គ្រូបង្រៀន (មករា ២០២២) | សកម្មភាពសិស្សអនុវត្តបំណិនរកចំណូល (វិច្ឆិកា ២០២១) |
| | |
| បរិស្ថានសាលារៀន (មីនា ២០១៨) | បរិស្ថានសាលារៀន (មីនា ២០២១) |
| | |
| | |
| | |
| | |

# ប្រវត្តិរូបសង្ខេប

(សរសេរប្រវត្តិរូបសង្ខេបរបស់អ្នកស្រាវជ្រាវជាកថាខណ្ឌមួយដែលរួមមានសំខាន់ៗមួយចំនួនដូចជា ឈ្មោះ មុខតំណែង/តួនាទី អង្គភាពធ្វើការ ប្រវត្តិការងារ ប្រវត្តិការសិក្សា ជំនាញឯកទេស ស្នាដៃការងារ និងអ៊ីម៉ែល ឬ/និង លេខទូរសព្ទទំនាក់ទំនង) រួចហើយ សូមលុបចោលការណែនាំនេះ។

| | |
|---|---|
| រូបថត<br>Profile | លោក សុខ សុវត្ថិ ជានាយកវិទ្យាល័យ …… ដែលស្ថិតក្នុងស្រុក …. ខេត្ត ….. ។ ចាប់ពីឆ្នាំ … ដល់ ឆ្នាំ …. សុវត្ថិបានបម្រើការជា …… នៅ …….។ ក្រោយមកលោកត្រូវជ្រើសជានាយក …… នៅឆ្នាំ ……..។ លោកបានបញ្ចប់ការសិក្សា …… នៅឆ្នាំ …..។ លោកមានជំនាញឯកទេសលើ ……………………..។ ស្នាដៃការងារចម្បងរបស់លោករួមមាន ……… ។ លោកអាចទាក់ទងបានតាមរយៈអ៊ីម៉ែល ……….. និងលេខទូរសព្ទ ………….<br>ចំណាប់អារម្មណ៍ក្នុងការធ្វើការស្រាវជ្រាវនេះគឺ ............ |
| រូបថត<br>Profile | លោកស្រី ............... ជា.............។<br>........................<br>ចំណាប់អារម្មណ៍ក្នុងការធ្វើការស្រាវជ្រាវនេះគឺ ............ |
| | |
| | |
| | |

**កិច្ចការត្រូវអនុវត្តដើម្បីសម្រេចលទ្ធផលសិក្សារំពឹងទុក៖**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

កិច្ចការទី ១៖ កំណត់បញ្ហានៃការស្រាវជ្រាវប្រតិបត្តិនៅក្នុងថ្នាក់រៀនបាន។

កិច្ចការទី ២៖ រៀបចំប្រមូលទិន្នន័យពាក់ព័ន្ធការស្រាវជ្រាវបានត្រឹមត្រូវ។

កិច្ចការទី ៣៖ វិភាគទិន្នន័យសម្រាប់ឆ្លើយសំណួរស្រាវជ្រាវបាន។

កិច្ចការទី ៤៖ សរសេររបាយការណ៍ស្រាវជ្រាវបានត្រឹមត្រូវ។

កិច្ចការទី ៥៖ ធ្វើបទបង្ហាញនូវអ្វីដែលបានរកឃើញតាមរយៈការស្រាវជ្រាវបាន។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និងកីឡា

# បច្ចេកទេសគន្លឹះ
# នៃការស្រាវជ្រាវប្រតិបត្តិ

ការណែនាំសម្រាប់ស្វ័យស្រាវជ្រាវ

**ឆ្នាំ ២០២០**

ក្រសួងអប់រំ យុវជន និងកីឡា

# បច្ចេកទេសគន្លឹះ
# នៃការស្រាវជ្រាវប្រតិបត្តិ

## ការណែនាំសម្រាប់ស្វ័យស្រាវជ្រាវ

បោះពុម្ពនៅភ្នំពេញ
ក្រសួងអប់រំ យុវជន និងកីឡា
ភ្នំពេញ ប្រទេសកម្ពុជា

ដើម្បីដកស្រង់សៀវភៅនេះ៖ ក្រសួងអប់រំ យុវជន និងកីឡា. (២០២០). បច្ចេកទេសគន្លឹះនៃការស្រាវជ្រាវប្រតិបត្តិ៖ *ការណែនាំសម្រាប់ស្វ័យស្រាវជ្រាវ.* ភ្នំពេញ ប្រទេសកម្ពុជា

# មាតិកា

**មាតិកា** ........ i
**បុព្វកថា** ........ ii
**សេចក្តីផ្តើម** ........ iii
**យល់ដឹងពីការណែនាំសម្រាប់ការធ្វើការស្រាវជ្រាវប្រតិបត្តិដោយខ្លួនឯង** ........ iii
**រចនាសម្ព័ន្ធសៀវភៅ** ........ iii
**គោលបំណង** ........ iv
**ជំពូកទី១ តើអ្វីជាការស្រាវជ្រាវប្រតិបត្តិ?** ........ ១
១.១- និយមន័យ ........ ១
១.២- សមាសធាតុសំខាន់ៗ ........ ១
១.៣- គោលបំណង ........ ២
១.៤- វិសាលភាព ........ ៣
**ជំពូកទី២ វិធីសាស្ត្រនៃការស្រាវជ្រាវប្រតិបត្តិ** ........ ៥
២.១- ការកំណត់បញ្ហា ........ ៥
២.២- ការបង្កើតសំណួរ ........ ៦
២.៣- ការស្វែងរកដៃគូស្រាវជ្រាវ ........ ៧
២.៤- ការប្រមូលទិន្នន័យ ........ ៨
២.៥- ការកត់ត្រាទិន្នន័យ ........ ១៧
២.៦- ការវិភាគទិន្នន័យ ........ ១៩
២.៧- ការឆ្លុះបញ្ចាំងក្នុងដំណើរការស្រាវជ្រាវប្រតិបត្តិ ........ ២២
២.៨- ការដាក់បញ្ចូលគ្នា ការចែករំលែកលទ្ធផលស្រាវជ្រាវ ការផ្តល់អនុសាសន៍ ........ ២៣
**ជំពូកទី៣ ក្រមសីលធម៌ស្រាវជ្រាវ** ........ ២៥
**ជំពូកទី៤ សេចក្តីសន្និដ្ឋាន** ........ ២៩
ឧបសម្ព័ន្ធ ១ ការវិភាគលើការផាត់ចេញពីសង្គម និងយេនឌ័រ (SEGA) ........ ៣១
ឧបសម្ព័ន្ធ ២ គំរូសម្រាប់សរសេររបាយការណ៍ផ្អែកលើការសិក្សាស្រាវជ្រាវប្រតិបត្តិរបស់អ្នក ........ ៣៤
ឧបសម្ព័ន្ធ ៣ សេចក្តីយល់ព្រមចូលរួមក្នុងការស្រាវជ្រាវ ........ ៣៧
ឧបសម្ព័ន្ធ ៤ គំរូថវិកាសម្រាប់ការស្រាវជ្រាវប្រតិបត្តិ ........ ៣៨

# បុព្វកថា

បច្ចេកទេសគន្លឹះនៃការស្រាវជ្រាវប្រតិបត្តិ ជាសៀវភៅណែនាំសម្រាប់បុគ្គលិកអប់រំ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរួមមានៈ មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា រដ្ឋបាល ក្រុង ស្រុក ខណ្ឌ នាយកសាលា គ្រូបង្រៀន សិស្ស និស្សិត ព្រមទាំងអ្នកដែលចាប់អារម្មណ៍ ការស្រាវជ្រាវប្រតិបត្តិ ដែលអាចប្រើប្រាស់សៀវភៅនេះ ដើម្បីពង្រឹងសមត្ថភាពការធ្វើផែនការ ការសម្រេចចិត្ត ការដឹកនាំ ការគ្រប់គ្រង ការអភិវឌ្ឍសមត្ថភាព និងការអភិវឌ្ឍស្ថាប័នដោយផ្អែកលើ ភស្តុតាងសំដៅជំរុញឱ្យមានការប្រែប្រួលតាមបរិបទថ្មី។ សៀវភៅនេះ ត្រូវបានតាក់តែងឡើងសម្រាប់ បុគ្គលិកអប់រំ ព្រមទាំងសម្រាប់អ្នកដែលមានបំណងចង់ដោះស្រាយបញ្ហាសំខាន់ៗ និងចង់ឱ្យមាន ការប្រែប្រួលនិងវឌ្ឍនភាពនៅកន្លែងធ្វើការផងដែរ។ សៀវភៅនេះមានការពន្យល់យ៉ាងសាមញ្ញៗពី វិធីសាស្ត្រប្រមូលទិន្នន័យ ការវិភាគទិន្នន័យ និងការបកស្រាយទិន្នន័យតាមរយៈឧទាហរណ៍ពី បទពិសោធជីវិតពិត និងភាពជាក់ស្ដែង។

ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា ជឿជាក់យ៉ាងមុតមាំថា សៀវភៅនេះនឹងធ្វើឱ្យអ្នក ចាប់អាម្មណ៍ និងចូលចិត្តស្រាវជ្រាវ។ ក្រសួងសូមសម្ដែងការកោតសរសើរ និងអំណរគុណយ៉ាង ជ្រាលជ្រៅចំពោះក្រុមការងារបច្ចេកទេស អ្នកពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍទាំងអស់ ដែលបាន លះបង់ពេលវេលាដ៏មានតម្លៃ កម្លាំងកាយ កម្លាំងចិត្ត កម្លាំងប្រាជ្ញាក្នុងការចងក្រងសៀវភៅនេះឡើង។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា សៀវភៅនេះនឹងក្លាយជាធនធានដ៏មានសារៈសំខាន់ សម្រាប់ បុគ្គលិកអប់រំ នាយកសាលា លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត។ សៀវភៅបច្ចេកទេសគន្លឹះនៃការ ស្រាវជ្រាវប្រតិបត្តិ នឹងជួយលើកទឹកចិត្ត ព្រមទាំងជំរុញឱ្យមានវប្បធម៌ស្រាវជ្រាវ និងចេះប្រើប្រាស់ លទ្ធផលស្រាវជ្រាវធ្វើជាភស្តុតាង ដើម្បីពង្រឹងការអនុវត្តឱ្យមានការប្រែប្រួលវិជ្ជមាន ទាំងកម្រិតបុគ្គល និងស្ថាប័នយ៉ាងពិតប្រាកដ។

ថ្ងៃអង្គារ ៨កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# សេចក្ដីផ្ដើម

## យល់ដឹងពីការណែនាំសម្រាប់ការធ្វើការស្រាវជ្រាវប្រតិបត្តិដោយខ្លួនឯង

តើអ្នកជាសិស្សដែលចង់នាំមកការប្រែប្រួលនិងវឌ្ឍនភាពដល់សាលារបស់អ្នកដែរឬទេ? តើអ្នកគឺជាគ្រូបង្រៀន ដែលចង់កែលម្អការបង្រៀននៅក្នុងថ្នាក់របស់អ្នក ឱ្យកាន់តែប្រសើរឡើង ដែរឬទេ? តើអ្នកគឺជានាយក នាយិកាសាលាដែលចង់ស្វែងរកមូលហេតុដែលនាំឱ្យសិស្សក្នុងសាលារៀនរបស់អ្នកបោះបង់ការសិក្សា និងមិនអាចបញ្ចប់ការសិក្សារបស់ពួកគេ ដែរឬទេ? តើអ្នកជាប្រធានមន្ទីរអប់រំ យុវជន និងកីឡា ហើយអ្នកចង់ប្រមូលនូវភស្តុតាងដែលអាចទុកចិត្តបានដើម្បីគាំទ្រដល់ការសម្រេចចិត្ត ក្នុងការធ្វើផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឬផែនការប្រតិបត្តិប្រចាំឆ្នាំ សម្រាប់អភិវឌ្ឍប្រព័ន្ធអប់រំដែរឬទេ?

ជាទូទៅ យើងតែងតែគិតថា តើធ្វើយ៉ាងណាដើម្បីឱ្យជីវិតការងាររបស់យើងបានប្រសើរឡើង ឬតើយើងគួរផ្លាស់ប្ដូរដោយរបៀបណាក្នុងការកែលម្អសាលារៀនកន្លែងធ្វើការ ឬ អង្គភាពរបស់យើង? ប៉ុន្តែ យើងមិនទាន់ដឹងថាត្រូវធ្វើយ៉ាងណា។ ចម្ងល់ទាំងនេះ ត្រូវបានបំភ្លឺដោយសៀវភៅបច្ចេកទេសគន្លឹះនៃការស្រាវជ្រាវប្រតិបត្តិមួយក្បាលនេះ។ សៀវភៅនេះ ត្រូវបានតាក់តែង សម្រាប់មន្ត្រីនៃមន្ទីរ និងការិយាល័យអយក. នាយក លោកគ្រូ អ្នកគ្រូ ព្រមទាំង សិស្ស និស្សិត និងគរុនិស្សិតដែលមានបំណងចង់ស្វែងរកនូវដំណោះស្រាយបញ្ហា ដែលកើតឡើងក្នុងជីវិតការងារ និងការសិក្សា ដោយនាំយកមកវិញនូវការប្រែប្រួល និងវឌ្ឍនភាពតាមរយៈការស្រាវជ្រាវបែបប្រតិបត្តិ។




### រចនាសម្ព័ន្ធសៀវភៅ

សៀវភៅនេះ ចែកចេញជា ៤ ជំពូក។ ជំពូកទី១ ផ្ដោតលើនិយមន័យនៃការស្រាវជ្រាវប្រតិបត្តិ សមាសធាតុសំខាន់ៗ និងអត្ថន័យរបស់សមាសធាតុសំខាន់ៗ ទាំងនោះ។ ជំពូកទី២ ពន្យល់ពីវិធីសាស្ត្រនៃគម្រោងស្រាវជ្រាវប្រតិបត្តិ ចាប់ពីចំណុចចាប់ផ្ដើមរហូតដល់បញ្ចប់។ ជំពូកនេះ ក៏បានបង្ហាញពីនីតិវិធីការប្រមូលទិន្នន័យ ការថតសារសំឡេង និងការវិភាគទិន្នន័យ និងសារៈសំខាន់នានានៃការឆ្លុះបញ្ចាំងឡើងវិញរបស់ការស្រាវជ្រាវ។ ជំពូកទី៣ ពន្យល់បកស្រាយពីបញ្ហាសំខាន់ៗ នៃចរិយាសម្បទាប្រកបដោយសីលធម៌ក្នុងការស្រាវជ្រាវ (គោលការណ៍ទាំង ៥ នៃក្រមសីលធម៌)។ លើសពីនេះ ជំពូកនេះក៏បានផ្ដោតដល់ការស្រាវជ្រាវជាមួយកុមារ ការការពារសុវត្ថិភាព និងការអនុវត្តការពារចំពោះកុមារគ្រប់កាលៈទេសៈ។ ជំពូកទី៤ ជាការសង្ខេបឡើងវិញនូវអ្វីដែលមាននៅក្នុងសៀវភៅនេះ និងការផ្ដល់ព័ត៌មានបន្ថែមទៀតទាក់ទងនឹងការវិភាគការផាត់

ចេញពីសង្គម និងយេនឌ័រ (SEGA) ព្រមទាំងការភ្ជាប់នូវទម្រង់គំរូផ្សេងៗ ដែលជាព័ត៌មានជំនួយបន្ថែមសម្រាប់ប្រើ ក្នុងអំឡុងពេលធ្វើការស្រាវជ្រាវប្រតិបត្តិ។

## គោលបំណង

សៀវភៅនេះ មានគោលបំណងជួយឱ្យអ្នកយល់ពីដំណើរការស្រាវជ្រាវប្រតិបត្តិ តាមជំហាននីមួយៗ ដើម្បីធ្វើឱ្យអ្នកស្រាវជ្រាវថ្មីមានទំនុកចិត្តក្នុងការធ្វើគម្រោងស្រាវជ្រាវប្រតិបត្តិ។ គោលបំណងមួយទៀត គឺចង្អុលបង្ហាញឱ្យច្បាស់ថា ការធ្វើការស្រាវជ្រាវប្រតិបត្តិនេះ មិនត្រូវបានកំណត់ចំពោះតែអ្នកសិក្សា និងនិស្សិតសាកលវិទ្យាល័យនោះទេ។ សៀវភៅនេះ ត្រូវបានតាក់តែងឡើងដោយវិធីងាយយល់និងងាយប្រើ។ អ្នកនិពន្ធសង្ឃឹមយ៉ាងមុតមាំថា អ្នកអាននឹងយល់ដឹងពីគោលការណ៍ជាមូលដ្ឋាននៃការស្រាវជ្រាវប្រតិបត្តិ។ ឯកសារនេះនឹងផ្តល់ ការណែនាំច្បាស់លាស់ និងជាក់លាក់ជាមួយនឹងឧទាហរណ៍ជាក់ស្តែង ដើម្បីប្រាកដថា អ្នកអាចធ្វើតាមដំណាក់កាលងាយៗក្នុងការស្រាវជ្រាវខ្នាតតូចនិងនាំមកនូវការប្រែប្រួលនិងវឌ្ឍនភាព។ លើសពីនេះ សៀវភៅនេះ នឹងក្លាយជាឯកសារដ៏មានសារៈសំខាន់ក្នុងការពង្រឹងសមត្ថភាពរបស់អ្នកដឹកនាំ និងអ្នកគ្រប់គ្រងអប់រំក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការប្រតិបត្តិប្រចាំឆ្នាំ និងការធ្វើការសម្រេចចិត្តផ្អែកលើភស្តុតាងជាក់ស្តែង។ សៀវភៅនេះមានសារៈសំខាន់ចំពោះមន្ត្រីអប់រំក្នុងការធ្វើផែនការ និងគោលនយោបាយផ្អែកលើភស្តុតាងជាចម្បង។ ការស្រាវជ្រាវបែបប្រតិបត្តិគឺជាវិធីសាស្ត្រដ៏ល្អមួយក្នុងការស្វែងរកភស្តុតាងដែលជំរុញដល់ការលើកកម្ពស់ការចូលរួម ការសហការ និងការចូលរួមបញ្ចេញមតិរបស់សហគមន៍ ដែលជារឿយៗមិនត្រូវបានគេរាប់បញ្ចូលក្នុងការសម្រេចចិត្តនានាកម្រិតថ្នាក់ជាតិ។ ការស្រាវជ្រាវប្រតិបត្តិ នឹងជួយដល់ការអភិវឌ្ឍសមត្ថភាពរបស់អ្នក ឱ្យបានយូរអង្វែងក្នុងការធ្វើការស្រាវជ្រាវគ្រប់ពេលដែលអ្នកត្រូវការនូវភស្តុតាងសម្រាប់ធ្វើគោលនយោបាយ ផែនការ និងការអភិវឌ្ឍសមត្ថភាពស្ថាប័ន។

# ជំពូកទី១

## តើអ្វីជាការស្រាវជ្រាវប្រតិបត្តិ?

### ១.១- និយមន័យ



ការស្រាវជ្រាវប្រតិបត្តិអាចមានអត្ថន័យច្រើនយ៉ាង។ ប៉ុន្តែ ក្នុងសៀវភៅនេះ បានកំណត់និយមន័យថា៖

**ការស្រាវជ្រាវប្រតិបត្តិ** គឺជាការសិក្សាខ្នាតតូចសម្រាប់បុគ្គល ក្រុម ឬ អង្គភាព ដែលចង់ស្វែងរកមូលហេតុជាក់លាក់ឱ្យបានស៊ីជម្រៅពីបញ្ហាដែលកើតមាននៅកន្លែងធ្វើការដើម្បីធ្វើឱ្យមានការប្រែប្រួល និងវឌ្ឍនភាពផ្អែកលើកស្តុតាងនៃការស្រាវជ្រាវ។

### ១.២- សមាសធាតុសំខាន់ៗ

ទោះបីមានការឱ្យនិយមន័យខុសៗគ្នាក៏ដោយ ការស្រាវជ្រាវប្រតិបត្តិមានសមាសធាតុសំខាន់ៗមួយចំនួនដូចជា៖

- វដ្តនៃការស្រាវជ្រាវត្រូវមាន «ការធ្វើផែនការ ការអនុវត្ត និងការឆ្លុះបញ្ចាំងឡើងវិញ» ដែលតែងតែកើតឡើងសារចុះសារឡើងមិនចេះចប់
- មានការផ្តោតលើសកម្មភាពច្បាស់លាស់ ដើម្បីការប្រែប្រួល និងវឌ្ឍនភាព
- ជាការសិក្សាខ្នាតតូច មានលក្ខណៈជាបុគ្គល សេរី និងមានការចូលរួមពីអ្នកពាក់ព័ន្ធ
- មានលក្ខណៈជាប្រព័ន្ធ វិន័យ ក្រមសីលធម៌ និងភាពច្បាស់លាស់
- មានលក្ខខណ្ឌផ្អែកលើស្មារតីស្មោះត្រង់ និងតម្លាភាពចំពោះការឆ្លុះបញ្ចាំងពីខ្លួនឯង
- ដំណើរការស្រាវជ្រាវមានលក្ខណៈមិនចេះចប់ និងមិនមានព្រំដែនច្បាស់លាស់ណាមួយ
- លើកទឹកចិត្តឱ្យមានការបើកចំហ
- លក្ខណៈសហការមានដូចជា ការសន្ទនា និងការធ្វើការជាមួយគ្នាដើម្បីពង្រឹងចំណងទំនាក់ទំនង។



ដំណើរការនៃការស្រាវជ្រាវប្រតិបត្តិ តែងតែមានទម្រង់ច្បាស់លាស់ ដែលផ្តើមដោយការកំណត់បញ្ហាដើម្បីធ្វើស្រាវជ្រាវ (មើលគំនូសតាងទី១)។

**១- ការធ្វើផែនការ៖** កំណត់អ្នកចូលរួម វិធីសាស្ត្រប្រមូលទិន្នន័យ វិសាលភាព និងរយៈពេល។

**២- ការអនុវត្ត និងការសង្កេត៖** ប្រមូលទិន្នន័យតាមរយៈការសម្ភាសជាលក្ខណៈបុគ្គល និងជាក្រុម ដោយការថតសំឡេង និងវិភាគទិន្នន័យ។

**៣- ការឆ្លុះបញ្ចាំងឡើងវិញ៖** តើអ្នកបានស្រាវជ្រាវ ដោយប្រកាន់ភ្ជាប់នូវគោលការណ៍ក្រមសីលធម៌ ប្រកបដោយភាពស្មោះត្រង់និងតម្លាភាព ដែរឬទេ? តើអ្នកមានភស្តុតាងដើម្បីគាំទ្រឱ្យមានការប្រែប្រួល និងវឌ្ឍនភាព ដែរឬទេ? តើអ្នកអាចឆ្លើយសំណួរស្រាវជ្រាវប្រកបដោយប្រសិទ្ធភាព ដែរឬទេ? តើអ្នកត្រូវការស្រាវជ្រាវក្នុងវដ្ត(ជុំ)ផ្សេងទៀត ដែរឬទេ?។




**គំនូសតាងទី១៖** ដំណើរការនៃវដ្តរបស់ការស្រាវជ្រាវប្រតិបត្តិ

## *១.៣- គោលបំណង*

គោលបំណងនៃការធ្វើការស្រាវជ្រាវប្រតិបត្តិគឺធ្វើឱ្យមានភាពស៊ីចង្វាក់គ្នា។ គោលបំណងទាំងនោះគឺដើម្បីកំណត់បញ្ហាដែលកើតឡើងក្នុងជីវិតការងាររបស់បុគ្គល ក្រុម ឬអង្គភាព ហើយជំរុញ និងលើកទឹកចិត្តឱ្យធ្វើការស្រាវជ្រាវប្រកបដោយទំនុកចិត្ត និងប្រមូលរកភស្តុតាងក្នុងការធ្វើការប្រែប្រួល និងវឌ្ឍនភាព។

## ១.៤- *វិសាលភាព*

វិសាលភាពនៃគម្រោងស្រាវជ្រាវប្រតិបត្តិជាមូលដ្ឋាន សំដៅទៅលើប្រធានបទនានា និងការកំណត់ចំនួនអ្នកចូលរួម។ ជាក់ស្តែងវិសាលភាពនៃការស្រាវជ្រាវផ្អែកលើបញ្ហា ដែលអ្នកចង់ធ្វើការសង្កេតនោះ។ ឧទាហរណ៍ លោកគ្រូ អ្នកគ្រូចង់ធ្វើការស្រាវជ្រាវនៅក្នុងថ្នាក់រៀន ដែលគ្រាន់តែតម្រូវឱ្យសិស្ស ២ ឬ ៣ នាក់មកចូលរួម។ ក្នុងករណីបែបនេះ ការស្រាវជ្រាវមានរយៈពេលខ្លីប៉ុណ្ណោះ (៣ ទៅ ៤ សប្តាហ៍) និងត្រូវធ្វើឡើងក្នុងសាលារៀនដែលខ្លួនបង្រៀន។

ក្នុងករណីនាយកសាលាចង់សិក្សាស្វែងរកមូលហេតុ ដែលសិស្សថ្នាក់ទី៦ រៀនខ្សោយខាងអំណាន គាត់អាចនឹងចំណាយពេលវែង ព្រោះគាត់ត្រូវធ្វើការសម្ភាសជាមួយអ្នកចូលរួមច្រើនប្រភេទ ដូចជា គ្រូ សិស្ស និងឪពុកម្តាយជាដើម។ ហេតុនេះ ដំណើរការស្រាវជ្រាវនឹងអាចចំណាយពេលប្រហែល ៦ទៅ៨ សប្តាហ៍ ហើយទីកន្លែងនឹងអាចផ្លាស់ប្តូរគ្រប់ពេល អាស្រ័យលើទីតាំងសាលារៀន និងកន្លែង ដែលឪពុកម្តាយសិស្សជ្រើសរើសធ្វើការណាត់ជួប។

ក្នុងករណី មន្ត្រីមន្ទីរអយក. កំពុងធ្វើការស្រាវជ្រាវពីអត្រាបោះបង់ការសិក្សាឬការផាត់ចេញពីសង្គម នោះការសិក្សាស្រាវជ្រាវ នឹងចំណាយពេលវែង ដោយអ្នកចូលរួមមានច្រើនប្រភេទ ដូចជា នាយកសាលា សិស្ស ឪពុកម្តាយ សមាជិកសហគមន៍...។ល។ ក្នុងករណីនេះ គម្រោងការស្រាវជ្រាវប្រតិបត្តិនឹងមានក្របខណ្ឌពេលវេលាច្បាស់លាស់ ចន្លោះពី ២ទៅ៣ ខែ រីឯទីតាំងនៃការស្រាវជ្រាវនឹងមានវិសាលភាពធំជាងមុន ដោយធ្វើដំណើរតាមស្រុក ឃុំ ភូមិ ដើម្បីសម្ភាសអ្នកចូលរួមក្នុងសាលារៀន និងសហគមន៍។

នាយក នាយិកាសាលា និងមន្ត្រីអប់រំការិយាល័យអយក. មន្ទីរអយក. នឹងត្រូវការភស្តុតាង ពីការសិក្សាស្រាវជ្រាវប្រតិបត្តិ ដើម្បីបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ។ ក្នុងករណីនេះ ពិតជាមានសារៈសំខាន់ណាស់ ក្នុងការរៀបចំគម្រោងស្រាវជ្រាវឱ្យបានទាន់ពេលដែលនាំឱ្យទទួលបានលទ្ធផលស្រាវជ្រាវសម្រាប់បញ្ចូលក្នុងផែនការ។

ការរៀបចំតារាងពេលវេលា របស់គម្រោងស្រាវជ្រាវ គឺជាមធ្យោបាយមួយដែលជួយសម្រួលដល់ការពិនិត្យតាមដានវឌ្ឍនភាពការងារ និងធានាថា ការស្រាវជ្រាវអាចសម្រេចបានលទ្ធផលទាន់ពេលវេលា (មើលតារាងទី១)។

**តារាងទី១៖** គំរូតារាងពេលវេលាសម្រាប់គម្រោងការស្រាវជ្រាវប្រតិបត្តិខ្នាតតូច

| សប្តាហ៍ | កិច្ចការដែលត្រូវបំពេញ |
|---|---|
| សប្តាហ៍ទី ១ | - កំណត់បញ្ហា<br>- បង្កើតសំណួរស្រាវជ្រាវ<br>- កំណត់អ្នកចូលរួមសម្ភាស និងរៀបចំរួចរាល់លិខិតសុំសម្ភាស (សូមពិនិត្យមើលជំពូកទី៣)<br>- ចាប់ផ្តើមអានឯកសារពាក់ព័ន្ធនានា។ |

| | |
|---|---|
| **សប្តាហ៍ទី ២** | - បានសម្រេចចិត្តជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ ដើម្បីប្រមូលទិន្នន័យ និងការសុំថតទុកសារសំឡេង៖ ការធ្វើសម្ភាស (ជាបុគ្គល ឬក្រុម) កិច្ចពិភាក្សាជាក្រុមការរៀបចំកម្រងសំណួរ<br>- កំណត់ពេលវេលា និងទីកន្លែងសម្រាប់ធ្វើការសម្ភាស ឬការពិភាក្សាក្រុម<br>- បង្កើតសំណួរស្រាវជ្រាវតូចៗ សម្រាប់ប្រើប្រាស់ពេលសម្ភាស ឬពេលពិភាក្សាក្រុម (សូមពិនិត្យជំពូកទី២)។ |
| **សប្តាហ៍ទី ៣** | - ចែករំលែកតារាងពេលវេលាជាមួយអ្នកចូលរួមសម្ភាស និងកំណត់ពេលវេលា និងទីកន្លែងណាត់ជួបគ្នា<br>- ចាប់ផ្តើមសម្ភាស កិច្ចពិភាក្សាក្រុម និងស្នើសុំថតទុកសារសំឡេងតាមរយៈឧបករណ៍ថតសំឡេង (សារសំឡេងនឹងត្រូវការសរសេរដាក់ក្រដាសឡើងវិញ) ឬអាចកត់ត្រាចំណុចគន្លឹះៗពេលកំពុងសម្ភាស។ |
| **សប្តាហ៍ទី ៤** | - បញ្ចប់ការសម្ភាស កិច្ចពិភាក្សាក្រុម<br>- ចាប់ផ្តើមសរុប និងការរៀបចំទិន្នន័យឱ្យមានរបៀបរៀបរយ<br>- ចាប់ផ្តើមវិភាគ និងពិនិត្យមើលថាតើមានខ្លឹមសារសំខាន់ៗណាខ្លះដែលបានរំលេចឡើងក្នុងទិន្នន័យ។ |
| **សប្តាហ៍ទី ៥** | - ផ្តោតលើការវិភាគ៖ អានហើយ អានទៀតលើទិន្នន័យដើម្បីស្វែងរកនូវខ្លឹមសារសំខាន់ៗ និងចាត់ចំណាត់ថ្នាក់ទិន្នន័យ<br>- សួរខ្លួនឯង «តើទិន្នន័យចង់ប្រាប់ខ្ញុំអំពីអ្វី?»<br>- ថាតើសំណួរស្រាវជ្រាវរបស់អ្នកត្រូវបានឆ្លើយហើយឬនៅ? ទាញការសំយោគសេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍<br>- ពិចារណាថាតើអ្នកនឹងត្រូវចែករំលែកលទ្ធផលស្រាវជ្រាវតាមរបៀបណា ដើម្បីនាំទៅរកការប្រែប្រួល និងវឌ្ឍនភាព?។ |
| **សប្តាហ៍ទី ៦** | - សម្រាប់អ្នក ដែលត្រូវការបញ្ចូលលទ្ធផលស្រាវជ្រាវ ទៅក្នុងផែនការយុទ្ធសាស្ត្រ ឬ ផែនការប្រតិបត្តិប្រចាំឆ្នាំ ត្រូវឱ្យប្រាកដថា ការវិភាគទិន្នន័យ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ត្រូវបានបញ្ចប់រួចរាល់ជាស្ថាពរ មុនពេលផែនការទាំងនោះបានបញ្ជូនមកថ្នាក់ដឹកនាំ។ តើពេលវេលាផុតកំណត់របស់អ្នកនៅពេលណា?។ |

# ជំពូកទី២

## វិធីសាស្ត្រនៃការស្រាវជ្រាវប្រតិបត្តិ

### ២.១- ការកំណត់បញ្ហា

ការស្រាវជ្រាវប្រតិបត្តិ ចាប់ផ្តើមពីការកំណត់បញ្ហាដែលអ្នកចង់ដោះស្រាយ ឬ ចង់ធ្វើការកែលម្អឱ្យកាន់តែប្រសើរឡើងក្នុងស្ថានភាពណាមួយ។ ចំពោះការកំណត់បញ្ហាគឺអាស្រ័យលើអ្នកស្រាវជ្រាវ។ ឧទាហរណ៍ គ្រូបង្រៀនម្នាក់ចង់កំណត់បញ្ហា ក្នុងការរៀនសូត្ររបស់សិស្សក្នុងថ្នាក់។ នាយកសាលាចង់ធ្វើការកែលម្អគុណភាព នៃការប្រជុំបច្ចេកទេសនៅក្នុងសាលារៀន។ រដ្ឋបាលថ្នាក់ក្រោមជាតិចង់កំណត់នូវមធ្យោបាយបង្កើនការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតមត្តេយ្យសិក្សាក្នុងសហគមន៍។ ជាធម្មតា មានបញ្ហាច្រើនដែលបានកើតឡើង។ ដូចនេះ ប្រហែលជាមានការលំបាកក្នុងការជ្រើសរើសយកបញ្ហាតែមួយយកមកធ្វើការសិក្សា។ ក្នុងករណីនេះ បើអ្នកត្រូវការជំនួយក្នុងការកំណត់បញ្ហាអាទិភាពអាចអនុវត្តតាមជំហានខាងក្រោម៖



① **បំផុសបញ្ហាជាមួយក្រុមការងារ**
ពិភាក្សាពីបញ្ហាជាមួយសហការីរបស់អ្នក

② **ធ្វើការបោះឆ្នោតដើម្បីជ្រើសរើសយកបញ្ហាអាទិភាព**
ត្រូវមានភាពប្រជាធិបតេយ្យ និងស្មើភាព ឱ្យឱកាសអ្នកទាំងអស់គ្នាបញ្ចេញមតិ

③ **ធ្វើការសម្រេចចិត្តចុងក្រោយពីបញ្ហាអាទិភាពណាដែលគួរសិក្សា**
រើសយកបញ្ហាអាទិភាព និងចាំបាច់ជាងគេ

### *កំណត់សម្គាល់៖ ការវិភាគលើការផាត់ចេញពីសង្គម និងយេនឌ័រ*

**ការវិភាគលើការផាត់ចេញពីសង្គម និងយេនឌ័រ(SEGA)** គឺជាផ្នែកមួយនៃការស្រាវជ្រាវប្រតិបត្តិ ដែលផ្តោតលើអ្នកដែលត្រូវបានគេមិនរាប់បញ្ចូលដូចជា៖ ជនជាតិភាគតិច កុមារដែលមានពិការភាព ជនជាតិដើមភាគតិច អ្នកស្រឡាញ់ភេទដូចគ្នា អ្នកផ្ទុកមេរោគអេដស៍...។ល។ ក្នុងករណីទាំងនេះ អ្នកនឹងផ្តោតលើសំណួរនៃការស្រាវជ្រាវប្រតិបត្តិជាក់លាក់មួយ(សូមមើលឧបសម្ព័ន្ធទី១)។



## ២.២- *ការបង្កើតសំណួរ*



បន្ទាប់ពីកំណត់បញ្ហាស្រាវជ្រាវរួច អ្នកអាចចាប់ផ្តើមបង្កើតសំណួរ។ សំណួរទាំងនេះត្រូវបានបង្កើតឡើង ដើម្បីបញ្ជាក់ពីបញ្ហា និងជាមូលដ្ឋានសម្រាប់ការស្រាវជ្រាវ។ សំណួរស្រាវជ្រាវដែលល្អគឺច្បាស់លាស់ ហើយផ្តោតទៅលើចំណុចតូចៗ និងជាក់លាក់។ សំណួរស្រាវជ្រាវល្អ គួរតែចាប់ផ្តើមដោយពាក្យ៖ **«តើ...ដោយ របៀបណា ឬយ៉ាងដូចម្តេច»** និងបន្ថែមឃ្លានៃការប្រែប្រួល និងវឌ្ឍនភាពណាមួយដែលអ្នកកំពុងស្វែងរក។ ឧទាហរណ៍៖ *«តើយើងអាចលើកទឹកចិត្តសិស្សឱ្យបន្តការសិក្សាបន្ទាប់ពីបញ្ចប់ថ្នាក់ទី ៦ ដោយរបៀបណា ?»* សំណួរចាប់ផ្តើមដោយ «តើ..... ដោយរបៀបណា ឬយ៉ាងដូចម្តេច» និងផ្តោតលើការបន្តការសិក្សារបស់សិស្សដែលជាការប្រែប្រួលជាវិជ្ជមានដែលអ្នកចង់បាន។ សំណួរគួរសួរឱ្យមានលក្ខណៈសមស្រប។ ឧទាហរណ៍៖ សំណួរសួរថា *«ហេតុអ្វីមិត្តរបស់ខ្ញុំខ្ជិលរៀនម្លេះ ?»* នឹងមិនលើកទឹកចិត្តឱ្យមានការសហការ និងការចូលរួមទេ ហើយបណ្តាលឱ្យគម្រោងស្រាវជ្រាវមិនល្អ។ ម៉្យាងវិញទៀត សំណួរដូចជា *«តើខ្ញុំអាចជួយមិត្តរបស់ខ្ញុំ កែលម្អការសិក្សាយ៉ាងដូចម្តេច ?»* មានលក្ខណៈវិជ្ជមាន និងផ្តល់ការណែនាំច្បាស់លាស់សម្រាប់ការស្រាវជ្រាវ។ តារាង ២ នឹងបង្ហាញពីសំណួរស្រាវជ្រាវច្បាស់លាស់ និងសំណួរស្រាវជ្រាវមិនច្បាស់លាស់៖

**តារាង ២៖** សំណួរស្រាវជ្រាវច្បាស់លាស់ និងសំណួរស្រាវជ្រាវមិនច្បាស់លាស់

| បញ្ហា | ឧទាហរណ៍ សំណួរស្រាវជ្រាវមិនច្បាស់លាស់ | ឧទាហរណ៍ សំណួរស្រាវជ្រាវច្បាស់លាស់ |
|---|---|---|
| កិច្ចតែងការបង្រៀនគណិតវិទ្យាថ្នាក់ទី៣របស់គ្រូពុំល្អនាំឱ្យការរៀនរបស់សិស្សពុំមានប្រសិទ្ធភាព ។ | តើខ្ញុំអាចក្លាយជាគ្រូគណិតវិទ្យាដ៏ល្អដោយរបៀបណា ? | តើខ្ញុំអាច កែលម្អកិច្ចតែងការគណិតវិទ្យាដើម្បីឱ្យសិស្សថ្នាក់ទី៣របស់ខ្ញុំអាចអភិវឌ្ឍការយល់ដឹងល្អនិងចងចាំ រយៈពេលវែងដោយរបៀបណា ? |
| សិស្សថ្នាក់ទី ៩ ម្នាក់មានអំណានខ្សោយភាសាខ្មែរ។ | តើខ្ញុំអាចក្លាយជាអ្នកអានដ៏ល្អដោយរបៀបណា ? | តើខ្ញុំអាចកំណត់កត្តាដែលជះឥទ្ធិពលអំណានភាសាខ្មែរ បានស្ទាត់ជំនាញដោយរបៀបណា ? |
| ការសហការគ្នា ក្នុងការអភិវឌ្ឍសាលារៀនរបស់នាយកសាលា | តើខ្ញុំអាចក្លាយជានាយកសាលាដ៏ល្អម្នាក់ដោយរបៀបណា ? | តើយើងអាចបង្កើនការគាំទ្រ និងការសហការគ្នារវាងគ្រូ បុគ្គលិក និង |

| | | |
|---|---|---|
| គ្រូ បុគ្គលិក និងសហគមន៍មិនសូវសកម្ម។ | | សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀនបានដោយរបៀបណា ? |
| ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំនៅកម្រិតការិយាល័យអយក. មិនទាន់បានល្អប្រសើរ។ | តើខ្ញុំរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំដ៏ល្អមួយដោយរបៀបណា ? | តើខ្ញុំអាចបង្កើនការចូលរួម និងគណនេយ្យភាពក្នុងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំសម្រាប់ការិយាល័យអយក. ដោយរបៀបណា ? |

## ២.៣- *ការស្វែងរកដៃគូស្រាវជ្រាវ*



ក្នុងការស្រាវជ្រាវប្រតិបត្តិ អ្នកចូលរួមទាំងអស់ធ្វើការជាមួយគ្នា ដើម្បីចែករំលែកចំណេះដឹង។ អ្នកដឹកនាំស្រាវជ្រាវ (ឬអ្នកដឹកនាំ) គឺជាអ្នកដើរតួយ៉ាងសំខាន់ក្នុងការបង្កើតសំណួរគន្លឹះ ដែលជួយសម្រួលដល់ដំណើរការស្រាវជ្រាវ និងទទួលខុសត្រូវក្នុងការរៀបចំ របាយការណ៍ បទបង្ហាញ ឬចែករំលែកលទ្ធផលនៃគម្រោងស្រាវជ្រាវ។

អ្នកចូលរួមក្នុងការស្រាវជ្រាវ គឺជាអ្នកដែលចាប់អារម្មណ៍លើបញ្ហា ដែលកំពុងស្រាវជ្រាវអ្នកដែលរងផលប៉ះពាល់ពីបញ្ហានេះ និងអ្នកដែលមានចំណេះដឹងពីបញ្ហានោះ។ ឧទាហរណ៍៖ សិស្ស គ្រូបង្រៀន ឪពុកម្ដាយ គណៈកម្មការគ្រប់គ្រងសាលារៀន មន្ត្រីអប់រំ...។ល។ អ្នកចូលរួមស្រាវជ្រាវដ៏ល្អ គឺជាអ្នកដែលបានប្ដេជ្ញាចិត្តចំពោះគម្រោងស្រាវជ្រាវ និងចាប់អារម្មណ៍ខ្លាំងក្នុងការជួយអ្នកដឹកនាំស្រាវជ្រាវដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ ក្នុងការប្រែប្រួលជាវិជ្ជមាន។

ចំនួនអ្នកចូលរួមក្នុងគម្រោងស្រាវជ្រាវគឺអាស្រ័យលើវិសាលភាពនៃការសិក្សាស្រាវជ្រាវ។ ជាទូទៅ អ្នកដឹកនាំការស្រាវជ្រាវ អាចជ្រើសរើសអ្នកចូលរួមពី ៣ ទៅ ១០នាក់ ដើម្បីជួយក្នុងគម្រោងស្រាវជ្រាវ។ អ្នកដឹកនាំ ក៏អាចកំណត់តួនាទីជាក់លាក់របស់អ្នកចូលរួមតាមការចាំបាច់ ដូចជា ជួយសម្ភាស កត់ត្រាបទសម្ភាស កំណត់ចំណុចសំខាន់ៗ នៅក្នុងការពិភាក្សាក្រុមរៀបចំបទបង្ហាញពីលទ្ធផលស្រាវជ្រាវ។ ប្រសិន បើគ្រូម្នាក់ធ្វើគម្រោងស្រាវជ្រាវប្រតិបត្តិផ្ទាល់ខ្លួន ដើម្បីកែលម្អការអនុវត្តរបស់គាត់នៅក្នុងថ្នាក់រៀន គាត់អាចគ្រាន់តែធ្វើការជាមួយមិត្តរួមការងារម្នាក់ និងឬ និស្សិតមួយចំនួន ដើម្បីជួយឆ្លើយសំណួរស្រាវជ្រាវ។ ម៉្យាងទៀត មន្ត្រីអប់រំដែលធ្វើការសិក្សាទ្រង់ទ្រាយធំ ក៏អាចជ្រើសរើសអ្នកតំណាងមកពីការិយាល័យនៅថ្នាក់ក្រោមជាតិ ផ្សេងៗគ្នាក្នុងករណីដែលត្រូវការចំនួនអ្នកចូលរួមច្រើន។

## ២.៤- ការប្រមូលទិន្នន័យ

ទិន្នន័យ មិនគ្រាន់តែជាការពិត និងតួលេខប៉ុណ្ណោះទេ តែទិន្នន័យអាចមានទម្រង់ផ្សេងៗ គ្នាជាច្រើន។ រាល់ទម្រង់ទិន្នន័យទាំងអស់ អាចប្រមូលបានតាមវិធីផ្សេងៗគ្នា ប៉ុន្តែ វិធីខាងក្រោមនេះ ត្រូវបានគេប្រើញឹកញាប់បំផុត៖




### ក. ការសម្ភាស

ការសម្ភាសមានភាពងាយស្រួល ដោយគ្រាន់តែនិយាយទៅកាន់អ្នកចូលរួម។ ការសម្ភាសអាចមួយទល់មួយដៃគូ ឬ ជាក្រុម ដែលអ្នកសម្ភាសមនុស្សជាច្រើនក្នុងពេលតែមួយ។ ដើម្បីប្រមូលទិន្នន័យប្រកបដោយប្រសិទ្ធភាព អ្នកស្រាវជ្រាវត្រូវបង្កើតសំណួរសម្រាប់សម្ភាស ឬ សំណួរគន្លឹះជាមុនដែលលើកទឹកចិត្តអ្នកចូលរួម ឱ្យផ្តល់ព័ត៌មានបានពេញលេញ និងគ្រប់ជ្រុងជ្រោយ។ សំណួរបើកគឺជាសំណួរដែលមិនមានចម្លើយ បាទ ចាស ឬទេ ហើយត្រូវបានប្រើ ដើម្បីឱ្យអ្នកចូលរួមផ្តល់គំនិត និងយោបល់ដោយសេរី។ អ្នកត្រូវគិតគូរដោយប្រុងប្រយ័ត្នក្នុងការបង្កើតសំណួរសម្ភាស ព្រោះសំណួរសម្ភាសនឹងគាំទ្រដល់សំណួរស្រាវជ្រាវ (តារាង ៣.ក និង៣.ខ)។



**តារាង ៣.ក៖** សំណួរគន្លឹះគាំទ្រដល់សំណួរស្រាវជ្រាវសម្រាប់នាយកសាលា ឬ ការិយាល័យអយក.

| សំណួរស្រាវជ្រាវ | អ្នកចូលរួម | សំណួរគន្លឹះសម្រាប់ការសម្ភាស |
|---|---|---|
| តើយើងអាចលើកទឹកចិត្តសិស្សឱ្យបន្តការសិក្សាបន្ទាប់ពីបញ្ចប់ថ្នាក់ទី ៦ ដោយរបៀបណា? | សិស្ស | ១- តើអ្នកអាចប្រាប់ពីការរៀនសូត្ររបស់អ្នកបាន ដែរឬទេ? |
| | | ២- មូលហេតុអ្វីធ្វើឱ្យអ្នកចង់មកសាលារៀន? |
| | | ៣- តើនៅសាលារៀនមានអ្វីដែលអ្នកមិនចូលចិត្ត ដែរឬទេ? |
| | | ៤- តើមុខវិជ្ជាណាដែលអ្នកពិបាករៀន? ហេតុអ្វី? |

| | | |
|---|---|---|
| | | ៥- តើពេលរៀនចប់ អ្នកចង់ធ្វើការងារអ្វី? |
| | | ៦- តើសាលារៀនរបស់អ្នកគួរតែកែលម្អចំណុចណាខ្លះ? |
| | ឪពុកម្ដាយ | ៧- តើអ្នកយល់យ៉ាងណាចំពោះការសិក្សារបស់កូន? |
| | | ៨- តើអ្នកជឿថា ការអប់រំមានសារៈសំខាន់សម្រាប់កូនដែរឬទេ? |
| | | ៩- តើអ្នកយល់ថា ការឱ្យកូនបានរៀនបញ្ចប់កម្រិតមូលដ្ឋាន (៩ឆ្នាំ) មានសារៈសំខាន់បែបណា? |
| | | ១០- តើសាលារៀនកូនរបស់អ្នកគួរតែកែលម្អចំណុចណាខ្លះ? |
| | | ១១- តើអ្នកចង់ឃើញកូនរបស់អ្នកមានការងារល្អនាពេលអនាគត ដែរឬទេ? |

**តារាង ៣.ខ៖** សំណួរគន្លឹះគាំទ្រដល់សំណួរស្រាវជ្រាវសម្រាប់មន្ទីរអេយក.

| សំណួរស្រាវជ្រាវ | អ្នកចូលរួម | សំណួរគន្លឹះសម្រាប់ការសម្ភាស |
|---|---|---|
| តើយើងអាចប្រើថវិការបស់ការិយាល័យអធិការកិច្ចនៃមន្ទីរអេយក. ឱ្យមានប្រសិទ្ធភាពដោយរបៀបណាក្នុងការត្រួតពិនិត្យសាលារៀននៅពេលដែលថវិកាត្រូវបានកាត់បន្ថយ | មន្ត្រីអធិការកិច្ច | ១- តើអ្នកទទួលខុសត្រូវលើសាលារៀនចំនួនប៉ុន្មាន? |
| | | ២- តើអ្នកមានសិទ្ធិជ្រើសរើសសាលារៀនណាខ្លះ និងចំនួនប៉ុន្មានដើម្បីចុះអធិការកិច្ច? |
| | | ៣- តើអ្នកបានសាកល្បងចុះអធិការកិច្ចសាលារៀនទាំងអស់គ្រប់ពេល ដែរឬទេ? |
| | | ៤- តើអ្នកចុះអធិការកិច្ចសាលាជាក្រុម ដែរឬទេ? |
| | | ៥- តើសាលារៀនដែលអ្នកបានចុះ អធិការកិច្ចអនុវត្តបានល្អដែរឬទេ? |

| | | |
|---|---|---|
| ២៥% ក្នុងឆ្នាំ ២០២០? | | ៦- តើអ្នកបាន ធ្វើអធិការកិច្ចពិនិត្យតាមដានសាលារៀន ដែលអនុវត្តមិនសូវល្អ ដែរឬទេ? |
| | | ៧- តើអ្នកបានធ្វើអធិការកិច្ចសាលារៀនដែលអនុវត្តបានល្អប្រសើ ដែរឬទេ? |
| | | ៨- តើអ្នកគិតថាមានសារៈសំខាន់ឬទេក្នុងការចុះអធិការកិច្ចសាលារៀនដែលអនុវត្តមិនសូវល្អជាប្រចាំ? |
| | | ៩- តើអ្នកបានធ្វើអាទិភាពសាលារៀនដែលបានចុះអធិការកិច្ច ដែរឬទេ? |
| | នាយកសាលា គ្រូបង្រៀន | ១០- តើអ្នកបានផ្តល់ដំណឹងដល់សាលារៀន ដែរឬទេ មុនពេលចុះអធិការកិច្ច? |
| | | ១១- តើអ្នកគិតថាការចុះ អធិការកិច្ចជាប្រចាំមានផលវិជ្ជមានទៅលើដំណើរការសាលារៀន និងការបង្រៀន និងរៀន ដែឬទេ? |
| | | ១២- តើអ្នកគិតថាការចុះពិនិត្យតាមដាន ឬអធិការកិច្ចជាប្រចាំមានផលអវិជ្ជមាន ទៅលើដំណើរការសាលារៀន និងការបង្រៀន និងរៀន ដែឬទេ? |
| | | ១៣- តើលោកគ្រូ អ្នកគ្រូគិតយ៉ាងដូចម្តេចចំពោះការចុះអធិការកិច្ច? |
| | | ១៤- តើអ្នកគិតថាការចុះធ្វើអធិការកិច្ចធ្វើឱ្យសមត្ថភាពគ្រូមានការកើនឡើង ដែរឬទេ? |
| | | ១៥- តើការចុះអធិការកិច្ចរំខានដល់ការងារប្រចាំថ្ងៃរបស់អ្នក ដែរឬទេ? |

| | | |
|---|---|---|
| | | ១៦- តើអ្នកធ្លាប់សហការជាមួយសាលារៀនដទៃដើម្បីបង្កើនប្រសិទ្ធភាពគ្រប់គ្រងសាលារៀន ដែរឬទេ? |

សំណួរសម្ភាស គួរមានលក្ខណៈអព្យាក្រឹតជានិច្ច ដែលនាំឱ្យអ្នកស្រាវជ្រាវអាចចៀសវាងសួរសំណួរគន្លឹះ ដែលអាចជះឥទ្ធិពលលើអ្នកចូលរួម។ អ្នកស្រាវជ្រាវត្រូវការប្រមូលទិន្នន័យ ដែលមានលក្ខណៈដូចជាសំឡេងពិតៗ មតិត្រង់របស់អ្នកចូលរួមជាជាងការឆ្លើយតបដែលផ្តល់ឱ្យដោយតែងតែយល់ស្របជាមួយអ្នកស្រាវជ្រាវ។

ប្រសិនបើអ្នកចូលរួមសម្ភាសស្ថិតនៅតំបន់ដាច់ស្រយាល ហើយពិបាករៀបចំធ្វើការសម្ភាសផ្ទាល់មាត់ ការសម្ភាសតាមទូរស័ព្ទគឺជាជម្រើសមួយដ៏ល្អ។ ការសម្ភាស ក៏អាចធ្វើតាមបណ្តាញទំនាក់ទំនង Zoom, Google Meet និង Skype ប្រសិនបើ ទីនោះមានបណ្តាញអ៊ីនធើណិតទៅដល់។

## ខ. ការពិភាក្សាក្រុម



ការពិភាក្សាក្រុម គឺស្រដៀងគ្នាទៅនឹងការសន្ទនាក្រុម ដែលអ្នកស្រាវជ្រាវសួរសំណួរជំរុញឱ្យអ្នកចូលរួមមាន មតិ យោបល់ និងគំនិត។ ដោយឡែក ការពិភាក្សា ក្រុមត្រូវផ្តោតលើប្រធានបទដែលកំពុងពិភាក្សា។ អ្នកដឹកនាំការស្រាវជ្រាវអាចធានាបានថា ការពិភាក្សាអំពីបញ្ហាគឺឆ្លើយតបទៅនឹងសំណួរគន្លឹះ។ ការពិភាក្សាជាក្រុមខុសគ្នាពីការសម្ភាសជាក្រុម ព្រោះវាមានលក្ខណៈមិនសូវផ្លូវការ និងសំណួរខ្លះមានលក្ខណៈទូលំទូលាយ។

គោលការណ៍ណែនាំការពិភាក្សាជាក្រុម៖ អ្នកដឹកនាំការស្រាវជ្រាវ អញ្ជើញអ្នកចូលរួមដើម្បីពិភាក្សាជាក្រុម តាមកាលបរិច្ឆេទ និងទីកន្លែងដែលបានព្រមព្រៀងគ្នាទុក។ ការពិភាក្សាក្រុមមានសារៈសំខាន់ណាស់ ដែលមានតំណាងក្រុមរងផលប៉ះពាល់ពីបញ្ហាដែលកំពុងស្រាវជ្រាវ (តារាង ៤.ក និង៤.ខ)។

ការពិភាក្សាជាក្រុម ចាប់ផ្តើមដោយអ្នកដឹកនាំការស្រាវជ្រាវបង្ហាញពីវត្ថុបំណងនៃការពិភាក្សា និងប្រាប់អ្នកចូលរួមថាអាចបញ្ចេញមតិ និងផ្តល់យោបល់ដោយសេរី។ បន្ទាប់មក អ្នកដឹកនាំការស្រាវជ្រាវចាប់ផ្តើមសួរសំណួរ (មាន ៥ ទៅ ៦ សំណួរ គួររៀបចំក្នុងផ្នែកមួយនៃផែនការស្រាវជ្រាវ និងពេលវេលាគ្រប់គ្រាន់ ដើម្បីពិភាក្សាឱ្យបានផុសផុល)។

**តារាង ៤.ក៖** ឧទាហរណ៍នៃសំណួរពិភាក្សាជាក្រុមនៅកម្រិតសាលារៀន

| សំណួរស្រាវជ្រាវ | អ្នកចូលរួម | ឧទាហរណ៍នៃសំណួរ សម្រាប់ពិភាក្សាជាក្រុម |
|---|---|---|
| តើឪពុកម្ដាយត្រូវបានលើកទឹកចិត្តឱ្យនាំកូនចុះឈ្មោះចូលរៀននៅសាលាមត្តេយ្យសិក្សាសហគមន៍ដោយរបៀបណា? | ○ សមាជិកសហគមន៍<br>○ ឪពុកម្ដាយ<br>○ គ្រូមត្តេយ្យសិក្សា<br>○ គ្រូបឋមសិក្សា<br>○ នាយកសាលា | ១- តើអ្នកយល់យ៉ាងណាចំពោះកុមារដែលចាប់ផ្ដើមចូលរៀននៅសាលាមត្តេយ្យសិក្សាសហគមន៍ចាប់ពីអាយុ ៣ ឬ ៤ ឆ្នាំ? |
| | | ២- តើអ្នកដឹងទេថា កុមារធ្វើអ្វីខ្លះ នៅពេលពួកគេទៅរៀននៅសាលាមត្តេយ្យសិក្សាសហគមន៍? |
| | | ៣- តើអ្នកគិតថាគ្រូដែលបង្រៀនកុមារត្រូវមានចំណេះដឹងកម្រិតណា? |
| | | ៤- តើអ្នកគិតថា ហេតុអ្វីបានជាឪពុកម្ដាយមួយចំនួនមិនចង់ឱ្យកូនទៅរៀននៅសាលាមត្តេយ្យសិក្សាសហគមន៍? |
| | | ៥- តើមានអត្ថប្រយោជន៍អ្វីខ្លះ ដែលកុមារអាចទទួល បានពីការចូលរៀននៅសាលាមត្តេយ្យសិក្សាសហគមន៍ក្នុងរយៈពេលវែង? |

**តារាង ៤.ខ៖** ឧទាហរណ៍នៃសំណួរពិភាក្សាជាក្រុមនៅកម្រិតមន្ទីរអេយក.

| សំណួរស្រាវជ្រាវ | អ្នកចូលរួម | ឧទាហរណ៍នៃសំណួរសម្រាប់ពិភាក្សាជាក្រុម |
|---|---|---|
| តើការចូលរួមនិងគណនេយ្យភាពក្នុងការអភិវឌ្ឍផែនការប្រតិបត្តិប្រចាំឆ្នាំធ្វើឱ្យប្រសើរឡើងដោយរបៀបណា? | អ្នកតំណាងឱ្យការិយាល័យជំនាញនៅមន្ទីរអេយក.<br>- អប់រំកុមារតូច<br>- បឋមសិក្សា<br>- មធ្យមសិក្សា<br>- អប់រំក្រៅប្រព័ន្ធ<br>- ផែនការ...។ល។ | ១- តើអ្នកយល់ថា បច្ចុប្បន្នអ្នកបានចូលរួមធ្វើការសម្រេចចិត្តនៅកម្រិតមន្ទីរអេយក. ដែរឬទេ? |
| | | ២- តើអ្នកយល់ថា បច្ចុប្បន្នអ្នកបានផ្ដល់មតិយោបល់ក្នុងការិយាល័យរបស់អ្នកដែរឬទេ? |
| | | ៣- តើអ្នកធ្លាប់សហការជាមួយការិយាល័យនានាតាមមធ្យោបាយផ្សេងៗ ដែរឬទេ? |
| | | ៤- តើបច្ចុប្បន្ននេះ អ្នកបានចូលរួមរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ដោយមធ្យោបាយណាមួយ? |

| | | |
|---|---|---|
| | | ៥- តើអ្នកគិតថា ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ជាការទទួលខុសត្រូវរបស់អ្នកណា ? |
| | | ៦- តើអ្នកយល់ថា កិច្ចសហការគ្នារបស់អនុវិស័យ អាចជំរុញគុណភាពនៃផែនការប្រតិបត្តិប្រចាំឆ្នាំ ដែរឬទេ ? |

សំណួរទាំងនេះ ត្រូវបានរៀបចំឡើងដើម្បីជំរុញសកម្មភាពការពិភាក្សាក្រុម ក្នុងការប្រមូលគំនិត និងមតិយោបល់របស់អ្នកចូលរួម។ ទោះយ៉ាងណា អ្នកស្រាវជ្រាវត្រូវជានាថា សំណួរគន្លឹះមានលក្ខណៈអព្យាក្រឹត ហើយមិនមានឥទ្ធិពលលើអ្នកចូលរួម។ អ្នកដឹកនាំការស្រាវជ្រាវ (ឬអ្នកចូលរួមការស្រាវជ្រាវ) អាចធ្វើការកំណត់ចំណាំនូវចំណុចចម្បងនៃការពិភាក្សា និងចែករំលែកជាមួយអ្នកចូលរួមដទៃទៀត ដើម្បីធ្វើឱ្យប្រាកដថាពួកគាត់យល់ពីចំណុចសំខាន់ៗនៃការពិភាក្សា។ ការកត់ត្រាទាំងនេះ ក្លាយជាផ្នែកមួយនៃការប្រមូលទិន្នន័យរបស់អ្នកស្រាវជ្រាវ។

## គ. ការសង្កេត

ពេលខ្លះ ទិន្នន័យអាចប្រមូលបានតាមរយៈការសង្កេត។ ឧទាហរណ៍៖ នាយកសាលាមានបំណងបង្កើនកម្រិតអំណាន ក្នុងសាលារៀន។ គាត់អាចចូលតាមថ្នាក់រៀនផ្សេងៗគ្នា និងធ្វើការសង្កេតពីវិធីសាស្ត្របង្រៀនផ្សេងៗគ្នា ដោយកត់សម្គាល់នូវអ្វីដែលបានសង្កេតឃើញទាក់ទងនឹងសកម្មភាព និងឥរិយាបថនៃការចូលរួមរបស់សិស្ស ក៏ដូចជា វិធីសាស្ត្របង្រៀន ដែលគ្រូកំពុងប្រើ ហើយបន្តការសង្កេតបែបនេះនៅថ្នាក់ផ្សេងៗទៀត។ ក្នុងករណីខ្លះ រូបថតក៏អាចប្រើជាភស្តុតាងផងដែរ។ ប៉ុន្តែ ត្រូវមានការពន្យល់ច្បាស់លាស់អំពីអ្វីដែលកំពុងកើតឡើងនៅក្នុងរូបថតទាំងនោះ។

## ឃ. ការពិនិត្យឯកសារ



យើងត្រូវស្វែងរកទិន្នន័យនានាដែលពាក់ព័ន្ធទៅនឹងប្រធានបទស្រាវជ្រាវ។ ការពិនិត្យឯកសារផ្តល់កិច្ចគាំទ្រឆ្លើយតបបរិបទស្រាវជ្រាវ និងជួយផ្តល់ព័ត៌មានបន្ថែមលើប្រធានបទស្រាវជ្រាវ។ ចំពោះទិន្នន័យ ដែលយើងដកស្រង់ចេញពីឯកសារពាក់ព័ន្ធនានា អាចជួយបន្ថែមលើទិន្នន័យដែលប្រមូលបាន ដោយការសម្ភាស និងការពិភាក្សាជាក្រុម (កម្រងសំណួរ ប្រសិនបើពាក់ព័ន្ធ) ហើយក៏អាចជា ផ្នែកនៃការវិភាគទិន្នន័យផងដែរ។ រាល់ទិន្នន័យពាក់ព័ន្ធទាំងអស់អាចប្រើប្រាស់សម្រាប់ជាឯកសារជំនួយដូចជា៖ ឯកសារកម្មវិធីសិក្សា បទបញ្ជាផ្ទៃក្នុងសាលា លិខិតគតិយុត្តរបស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការប្រតិបត្តិប្រចាំឆ្នាំ អត្ថបទកាលិកបត្រ និងសៀវភៅពុម្ពជាដើម។

### *កំណត់សម្គាល់៖ ក្រមសីលធម៌លើការស្រាវជ្រាវប្រតិបត្តិ*

ការប្រកាន់ខ្ជាប់នូវក្រមសីលធម៌ ពិតជាមានសារៈសំខាន់ណាស់គ្រប់ពេល ដែលអ្នកធ្វើការស្រាវជ្រាវ ទោះបី តាមវិធីសាស្ត្រណាក៏ដោយ (សូមមើលជំពូកទី ៣៖ គោលការណ៍ទាំង ៥ នៃក្រមសីលធម៌)។ ក្រៅពីវិធីសាស្ត្រប្រមូលទិន្នន័យខាងលើនៅមានវិធីសាស្ត្រប្រមូលទិន្នន័យផ្សេងៗទៀត ដែលអាចរៀបចំឡើងនៅក្នុងការស្រាវជ្រាវប្រតិបត្តិ។

### *ង. កម្រងសំណួរ*

កម្រងសំណួរជាទូទៅ មិនត្រូវបានប្រើសម្រាប់ការស្រាវជ្រាវ ដែលមានចំនួនអ្នកចូលរួមតិចនោះទេ។ ករណីដែលមានចំនួនអ្នកចូលរួមតិច ការប្រមូលទិន្នន័យតាមរយៈការសម្ភាស ឬការពិភាក្សាក្រុម អាចផ្តល់ទិន្នន័យប្រសើរជាងក្នុងការឆ្លើយទៅនឹងសំណួរស្រាវជ្រាវ។ ផ្ទុយទៅវិញគម្រោងស្រាវជ្រាវប្រតិបត្តិ ដែលមានចំនួនអ្នកចូលរួមច្រើន និងមានទីតាំងភូមិសាស្ត្រផ្សេងគ្នា ដែលធ្វើឱ្យមានការលំបាកក្នុងការសម្ភាស។ ដូចនេះ កម្រងសំណួរអាចមានប្រយោជន៍ជាង។

កម្រងសំណួរ ត្រូវតែរៀបចំឡើងដោយយកចិត្តទុកដាក់បំផុត និងជាទូទៅ ចែកចេញជាពីរផ្នែកគឺ៖ ផ្នែកទី១ ផ្តោតលើព័ត៌មានទូទៅរបស់អ្នកចូលរួម (ភេទ ក្រុមអាយុ ស្ថានភាពការងារ។ល។) ដែលអាចមានឥទ្ធិពលលើចម្លើយរបស់ពួកគេ។ ផ្នែកទី ២ ជាផ្នែកពហុជ្រើសរើស និងសំណួរបើកដែលតម្រូវឱ្យអ្នកចូលរួមសរសេរបន្ថែម ព្រមទាំងបញ្ចូលគំនិតនិងមតិយោបល់ផ្ទាល់ខ្លួន។ ជាទូទៅកម្រងសំណួរត្រូវបានយកទៅ «សាកល្បង» មុនពេលចុះប្រមូលទិន្នន័យជាមួយចំនួនអ្នកចូលរួមជាក់លាក់។ ការសាកល្បងកម្រងសំណួរ ត្រូវធ្វើជាមួយអ្នក ដែលមិនបានចូលរួមក្នុងការសិក្សាជាក់ស្តែង។ ដូចនេះ អ្នកអាចវិនិច្ឆ័យថាតើសំណួរទាំងនោះទទួលបានចម្លើយមកវិញ ដូចការរំពឹងទុក ដែរឬទេ។ ការសាកល្បងកម្រងសំណួរទាំងនោះ នឹងត្រូវការពេលវេលាបន្ថែមទៀត សម្រាប់គម្រោងស្រាវជ្រាវប្រតិបត្តិ។

មុនពេលចែកកម្រងសំណួរ ត្រូវពិនិត្យមើលសមត្ថភាពនៃការអាន និងការសរសេរ ព្រមទាំងភាសាដែលប្រើក្នុងសំណួរឆ្លើយតបនឹងការយល់ដឹងរបស់អ្នកចូលរួម។ ចំពោះការប្រើកម្រងសំណួរជាមួយជនជាតិដើមភាគតិច ឬ ក្រុមបាត់បង់ឱកាស ដែលជាអ្នកមានបទពិសោធន៍តិចតួចក្នុងការបំពេញកម្រងសំណួរនោះ គឺពិតជាមិនសមរម្យទេ។

ការគោរពគោលការណ៍ក្រមសីលធម៌ ក៏មានសារៈសំខាន់ផងដែរក្នុងការស្រាវជ្រាវ និងរក្សាការសម្ងាត់លើព័ត៌មានរបស់អ្នកចូលរួម (សូមមើលជំពូកទី៣)។ ឧទាហរណ៍ កម្រងសំណួរត្រូវបានបង្ហាញដូចខាងក្រោម៖

**សំណួរស្រាវជ្រាវ**

តើបន្ទាប់ពីទទួលបានការបណ្តុះបណ្តាលរយៈពេល ៨ ម៉ោងកន្លងមក អ្នកស្រាវជ្រាវថ្មីអាចចាប់ផ្តើមធ្វើការស្រាវជ្រាវប្រតិបត្តិដោយភាពជឿជាក់កម្រិតណា?

**ការណែនាំ៖** ចូរសរសេរកថាខណ្ឌពន្យល់ពីការស្រាវជ្រាវអ្វីមួយដែលអ្នកនឹងធ្វើ និងពីរបៀបដែលអ្នកចង់ឱ្យអ្នកចូលរួមបំពេញកម្រងសំណួរ ដើម្បីជួយរកព័ត៌មានគាំទ្រដល់ការស្រាវជ្រាវនោះ។ ចូរចងចាំថាអ្នកត្រូវដាក់**ពេលកំណត់**ឱ្យបានច្បាស់លាស់ នៅពេលអ្នកចង់យកមកវិញនូវកម្រងសំណួរដែលបានបំពេញរួចរាល់។

ឈ្មោះ: (ដាក់ក៏បាន មិនដាក់ក៏បាន)...........ភេទ: ........ អាយុ: ........ មុខរបរ: .................

**តារាង ៥៖** ចូរគូសសញ្ញា ✓ ក្នុងប្រអប់ ❑ ដែលអ្នកយល់ថាត្រឹមត្រូវ

| ប្រយោគ | (១). យល់ស្រប សោះ | (២). មិនយល់ ស្រប | (៣). ពុំមាន យោបល់ | (៤). យល់ ស្រប | (៥). យល់ស្រប ទាំងស្រុង |
|---|---|---|---|---|---|
| ១- ខ្ញុំអាចបកស្រាយនិយមន័យការស្រាវជ្រាវប្រតិបត្តិបានយ៉ាងច្បាស់លាស់ដល់អ្នកចូលរួម។ | | | | | ✓ |
| ២- ខ្ញុំដឹងពីធាតុផ្សំសំខាន់ៗនៃការស្រាវជ្រាវប្រតិបត្តិ។ | | | | ✓ | |
| ៣- ខ្ញុំអាចពន្យល់ពីការចូលរួមទូលំទូលាយក្នុងការស្រាវជ្រាវប្រតិបត្តិ។ | | | | | ✓ |
| ៤- ខ្ញុំយល់ពីសារៈសំខាន់នៃការសហការដើម្បីសម្រេចបានការប្រែប្រួលជាវិជ្ជមាន។ | | | | ✓ | |
| ៥- ខ្ញុំដឹងពីរបៀបកំណត់អត្តសញ្ញាណអ្នកចូលរួម។ | | | | ✓ | |
| ៦- ខ្ញុំអាចសរសេរសំណួរស្រាវជ្រាវបានល្អ។ | | | ✓ | | |
| ៧- ខ្ញុំយល់ពីសារៈសំខាន់នៃក្រមសីលធម៌ក្នុងការស្រាវជ្រាវប្រតិបត្តិ។ | | | | | ✓ |
| ៨- ខ្ញុំយល់ពីហេតុផលដែលយើងត្រូវឆ្លុះបញ្ចាំងលើលទ្ធផលនៃការស្រាវជ្រាវ។ | | | | ✓ | |

៩- ហេតុអ្វីបានជាអ្នកចង់ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការស្រាវជ្រាវប្រតិបត្តិ ?

.....................................................................................................................

.....................................................................................................................

១០- តើអ្នកគិតថា នៅពេលអ្នកបានចូលរួមវគ្គបណ្តុះបណ្តាលរួច អ្នកមានទំនុកចិត្តក្នុងការធ្វើគម្រោងស្រាវជ្រាវ ដែរឬទេ ?

.....................................................................................................................

.....................................................................................................................

១១- តើនៅមានផ្នែកណាខ្លះដែលមិនទាន់បានលើកឡើងក្នុងវគ្គបណ្តុះបណ្តាល?

.....................................................................................................................

.....................................................................................................................

១២- តើអ្នកចង់ណែនាំវគ្គបណ្តុះបណ្តាលនេះបន្តដល់មិត្តរបស់អ្នកនៅផ្នែកណាខ្លះ ?

.....................................................................................................................

.....................................................................................................................

១៣- តើអ្នកចង់ចូលរួមវគ្គបណ្តុះបណ្តាលអ្វីខ្លះបន្ថែមទៀតពីការស្រាវជ្រាវប្រតិបត្តិ ?

.....................................................................................................................

.....................................................................................................................

## ២.៥- ការកត់ត្រាទិន្នន័យ



វិធីសាស្ត្រដ៏ងាយស្រួលបំផុត គឺការថតសំឡេងពេលសម្ភាស ដោយប្រើទូរស័ព្ទដៃ ឬឧបករណ៍ថតសំឡេងផ្សេងៗ។ ប៉ុន្តែ អ្នកត្រូវកត់ត្រាឡើងវិញនូវរាល់ពាក្យពេចន៍ ដែលបានថតទុក ដើម្បីងាយស្រួលធ្វើការវិភាគ បានគ្រប់ជ្រុងជ្រោយ។ ការកត់ត្រាកិច្ចសម្ភាសឡើងវិញ អាចចំណាយពេលយូរ និងប្រើកម្លាំងច្រើន។ ជម្រើសមួយទៀត អ្នកអាចស្តាប់សារសំឡេងឡើងវិញឱ្យបានច្រើនដង និងដកស្រង់យកតែចំណុចសំខាន់ៗ។ វិធីសាស្ត្រនេះ អាចកាត់បន្ថយពេលវេលា ហើយចំណុចសំខាន់ៗ ដែលបានដកស្រង់នោះ ឆ្លុះបញ្ចាំងទៅនឹងអ្វីៗ ដែលអ្នកចូលរួមឆ្លើយតបដោយស្មោះត្រង់ (សូមមើលផ្នែក ២.៩ សម្រាប់ព័ត៌មានលម្អិត)។ ជម្រើសមួយទៀតចំពោះការកត់ត្រាទិន្នន័យ នៃការពិភាក្សាក្រុម និងការសម្ភាស អ្នកអាចធ្វើការសរសេរចំណុចសំខាន់ៗ នៅលើក្រដាសក្នុងពេល ដែលអ្នកចូលរួមកំពុងពិភាក្សាគ្នា។ យើងគួរប្រើក្រដាសខ្នាតធំ ដើម្បីងាយស្រួលបង្ហាញអ្នកចូលរួមឱ្យមើលឃើញពីចំណុចដែលបានពិភាក្សា ហើយយល់ស្រប ឬពុំយល់ស្រប ចំពោះចំណុចដែលបានកត់ត្រា។ បន្ទាប់ពីសម្ភាស ឬ ពិភាក្សាក្រុម អ្នកស្រាវជ្រាវ អាចបញ្ចូលទិន្នន័យដែលបានកត់ត្រា ដោយដៃ ដើម្បីវិភាគ។

បើអ្នកជ្រើសរើសការថតសំឡេងរបស់អ្នកចូលរួមនៅពេលសម្ភាស និងពិភាក្សាក្រុម អ្នកត្រូវធ្វើការកត់ត្រាពាក្យពេចន៍ទាំងអស់ចូលក្នុងទម្រង់ឱ្យរួចស្រេច ដើម្បីធ្វើការវិភាគ។ ប៉ុន្តែ ការប្រើវិធីនេះគឺត្រូវចំណាយពេលវេលាច្រើន។ ជម្រើសមួយទៀត ដើម្បីចៀសវាងការចម្លងឡើងវិញគ្រប់ពាក្យពេចន៍ អ្នកអាចជ្រើសយកតែចំណុចសំខាន់ៗ បើទោះបី ជាត្រូវស្តាប់សំឡេងច្រើនដងក៏ដោយ។ សូមមើលឧទាហរណ៍ខាងក្រោម៖

> ការថតសំឡេងសម្ភាសជាមួយមន្ត្រីការិយាល័យអយក. ក្នុងការឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ៖ តើយើងអាចធ្វើឱ្យការចូលរួម និងគណនេយ្យភាពក្នុងការអភិវឌ្ឍផែនការប្រតិបត្តិប្រចាំឆ្នាំ ធ្វើឱ្យបានប្រសើរឡើងដោយរបៀបណា?

«ជារៀងរាល់ឆ្នាំ...យើងដឹងថា យើងត្រូវរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ...ហើយមានពេលកំណត់ច្បាស់លាស់។ ប៉ុន្តែ យើងជួបការលំបាកក្នុងការរៀបចំ ហើយមានការយឺតយ៉ាវក្នុងការផ្ញើជូន...ពេលខ្លះធ្វើមិនទាន់ពេល...ខ្ញុំគិតថាធ្លាប់ធ្វើទាន់ពេលម្តង...តាំងពីពីរបីឆ្នាំមុនមក ហើយនៅពេលនោះអ្វីៗ មិនដូចគ្នាទេ...គន្ធាជាអ្នកទទួលខុសត្រូវធ្វើកិច្ចការនេះ។ ខ្ញុំត្រូវការព័ត៌មានពីសាលា ប៉ុន្តែពេលខ្លះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនធ្វើមិនបានល្អ។ ដូចនេះ ខ្ញុំត្រូវចុះទៅសាលារៀនដោយខ្លួនឯង...ពេលខ្លះខ្ញុំត្រូវទៅជាច្រើនដង...ខ្ញុំទៅម្តងហើយម្តងទៀត។ ឥឡូវគេបានប្តូរទម្រង់ថ្មីនៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ហើយយើងត្រូវរៀបចំខុសពីមុនដែរ...គ្មាននរណាម្នាក់ចេះធ្វើនោះទេ...ហើយខ្ញុំច្បាស់ថាមិនមែនតែរូបខ្ញុំទេដែលជួបរឿងបែបនេះ។ យើងទទួលបានការប្រជុំណែនាំមានរយៈពេលកន្លះថ្ងៃដែរ។ ចំណុចដែលចាប់អារម្មណ៍ក្នុងការប្រជុំណែនាំនេះ គឺមានអាហារសម្រន់ឆ្ងាញ់! ការប្រជុំណែនាំនេះ នៅមិនទាន់គ្រប់គ្រាន់ទេ...ភាគច្រើន យើងទាំងអស់គ្នាមិនអាចយល់បាននូវអ្វីដែលបានណែនាំនោះទេ បើទោះបី យើងខំកត់ត្រាទុកក៏ដោយ...វាពិបាកមែន! ខ្ញុំមិនដឹងថា ស្រុកផ្សេងទៀតយ៉ាងម៉េចដែរទេ...ចុងក្រោយ យើងចម្លងសកម្មភាពពីផែនការឆ្នាំមុនមកដាក់...គ្មានអ្នកណាចាប់អារម្មណ៍ឡើយ ដូចនេះ ខ្ញុំគិតថា វាមិនអីទេ។ ឥឡូវ គេចង់ឱ្យដាក់សកម្មភាពទាំងអស់នោះ...មានការងារជាច្រើនដែលត្រូវធ្វើ និងប្រែប្រួលជាញឹកញាប់....»។



នៅពេលស្តាប់សំឡេងថតជាច្រើនលើកច្រើនសារួចមក អ្នកនឹងអាចកំណត់ចំណុចសំខាន់ ហើយដកស្រង់ចំណុចទាំងនោះ ដូចខាងក្រោម៖

...ពេលខ្លះធ្វើមិនទាន់ពេល
...ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនធ្វើមិនបានល្អ
...ខ្ញុំត្រូវចុះទៅសាលារៀនដោយខ្លួនឯង
...ខ្ញុំទៅម្តងហើយ ម្តងទៀត
...ប្តូរទម្រង់ថ្មីនៃការរៀបចំ
...បានការប្រជុំណែនាំមានរយៈពេលកន្លះថ្ងៃដែរ
...ការប្រជុំណែនាំនេះ នៅមិនទាន់គ្រប់គ្រាន់ទេ
...យើងទាំងអស់គ្នាមិនអាចយល់បាននូវអ្វីដែលបានណែនាំនោះទេ
...យើងចម្លងសកម្មភាពពីផែនការឆ្នាំមុនមកដាក់
...គ្មានអ្នកណាចាប់អារម្មណ៍ឡើយ
...ការងារជាច្រើនដែលត្រូវធ្វើ និងប្រែប្រួលជាញឹកញាប់ គ្រាន់តែធ្វើការកត់ត្រាលើចំណុចសំខាន់ៗ ដែលគេបាននិយាយ អ្នកអាចយកចំណុចទាំងនោះ ដោយមិនបាច់សរសេរឡើងវិញនូវអ្វី ដែលមិនពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវ។ ឧទាហរណ៍ «មានអាហារសម្រន់ឆ្ងាញ់»។ ការកត់ត្រាចំណុចសំខាន់ៗក៏អាចជួយការវិភាគទិន្នន័យបានដែរពីព្រោះអាចកាត់បន្ថយចំនួនពាក្យពេចន៍ដែលត្រូវយកមកវិភាគ។ ទោះបីជាយ៉ាងណា អ្វីដែលចាំបាច់អ្នកស្រាវជ្រាវ ត្រូវស្រង់គោលគំនិតសំខាន់ៗ នៃការសម្ភាស ហើយគ្រប់សំឡេងនៃអ្នកចូលរួមនោះ គឺមានភាពត្រឹមត្រូវនិងទៀងត្រង់។ បន្ទាប់មក អ្នកអាចរក្សានូវសំឡេងដែលបានថតទុក ពីព្រោះអ្នកអាចធ្វើការផ្ទៀងផ្ទាត់ នៅពេលវិភាគទិន្នន័យឡើងវិញ ដើម្បីឱ្យប្រាកដថាទិន្នន័យសំខាន់ៗ ទាំងអស់ត្រូវបានយកមកវិភាគគ្រប់ជ្រុងជ្រោយ។

## ២.៦- *ការវិភាគទិន្នន័យ*

ការវិភាគទិន្នន័យ គឺមានលក្ខណៈស្មុគស្មាញ និងចំណាយពេលច្រើនជាងគេក្នុងដំណើរការស្រាវជ្រាវប្រតិបត្តិ ពីព្រោះ ត្រូវវិភាគឱ្យបានស៊ីជម្រៅ និងធ្វើការផ្ទុះបញ្ចាំង។ ការវិភាគទិន្នន័យដែលល្អ គឺត្រូវធ្វើតាមដំណាក់កាលនីមួយៗនៃគោលការណ៍ណែនាំ។ ជាទូទៅ អ្នកដឹកនាំស្រាវជ្រាវជាអ្នកទទួលខុសត្រូវក្នុងការវិភាគទិន្នន័យ ប៉ុន្តែអ្នកចូលរួមក៏អាចជួយវិភាគទិន្នន័យបានដែរ ប្រសិនបើមានការណែនាំបានច្បាស់លាស់។

**គំនូសតាង ២៖** គោលការណ៍ណែនាំពីដំណើរការនៃការវិភាគទិន្នន័យ




ឧទាហរណ៍ខាងក្រោមបង្ហាញពីគំរូមួយចំនួននៃការវិភាគទិន្នន័យ៖

**<u>សំណួរស្រាវជ្រាវ</u>**
តើយើងអាចជួយគាំទ្រសិស្សឱ្យបញ្ចប់ការសិក្សានៅកម្រិតមូលដ្ឋានបានដោយរបៀបណា?
**<u>សំណួរគន្លឹះ</u>**
តើមូលហេតុអ្វីខ្លះដែលប្អូនមិនបានមករៀនទៀងទាត់?

**តារាង ៥.ក៖** ឧទាហរណ៍នៃការប្រមូលទិន្នន័យដោយនាយកសាលាតាមរយៈការសម្ភាសជាមួយសិស្ស

| ល.រ | ភេទ | ទិន្នន័យកត់ត្រាចេញពីការសម្ភាស | គំនិតសំខាន់ | ចំណាត់ថ្នាក់ |
|---|---|---|---|---|
| ១ | ស្រី | ឪពុកខ្ញុំតែងតែផឹកស្រា លេងល្បែងនិងប្រើអំពើហិង្សាក្នុងគ្រួសារ។ ដូច្នេះ ខ្ញុំមិនអាចផ្ដោតលើការសិក្សានៅសាលាបានទេ។ ខ្ញុំតែងតែគេចសាលា និងមិនចង់ទៅរៀន។ | - ផឹកស្រា<br>- លេងល្បែង<br>- អំពើហិង្សា | **កត្តាគ្រួសារ** |

| | | | | |
|---|---|---|---|---|
| ២ | ស្រី | ពេលឪពុកម្ដាយខ្ញុំទៅស៊ីឈ្នួល ធ្វើស្រែចំការ។ ខ្ញុំត្រូវនៅមើលថែប្អូនប្រុសខ្ញុំ ពីព្រោះគាត់ទើបតែមានអាយុ ២ ឆ្នាំ។ តាមពិត ខ្ញុំចូលចិត្តរៀនដែរ តែខ្ញុំមិនអាចទៅសាលាឱ្យបានទៀងទាត់ដូចមិត្តរបស់ខ្ញុំទេ។ | - ក្រីក្រ | **កត្តាគ្រួសារ** |
| ៣ | ប្រុស | ក្នុងថ្នាក់រៀនរបស់ខ្ញុំ មានសិស្សខិលខូចមួយចំនួនតូចដែលបង្កបញ្ហាក្នុងម៉ោងរៀន ដែលនាំឱ្យខ្ញុំមិនអាចផ្ដោតលើការសិក្សាបានទេ ព្រោះមានអារម្មណ៍ភ័យខ្លាច។ | - ក្រុមសិស្សខិលខូច | **កត្តាសាលា** |

ទិន្នន័យ តារាង ៥.ក បញ្ជាក់ថា សិស្សមួយចំនួនបានពិពណ៌នាពីបញ្ហាក្នុងគ្រួសាររបស់ពួកគេ។ បញ្ហាដែលលើកឡើងទាំងនេះ អាចជាគំនិតសំខាន់ដូចជា ការផឹកស្រា ការលេងល្បែង អំពើហិង្សា ភាពក្រីក្រ ដែលចាត់ថ្នាក់ជាកត្តាគ្រួសារ។ ប៉ុន្តែ បញ្ហាក្រុមសិស្សខិលខូច អាចចាត់ថ្នាក់ជាកត្តាសាលារៀន។ ក្នុងន័យវិជ្ជមាន ការដោះស្រាយស្ថានភាព គ្រួសារមានលក្ខណៈស្មុគស្មាញ។ ដូច្នេះ នាយកសាលាគួរផ្ដោតលើការសិក្សាពីបញ្ហានៅក្នុងសាលារៀនវិញ ពីព្រោះនាយក និងគ្រូបង្រៀនមានដែនសមត្ថកិច្ចអាចទប់ស្កាត់ក្រុមសិស្សខិលខូចបាន។ «គំនិតសំខាន់» អាស្រ័យលើសំណួរស្រាវជ្រាវ។

**តារាង ៥.ខ៖** ឧទាហរណ៍របស់មន្ត្រីស្រាវជ្រាវនៃមន្ទីរ ការិយាល័យអយក. សម្ភាសគ្រូបង្រៀន

**<u>សំណួរស្រាវជ្រាវ</u>**

តើយើងអាចកំណត់ លក្ខណសម្បត្តិនាយកសាលាដែលគាំទ្រការលើកកម្ពស់បំពេញការងាររបស់គ្រូបង្រៀនបានដោយរបៀបណា?

**<u>សំណួរគន្លឹះ</u>**

១- តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលបំពេញការងារក្នុងសាលារៀន?

២- តើនាយកសាលាប្រគល់ភារកិច្ចដល់គ្រូបង្រៀនដោយរបៀបណា?

៣- តើនាយកសាលាផ្ដល់ការលើកទឹកចិត្តដល់បុគ្គលិកអប់រំដោយរបៀបណា?

| ល.រ | ភេទ | ទិន្នន័យកត់ត្រាចេញពីការសម្ភាស | គំនិតសំខាន់ | ចំណាត់ថ្នាក់ |
|---|---|---|---|---|
| ១ | ប្រុស | ខ្ញុំសប្បាយចិត្តជាខ្លាំង ដែលបានបម្រើការក្នុងសាលារៀននេះ ព្រោះគ្រូបង្រៀនភាគច្រើនរួសរាយ និងចេះជួយគ្នា។ នាយកខ្ញុំតែងតែយក | -កម្រិតអប់រំ<br>-ទេពកោសល្យ | **ប្រគល់ភារកិច្ច** |

| | | | | |
|---|---|---|---|---|
| | | ចិត្តទុកដាក់ខ្ពស់លើបុគ្គលិក។ មុនពេលដែលគាត់ប្រគល់ភារកិច្ចដល់បុគ្គលិក គាត់តែងតែពិចារណាលើកម្រិតអប់រំ ទេពកោសល្យ បទពិសោធការងារ និងអាកប្បកិរិយា។ | -បទពិសោធការងារ<br>-អាកប្បកិរិយា | |
| ២ | ប្រុស | ខ្ញុំពេញចិត្តនឹងការងារខ្ញុំ ពីព្រោះបុគ្គលិកទាំងអស់ និងនាយកសាលាមានទំនាក់ទំនងល្អ។ យើងតែងតែជួយគ្នាទៅវិញទៅមក នៅពេលដែលនរណាម្នាក់មានបញ្ហា។ ថ្មីៗនេះ មានគ្រូម្នាក់ធ្លាក់ខ្លួនឈឺ យើងទាំងអស់គ្នា រួមទាំងនាយកបានចុះទៅសួរសុខទុក្ខគាត់។ គ្រូភាគច្រើនពិតជារីករាយក្នុងការបំពេញការងារ ព្រោះពួកយើងធ្វើការដោយប្រើចំណេះដឹង និងជំនាញរៀងៗខ្លួន។ | -ចំណេះដឹង<br>-ជំនាញ | **ទំនាក់ទំនងល្អរវាងបុគ្គល** |
| ៣ | ស្រី | ជួនកាល ខ្ញុំហាក់ដូចជាអន់ចិត្តជាមួយនាយករបស់ខ្ញុំដែរ។ គាត់មានភាពតឹងតែង និងមានពេលខ្លះស្តីបន្ទោសបុគ្គលិក។ ប៉ុន្តែ ខ្ញុំកត់សម្គាល់ឃើញថា ការប្រគល់ភារកិច្ចទៅដល់បុគ្គលិកមានភាពត្រឹមត្រូវ។ ខ្ញុំមិនដែលឮបុគ្គលិករិះគន់ពីគាត់ទេ។ | ភាពត្រឹមត្រូវ | **ប្រគល់ភារកិច្ច** |
| ៤ | ស្រី | ចំពោះការលើកទឹកចិត្តបុគ្គលិក ខ្ញុំគិតថានាយកធ្វើបានល្អ។ នៅពេលណាដែលបុគ្គលិកមានស្នាដៃល្អ គាត់តែងតែលើកសរសើរក្នុងពេលប្រជុំ។ នៅចុងឆ្នាំសិក្សា គ្រូដែលមានស្នាដៃឆ្នើមតែងតែទទួលបានរង្វាន់លើកទឹកចិត្ត។ | -សរសើរ<br>-រង្វាន់<br>-ស្នាដៃឆ្នើម | **លើកទឹកចិត្ត** |
| ៥ | ស្រី | ខ្ញុំគិតថា គាត់មានភាពជាអ្នកដឹកនាំល្អក្នុងការលើកទឹកចិត្តបុគ្គលិក ព្រោះគាត់ចេះលើកទឹកចិត្តបុគ្គលិកណាដែលឧស្សាហ៍ព្យាយាម ហើយណែនាំដល់បុគ្គលិកណា ដែលមិនសកម្ម ដូចជាគ្រូចូលចិត្តមកយឺតឬមានអវត្តមានច្រើន។ តែទោះបីជាមានការស្តីបន្ទោសខ្លះក្តី ក៏ពួកគាត់មិនខឹងនឹងគាត់ដែរ។ | ឧស្សាហ៍ព្យាយាម | **លើកទឹកចិត្ត** |

តាមរយៈអ្វីដែលគ្រូបាននិយាយប្រាប់ យើងអាចមើលឃើញថា នាយកសាលាបានប្រគល់ភារកិច្ចដល់បុគ្គលិកយ៉ាងមានប្រសិទ្ធភាព និងផ្តល់ការលើកទឹកចិត្តបុគ្គលិកឱ្យបំពេញការងារបានយ៉ាងល្អ។ គាត់ក៏មានទំនាក់ទំនងល្អជាមួយបុគ្គលិកផងដែរ។ ទោះបីជាមានបុគ្គលិកមួយចំនួនតូចសម្តែងនូវការមិនសប្បាយចិត្តជាមួយគាត់ក្តី ប៉ុន្តែ ពួកគេបានលើកសរសើរថាគាត់មានភាពត្រឹមត្រូវ ឧស្សាហ៍ព្យាយាម និងចេះលើកទឹកចិត្តបុគ្គលិកឱ្យធ្វើការបានល្អ។ នាយកសាលាបានដឹងច្បាស់ពីជំនាញរបស់គ្រូនៅពេលប្រគល់ភារកិច្ចឱ្យ។ ដូច្នេះ យើងអាចកត់សម្គាល់បានថា នាយកសាលាគួរតែមានភាពជាអ្នកដឹកនាំដ៏មានប្រសិទ្ធភាពដូចជា ជំនាញ បែងចែកភារកិច្ច ទំនាក់ទំនងរវាងបុគ្គល ឧស្សាហ៍ព្យាយាម និងលើកសរសើរដល់បុគ្គលិក។



បន្ទាប់ពីយើងទទួលលទ្ធផលតាមការវិភាគទិន្នន័យ យើងអាចផ្ទៀងផ្ទាត់ជាមួយសំណួរស្រាវជ្រាវ។ ប្រសិនបើ ឆ្លើយតប យើងអាចធ្វើសេចក្តីសន្និដ្ឋាន និងលើកជាសំណូមពរ ឬ អនុសាសន៍ ដើម្បីអនុវត្តការងារឱ្យមានភាពប្រែប្រួលជាវិជ្ជមាន។ បើត្រូវការទិន្នន័យបន្ថែម យើងអាចចាប់ផ្តើមវដ្តថ្មីមួយទៀត នៃការស្រាវជ្រាវប្រតិបត្តិ (មើលរូបភាពទី១)។

## *២.៧- ការឆ្លុះបញ្ចាំងក្នុងដំណើរការស្រាវជ្រាវប្រតិបត្តិ*

ការឆ្លុះបញ្ចាំងឡើងវិញ គឺជាដំណើរការនៃការបង្ហាញឱ្យយល់ពីខ្លួនឯងក្នុងនាមជាអ្នកស្រាវជ្រាវ ដើម្បីធ្វើឱ្យការវិភាគមានភាពត្រឹមត្រូវ និងមានប្រសិទ្ធភាព។ ការឆ្លុះបញ្ចាំងឡើងវិញទាក់ទងទៅនឹងការសន្និដ្ឋាន និងព្យាករណ៍ទុកជាមុនដែលអ្នកបានលើកយកមកសិក្សាស្រាវជ្រាវ ហើយក៏អាចមានឥទ្ធិពលដល់លទ្ធផលស្រាវជ្រាវផងដែរ។ យើងទាំងអស់គ្នា គ្មានអ្នកណាម្នាក់ដែលចេះព្យាករ និងបុរេវិនិច្ឆ័យច្បាស់លាស់នោះទេ គឺសុទ្ធតែផ្អែកលើបទពិសោធជីវិត និងអ្វីៗដែលធ្លាប់បានដឹងឮ ពីអ្នកជុំវិញប៉ុណ្ណោះ។

ការឆ្លុះបញ្ចាំងឡើងវិញ ធ្វើឱ្យយើងចេះគិតពីផលជះលើការសន្និដ្ឋាន លទ្ធផលស្រាវជ្រាវ និងការផ្សព្វផ្សាយចំណេះដឹងថ្មី ព្រមទាំងអាចជួយឱ្យយើងចេះពិចារណាពីអ្នកដែលត្រូវបានគេផាត់ចេញពីសង្គម និងអ្នកដែលត្រូវផ្តល់អាទិភាព ព្រមទាំងធ្វើការប៉ាន់ស្មានទុកមុនពីផលជះមកលើការស្រាវជ្រាវ និងអ្នកចូលរួម។ អ្នកស្រាវជ្រាវប្រតិបត្តិអាចសាកសួរសំណួរឆ្លុះបញ្ចាំងមានដូចជា៖




## ២.៨- ការដាក់បញ្ចូលគ្នា ការចែករំលែកលទ្ធផលស្រាវជ្រាវ ការផ្ដល់អនុសាសន៍

បន្ទាប់ពីបានបញ្ចប់ការស្រាវជ្រាវ យើងអាចរៀបចំកម្មវិធីធ្វើបទបង្ហាញ ដើម្បីផ្សព្វផ្សាយលទ្ធផលដល់អ្នកចូលរួម តាមរយៈរបាយការណ៍ បទបង្ហាញ PowerPoint និងសេចក្ដីសង្ខេប។ ដោយផ្អែកលើប្រធានបទស្រាវជ្រាវ យើងអាចចែករំលែកលទ្ធផលដល់ភាគីពាក់ព័ន្ធ ដោយផ្ដល់ជាអនុសាសន៍ ប្រសិនបើចាំបាច់។ ការធ្វើបែបនេះ យើងអាចទទួលបានជាតុចូលមតិយោបល់ត្រឡប់មកវិញ និងអនុសាសន៍សំខាន់ៗ បន្ថែមទៀតពីអ្នកចូលរួម។ ជាចុងក្រោយ លទ្ធផលស្រាវជ្រាវអាចផ្ដល់ភស្តុតាង ដើម្បីធ្វើផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ព្រមទាំងពង្រឹងវិធីសាស្ត្របង្រៀនជាដើម។



ឧទាហរណ៍៖ យើងអាចចែករំលែកលទ្ធផលស្រាវជ្រាវក្នុងការប្រជុំបច្ចេកទេសប្រចាំខែ និងការប្រជុំគណៈកម្មការគ្រប់គ្រងសាលារៀន។

| **អ្នកស្រាវជ្រាវ** | **សកម្មភាពចែករំលែកលទ្ធផលស្រាវជ្រាវ** |
|---|---|
| គ្រូបង្រៀន | ប្រជុំបច្ចេកទេសប្រចាំខែ<br>ប្រជុំគណៈកម្មការគ្រប់គ្រងសាលារៀន |
| នាយកសាលា | ប្រជុំបច្ចេកទេសប្រចាំខែ<br>ប្រជុំគណៈកម្មការគ្រប់គ្រងសាលារៀន<br>សន្និបាតអប់រំ |
| ការិយាល័យអយក.<br>មន្ទីរអយក. | ប្រជុំប្រចាំខែ<br>សិក្ខាសាលាផ្សព្វផ្សាយ<br>សន្និបាតអប់រំ |

# ជំពូកទី៣

## ក្រមសីលធម៌ស្រាវជ្រាវ

នៅពេលធ្វើការស្រាវជ្រាវប្រតិបត្តិ អ្នកស្រាវជ្រាវត្រូវតែពិនិត្យមើល ជជែក និងពិភាក្សាអំពីបញ្ហាក្រមសីលធម៌។ នៅគ្រប់គម្រោងស្រាវជ្រាវ អ្នកស្រាវជ្រាវទាំងអស់ ទាំងអ្នកដឹកនាំការស្រាវជ្រាវ និងអ្នកចូលរួមស្រាវជ្រាវ ត្រូវផ្តោតការយកចិត្តទុកដាក់លើចរិយាសម្បទាប្រកបដោយសីលធម៌។ ចរិយាសម្បទានេះ ត្រូវអនុវត្តគ្រប់សកម្មភាព ក្នុងដំណើរការស្រាវជ្រាវ ដើម្បីជានាការរក្សាសុវត្ថិភាពនិងការការពារកុមារ។ ជាទូទៅក្រមសីលធម៌ស្រាវជ្រាវ មាននូវគោលការណ៍សំខាន់ៗ ៥ យ៉ាងគឺ៖

### គោលការណ៍ទី១៖ មិនបង្ខិតបង្ខំ

អ្នកស្រាវជ្រាវត្រូវគោរពសិទ្ធិភាពផ្ទាល់ខ្លួន ស្វ័យភាព ភាពទីទៃពីគ្នា តម្លៃ និងសេចក្តីថ្លៃថ្នូររបស់អ្នកចូលរួមជាបុគ្គល ក្រុម និងសហគមន៍។ ការស្រាវជ្រាវប្រតិបត្តិ ត្រូវតែធ្វើឡើង ដោយភាពស្មោះត្រង់ ជាមួយនឹងការយល់ពីចំណុចរសើបការយោគយល់គ្នា ការពិចារណាស៊ីជម្រៅ និងការយកចិត្តទុកដាក់។ អ្នកស្រាវជ្រាវត្រូវធ្វើការស្រាវជ្រាវដោយមានទំនួលខុសត្រូវសង្គមក្នុងពេលស្រាវជ្រាវ និងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ។ អ្នកស្រាវជ្រាវត្រូវផ្តោតលើផលប្រយោជន៍ស្រាវជ្រាវឱ្យបានច្រើន (លទ្ធផលវិជ្ជមាន) និងកាត់បន្ថយផលប៉ះពាល់ឱ្យមានតិចបំផុត។

ឧទាហរណ៍៖ គន្ធាបានធ្វើការសិក្សាស្រាវជ្រាវប្រតិបត្តិមួយស្តីពី ការបោះបង់ការសិក្សានៅអនុវិទ្យាល័យ។ នាងសម្ភាសសិស្ស ៤ នាក់គឺ ណារី ពិសី វង្ឍា និងចំរើន ប៉ុន្តែ នៅពេលដល់ពាក់កណ្តាលនៃការសម្ភាស ណារីមានអារម្មណ៍មិនសប្បាយចិត្ត និងភ័យខ្លាចខ្លាំង ក្នុងការផ្តល់ព័ត៌មានតទៅទៀត។ ដោយមើលឃើញស្ថានភាពបែបនេះ គន្ធាមិនបានសុំណារី ឱ្យឆ្លើយសំណួរបន្ថែមនោះទេ ហើយបញ្ឈប់ការសម្ភាសតែម្តងដោយគោរពគោលការណ៍ «មិនបង្ខិតបង្ខំ»។



### គោលការណ៍ទី២៖ ការទទួលបានការព្រមព្រៀង

អ្នកចូលរួមទាំងអស់ត្រូវតែយល់ដឹងពីបញ្ហាដែលត្រូវស្រាវជ្រាវ និងវិធីសាស្ត្រស្រាវជ្រាវ (គោលបំណង វិធីសាស្ត្រ ទីតាំង ក្របខណ្ឌពេលវេលា។ ល។)។ អ្នកស្រាវជ្រាវត្រូវប្រតិបត្តិខ្លួនឱ្យគេមើលឃើញថាជាបុគ្គលដែលអាចជឿទុកចិត្តបាន មានតម្លាភាព និងមានភាពស្មោះត្រង់

ចំពោះការស្រាវជ្រាវ។ អ្នកស្រាវជ្រាវត្រូវប្រាប់អ្នកចូលរួមទាំងអស់ថា ពួកគេអាចដកខ្លួនចេញពីការស្រាវជ្រាវបានគ្រប់ពេលនិងដោយគ្មានផលវិបាកអ្វីឡើយ។ អ្នកចូលរួមទាំងអស់ត្រូវដឹងពីរបៀបនៃការប្រើប្រាស់ និងចែកចាយព័ត៌មានដែលខ្លួនបានផ្តល់ (សូមមើលឧបសម្ព័ន្ធ ៣)។

ឧទាហរណ៍៖ គន្ធាបានធ្វើគម្រោងស្រាវជ្រាវប្រតិបត្តិមួយស្តីពីការបោះបង់ការសិក្សានៅអនុវិទ្យាល័យ។ នាងបានសម្ភាសនាយកសាលា ក៏ដូចជាអ្នកចូលរួមដទៃទៀត។ គន្ធាបានពន្យល់ពួកគេ យ៉ាងច្បាស់អំពីអ្វី ដែលត្រូវធ្វើការស្រាវជ្រាវ និងរបៀបប្រើប្រាស់ទិន្នន័យ ដើម្បីធានាថា អ្នកចូលរួមមានទំនុកចិត្តនិងយល់ច្បាស់លើដំណើរការស្រាវជ្រាវ។ ជាចុងក្រោយ នាងបានស្នើសុំឱ្យអ្នកចូលរួមចុះហត្ថលេខាលើកិច្ចព្រមព្រៀង។ នៅក្នុងកិច្ចសម្ភាសមួយ នាយកសាលាបាននាំមិត្តម្នាក់មកជាមួយ ហើយគាត់បានសួរថា តើនាងអាចនៅចូលរួមក្នុងការសម្ភាសបាន ឬទេ។ មិត្តម្នាក់នោះមិនបានដឹងពីបញ្ហានៃការស្រាវជ្រាវ និងមិនបានបំពេញកិច្ចព្រមព្រៀង។ ដូច្នេះ គន្ធាបានប្រាប់ថា គាត់មិនអាចចូលរួមការសម្ភាសបានឡើយ។



## *គោលការណ៍ទី៣៖ ការរក្សាការសម្ងាត់ និងការមិនបញ្ចេញឈ្មោះ*

នៅក្នុងរបាយការណ៍តាមដានការធ្វើបទបង្ហាញ ឬផែនការ គេមិនប្រើឈ្មោះពិតនោះទេ ដើម្បីឱ្យមានទំនុកចិត្តរវាងអ្នកស្រាវជ្រាវ និងអ្នកចូលរួម។ ការមិនបញ្ចេញឈ្មោះ ធ្វើឱ្យអ្នកចូលរួមអាចនិយាយបានដោយសេរីពីព្រោះអត្តសញ្ញាណរបស់ពួកគេត្រូវបានរក្សាការសម្ងាត់។ ការរក្សាសិទ្ធិអ្នកចូលរួម ដើម្បីគេបញ្ចេញមតិ យោបល់ និងបញ្ហាផ្ទាល់ខ្លួនគឺជាការរក្សានូវគោលការណ៍ «មិនបង្ខិតបង្ខំ»។

ឧទាហរណ៍៖ គន្ធាធ្វើឱ្យណារី ពិសី វដ្ឋា និងចំរើន មានការជឿជាក់ អារម្មណ៍សុវត្ថិភាព និងមានការការពារ ដោយពន្យល់ថា រាល់ព័ត៌មានដែលពួកគេផ្តល់ឱ្យ ត្រូវបានរក្សាជាការសម្ងាត់ មានសុវត្ថិភាព និងមានការការពារ។ ល្ងាចមួយ ប្តីគន្ធាសួរពីអ្វី ដែលនាងបាននិយាយជាមួយក្មេងៗ អ្នកចូលរួមសម្ភាស។ ប៉ុន្តែ ដោយសារតែត្រូវរក្សាការសម្ងាត់ និងមិនបញ្ចេញឈ្មោះ គន្ធាមិនអាចប្រាប់ព័ត៌មានបាន សូម្បីតែប្តីនាង។




## *គោលការណ៍ទី៤៖ ការចៀសវាងការបោកបញ្ឆោត*

អ្នកស្រាវជ្រាវមិនត្រូវផ្តល់ព័ត៌មានមិនពិត និងមិនត្រូវបំភាន់ដោយចេតនាដល់អ្នកចូលរួម លើទិដ្ឋភាពណាមួយនៃការស្រាវជ្រាវឡើយ។

អ្នកផ្តល់ការសម្ភាសត្រូវចូលរួមក្នុងគម្រោងស្រាវជ្រាវដោយស្ម័គ្រចិត្ត និងមិនមានការបង្ខិតបង្ខំ ឬ ការគំរាមណាមួយនោះទេ។ លទ្ធផលស្រាវជ្រាវ ត្រូវបានផ្សព្វផ្សាយដោយភាពស្មោះត្រង់ និងគ្មានការក្លែងបន្លំព័ត៌មាន និងទិន្នន័យ។ ឧទាហរណ៍៖ គន្ធាពិតជាចង់ឱ្យសិស្សទាំងអស់ចូលរួមក្នុងគម្រោងស្រាវជ្រាវ ប៉ុន្តែ សិស្សខ្លះមិនចង់ចូលរួមទេ។ ដើម្បីលើកទឹកចិត្តសិស្សឱ្យចូលរួម គន្ធាបានប្រាប់ថា នាងនឹងផ្តល់រង្វាន់ ប្រសិនបើពួកគេចូលរួមផ្តល់សម្ភាស។ ក្រោយមក គន្ធាបានដឹងថា នេះជាកំហុសឆ្គង ព្រោះសិស្សត្រូវចូលរួមក្នុងគម្រោងស្រាវជ្រាវដោយស្ម័គ្រចិត្ត និងមិនមានការបង្ខិតបង្ខំ។ នាងបាននិយាយប្រាប់សារជាថ្មីថា សិស្សមានជម្រើសក្នុងការចូលរួមពិភាក្សាក្រុម ប៉ុន្តែ ប្រសិនបើ មានអារម្មណ៍មិនល្អ មិនបាច់ចូលរួមក៏បាន។ នាងនឹងមិនឱ្យរង្វាន់ដល់អ្នកណាទាំងអស់។

## *គោលការណ៍ទី៥៖ សិទ្ធិក្នុងការដកខ្លួន*

អ្នកចូលរួមមានសិទ្ធិដកខ្លួននៅគ្រប់ដំណាក់កាលណាមួយចេញពីការស្រាវជ្រាវ។ ប្រសិនបើអ្នកចូលរួមសម្រេចចិត្តដកខ្លួនចេញពីការស្រាវជ្រាវ មិនត្រូវដាក់សម្ពាធឱ្យនៅបន្តការសម្ភាសនិងមិនត្រូវឱ្យមានផលអវិជ្ជមានណាមួយដល់ពួកគេឡើយ។ ឧទាហរណ៍៖ នៅពេលផ្តល់សម្ភាសជាមួយអ្នកគ្រូគន្ធា ចំរើនមានអារម្មណ៍មិនល្អ និងមិនចង់បន្តការចូលរួមសម្ភាសតទៅទៀត។ គេសុំចាកចេញពីគម្រោងស្រាវជ្រាវនេះ។ គន្ធាពិតជាមិនចង់ឱ្យចំរើនចាកចេញទេ ដោយសារតែគេមានព័ត៌មានសំខាន់ក្នុងការចែករំលែក ប៉ុន្តែ គន្ធាយល់ថា ត្រូវតែគោរពតាមគោលការណ៍ក្រមសីលធម៌ក្នុងការដកខ្លួនចេញ។ ដូច្នេះ នាងក៏យល់ព្រមតាមការស្នើសុំ ហើយឱ្យចំរើនចាកចេញ។ គន្ធាញញឹម ដូច្នេះ ចំរើនដឹងថាគេមិនមានបញ្ហាអ្វីទេ។



## *ការស្រាវជ្រាវជាមួយកុមារ*

ការយកចិត្តទុកដាក់លើបញ្ហាក្រមសីលធម៌មានសារៈសំខាន់ មិនត្រឹមតែធ្វើការស្រាវជ្រាវជាមួយមនុស្សពេញវ័យនោះទេ ប៉ុន្តែ កាន់តែសំខាន់ថែមទៀត នៅពេលធ្វើការស្រាវជ្រាវជាមួយកុមារ។ កុមារងាយរងគ្រោះជាងមនុស្សពេញវ័យ។ កុមារតែងជឿ និងធ្វើតាមនូវអ្វីៗ ដែលមនុស្សធំបានប្រាប់។ ដូចនេះ នៅពេលមានកុមារចូលរួមផ្តល់សម្ភាស ក្នុងការសិក្សាស្រាវជ្រាវប្រតិបត្តិ អ្នកស្រាវជ្រាវត្រូវយកចិត្តទុកដាក់គោរពរាល់គោលការណ៍ក្រមសីលធម៌។

ឧទាហរណ៍៖ យើងមិនត្រូវគ្រប់គ្រង ឬបង្ខំកុមារឱ្យផ្តល់ព័ត៌មានដល់ដំណើរការស្រាវជ្រាវនោះទេ។ អ្នកស្រាវជ្រាវមិនត្រូវបន្លំឱ្យកុមារឆ្លើយតបតាមវិធីណាមួយឡើយ ហើយត្រូវតែសម្ភាសកុមារជាក្រុមតូចដែរ។ តាមរយៈការទទួលបានការព្រមព្រៀងក្នុងការស្រាវជ្រាវ កុមារត្រូវតែដឹងច្បាស់ពីបញ្ហាស្រាវជ្រាវ ហើយអ្នកស្រាវជ្រាវ ត្រូវតែពន្យល់ឱ្យបានច្បាស់ថែមទៀត។ ឪពុកម្តាយ ឬអ្នកថែទាំកុមារ ក៏ត្រូវផ្តល់ការព្រមព្រៀងក្នុងការអនុញ្ញាតឱ្យកុមារចូលរួមសម្ភាសផងដែរ។



# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន

បច្ចេកទេសគន្លឹះ នៃការស្រាវជ្រាវប្រតិបត្តិ គឺជាការណែនាំឱ្យធ្វើការស្រាវជ្រាវដោយខ្លួនឯងដែលបង្ហាញថា ការស្រាវជ្រាវប្រតិបត្តិអាចធ្វើឱ្យមនុស្សមានសមត្ថភាពធ្វើការស្រាវជ្រាវតាមរយៈការសហការគ្នា ដើម្បីលើកកម្ពស់ជីវិតការងារ ដោយស្វែងរកបញ្ហានៅកន្លែងធ្វើការ និងរកភស្តុតាងដែលអាចជឿទុកចិត្ត និងអនុវត្តបាន ដើម្បីឱ្យមានការប្រែប្រួលជាវិជ្ជមាន។ សៀវភៅនេះបង្ហាញថា នរណាក៏អាចធ្វើការស្រាវជ្រាវប្រតិបត្តិបានដែរ មិនចាំបាច់តែអ្នកសិក្សា ឬ និស្សិតសាកលវិទ្យាល័យនោះឡើយ។ លើសពីនេះទៀត គោលបំណងនៃសៀវភៅបង្ហាញថា អ្នកគ្រប់គ្នាអាចធ្វើការស្រាវជ្រាវប្រតិបត្តិបានតាមរយៈការណែនាំអំពីដំណើរការស្រាវជ្រាវជាជំហានៗ រួមទាំងឧទាហរណ៍ ជាច្រើនពីស្ថានភាពជាក់ស្តែងដែលកើតឡើងក្នុងជីវិតពិត។ រាល់ជំហាននីមួយៗ បានអធិប្បាយ និងពន្យល់យ៉ាងលម្អិតអំពីសកម្មភាពដែលអ្នកស្រាវជ្រាវត្រូវធ្វើគឺដើម្បីបំពេញឱ្យគ្រប់ដំណាក់កាលនៃការសិក្សាស្រាវជ្រាវ។ សៀវភៅនេះក៏បានបង្ហាញ និងលើកឡើងពីបញ្ហាសំខាន់ៗ នៃឥរិយាបថប្រកបដោយក្រមសីលធ៌ម ដែលអ្នកស្រាវជ្រាវ ត្រូវតែធ្វើការអង្កេតថាតើពួកគេកំពុងធ្វើការស្រាវជ្រាវជាមួយនឹងមនុស្សពេញវ័យ ឬ កុមារ។ នេះជារឿងសំខាន់សម្រាប់ ការស្រាវជ្រាវលើបញ្ហានៃការរិភាគការផាត់ចេញពីសង្គម និងយេនឌ័រ ដែលអ្នកចូលរួមអាចជាជនងាយរងគ្រោះ ឬក្រុមមកពីសហគមន៍ ដែលត្រូវគេរើសអើង មិនអើពើ និងមិនបានផ្តល់ឱកាស ឱ្យបញ្ចេញមតិក្នុងការពិភាក្សាដើម្បីកំណត់ពីអនាគតរបស់ពួកគេ។

សៀវភៅនេះ មានគោលបំណងបង្ហាញពីភាពបត់បែននៃការស្រាវជ្រាវប្រតិបត្តិ ប្រភេទ និងវិសាលភាព ដែលអាចផ្លាស់ប្តូរពីការសិក្សាស្រាវជ្រាវខ្នាតតូចទៅជាការសិក្សាស្រាវជ្រាវខ្នាតធំដោយផ្តោតលើការប្រែប្រួលជាលក្ខណៈស្ថាប័នទាំងមូល។ ពេលវេលាសម្រាប់ធ្វើការស្រាវជ្រាវមានភាពបត់បែននិងអាចធ្វើការសម្របទៅតាមតម្រូវការការស្រាវជ្រាវ ដែលអាចធ្វើត្រឹមតែ ២ ទៅ ៣ សប្តាហ៍ ឬ ត្រឹម ២ ទៅ ៣ ខែក៏បាន។

សម្រាប់មន្ត្រីអប់រំ នៅកម្រិតសាលារៀន ការិយាល័យ ឬមន្ទីរអេយក. សៀវភៅនេះនឹងផ្តល់នូវវិធីសាស្ត្រជាក់ស្តែង ដើម្បីស្វែងរកភស្តុតាងរឹងមាំ ដែលអាចបញ្ចូលទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រអប់រំ ព្រមទាំងការធ្វើការសម្រេចចិត្ត។ ឧទាហរណ៍នៃក្របខណ្ឌពេលវេលា ត្រូវបានដាក់បញ្ចូលសម្រាប់ជំនួយដល់ការគ្រប់គ្រងពេលវេលា ដែលអាចធ្វើឱ្យការស្រាវជ្រាវប្រតិបត្តិបញ្ចប់ទាន់ពេល ដើម្បីអាចយកលទ្ធផលដាក់បញ្ចូលក្នុងផែនការ។

ការស្រាវជ្រាវប្រតិបត្តិនេះ គឺជាមគ្គទេសក៍ដ៏សំខាន់ ដើម្បីអភិវឌ្ឍសមត្ថភាពដល់មន្ត្រីអប់រំ

និងមន្ត្រីរដ្ឋបាលអប់រំនៅគ្រប់លំដាប់ថ្នាក់ព្រមទាំងដើរតួនាទីបង្ហាញផ្លូវសម្រាប់ឆ្លុះបញ្ចាំងពីសកម្មភាព ការអនុវត្ត និងបំណងប្រាថ្នា ដើម្បីធ្វើអន្តរាគមន៍ប្រកបដោយជោគជ័យ។ ជាចុងក្រោយ យើងសង្ឃឹមថា សៀវភៅនេះនឹងលើកទឹកចិត្តដល់អ្នកដែលចង់ធ្វើឱ្យមានការប្រែប្រួលជាក់ស្តែង និងយូរអង្វែង ដើម្បីក្លាយទៅជាអ្នកស្រាវជ្រាវសកម្មដោយការប្តេជ្ញាចិត្ត ដើម្បីធ្វើឱ្យមានការប្រែប្រួល និងវឌ្ឍនភាព។

# ឧបសម្ព័ន្ធ ១

## ការវិភាគលើការផាត់ចេញពីសង្គម និងយេនឌ័រ (SEGA)

ឧបសម្ព័ន្ធនេះ មានគោលដៅពន្យល់ពីចំណេះដឹងមូលដ្ឋានខ្លះៗ ទៅលើអត្ថន័យនៃការផាត់ចេញពីសង្គម ប្រភេទនៃការផាត់ចេញពីសង្គម ក៏ដូចជាការផ្តល់នូវគន្លឹះខ្លះៗ ក្នុងការប្រើចំណេះដឹងសម្រាប់ការពិចារណាលើបញ្ហានៃការស្រាវជ្រាវប្រតិបត្តិ។ ការវិភាគការផាត់ចេញពីសង្គម និងយេនឌ័រ គឺជាប្រធានបទដ៏ធំមួយដែលមិនអាចបរិយាយតែមួយទំព័របានទេ។



### តើអ្វីទៅជាការផាត់ចេញពីសង្គម?

ការផាត់ចេញពីសង្គមនឹងកើតមាននៅពេលដែលបុគ្គល ឬក្រុមណាមួយ មិនអាចចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច សង្គម នយោបាយ និងវប្បធម៌ក្នុងសង្គមដែលពួកគេរស់នៅ។ ក្រុមដែលត្រូវគេរើសអើងអាចនឹងត្រូវធ្លាក់ចូលក្នុង ផ្នែកណាមួយនៃការផាត់ចេញពីសង្គម។ ក្រុមទាំងនេះអាចនឹងត្រូវបានគេបដិសេធនូវឱកាសចូលរួមក្នុងគ្រឹះស្ថានសិក្សា និងស្ថាប័នសាធារណៈ។ ពួកគេអាចនឹងត្រូវបានដកហូតនូវសិទ្ធិផ្ទាល់ខ្លួន និងការសម្រេចចិត្តសំខាន់ៗ ដែលនាំឱ្យគេមានអារម្មណ៍ថានៅដាច់ឆ្ងាយ និងជាមនុស្សអន់ជាងគេក្នុងសង្គម។

### ប្រភេទនៃការផាត់ចេញពីសង្គម៖

**សេដ្ឋកិច្ច**
- នគរូបនីយកម្ម
- ការងារ
- ប្រាក់ចំណូល
- ការអប់រំ

**វប្បធម៌**
- ក្រុមសីលធម៌
- យេនឌ័រ
- ភាសា
- ជំនាន់
- សាសនា

**បុគ្គល**
- សុខុមាលភាពផ្លូវចិត្ត
- សុខុមាលភាពផ្លូវកាយ
- គុណតម្លៃ

**សង្គម**
- បណ្តាញចំណង់ចំណូលចិត្ត
- បណ្តាញទំនាក់ទំនង

**នយោបាយ**
- ការចូលរួមក្នុងវិស័យស៊ីវិល
- ការចូលរួមនយោបាយ

ជាពិសេស មនុស្សអាចនឹងមានអារម្មណ៍ផាត់ចេញពីសង្គមក្នុងស្ថានភាពទាំង ៧ ដូចខាងក្រោម៖

១- យេនឌ័រ
២- ពិការភាព
៣- សាសនា
៤- ទំនោរផ្លូវភេទ (Lesbian, Gay, Bisexual, Transgender & Queer)
៥- ពូជសាសន៍
៦- ស្ថានភាពការងារ
៧- ទីតាំងភូមិសាស្ត្រ

សូមជ្រើសរើសយកបញ្ហាការវិភាគការផាត់ចេញពីសង្គម និងយេនឌ័រណាមួយ
សម្រាប់ការស្រាវជ្រាវប្រតិបត្តិដែលអ្នកអាចធ្វើបាន!



ក្នុងសង្គមសេរី និងប្រជាធិបតេយ្យការចូលរួមនិងការសម្រេចចិត្តគឺជាដំណើរការនៃការផ្ដល់អំណាចមួយដែលមានឥទ្ធិពលទៅលើជីវិតរបស់អ្នក។ ការចូលរួមនេះបង្កើតឱ្យមានទំនុកចិត្ត និងបណ្ដុះស្មារតីក្នុងការបញ្ចេញមតិ។ទន្ទឹមនឹងនេះក្រុមដែលបាត់បង់ឱកាសអាចធ្វើឱ្យមានការប្រែប្រួលនូវឥរិយាបថ បទដ្ឋានស្ថាប័ន និងគោលនយោបាយដែលធ្វើឱ្យការផាត់ចេញពីសង្គម ប្រែទៅជាការផ្លាស់ប្ដូររចនាសម្ព័ន្ធរយៈពេលវែង និងការលុបបំបាត់នូវស្ថានភាពការផាត់ចេញពីសង្គមតាមរយៈដំណើរការនៃការចូលរួម និងភាពមានឥទ្ធិពល។

ក្នុងបរិបទនេះ ការជ្រើសរើសបញ្ហាការវិភាគការផាត់ចេញពីសង្គម និងយេនឌ័រ យកមកធ្វើការស្រាវជ្រាវប្រតិបត្តិ ដោយប្រើប្រាស់សៀវភៅណែនាំនេះគឺជាជំហានវិជ្ជមានមួយ។ ខណៈពេលជ្រើសរើសបញ្ហានៅកម្រិតណាមួយមកវិភាគ អ្នកគួរតែចាំថា គ្រប់បញ្ហាតែងតែពាក់ព័ន្ធទៅនឹងការផាត់ចេញពីសង្គម និងយេនឌ័រ។ ចូរមើលថាតើ ការវិភាគការផាត់ចេញពីសង្គម និងយេនឌ័រ អាចជះឥទ្ធិពលដល់ការអប់រំគ្រប់កម្រិតដោយរបៀបណា ហើយតើយើងអាចបង្កើតសំណួរស្រាវជ្រាវពីបញ្ហាការផាត់ចេញពីសង្គម និងយេនឌ័រយ៉ាងដូចម្ដេច។

## កម្រិតសាលារៀន

១- តើយើងអាចបង្កើនការចូលរួមការអប់រំរបស់កុមារក្នុងសហគមន៍ណាមួយ
(ភាសា សាសនា និងសេដ្ឋកិច្ចសង្គម) ដោយរបៀបណា?

២- តើយើងអាចពង្រឹងការសិក្សារបស់កុមារដែលមកពីក្រុមបាត់បង់ឱកាស និងមានសាវតារដែលត្រូវបានផាត់ចេញពីសង្គមដោយរបៀបណា?

**កម្រិតមន្ទីរអេយក. ឬ ការិយាល័យអេយក.**

១- តើយើងអាចបង្កើនការចុះឈ្មោះចូលរៀន និងទប់ស្កាត់មិនឱ្យបោះបង់ការសិក្សារបស់កុមារក្នុងសហគមន៍ងាយរងគ្រោះ (ភាសា សាសនា សេដ្ឋកិច្ចសង្គម និង ក្រុមជនជាតិដើមភាគតិច) ដោយរបៀបណា?

២- តើយើងអាចពង្រឹងការសិក្សាលើមុខវិជ្ជាសំខាន់ៗ (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ក្នុងចំណោមកុមារដែលមកពីក្រុមមានភាសា សាសនា និងសេដ្ឋកិច្ចសង្គម ភាគតិច ដោយរបៀបណា?

បញ្ហាស្រដៀងគ្នានេះ ក៏អាចត្រូវបានកំណត់នៅកម្រិតនាយកដ្ឋាន និងស្ថាប័ន។

# *ឧបសម្ព័ន្ធ ២*

# គំរូសម្រាប់សរសេររបាយការណ៍ផ្អែកលើការសិក្សាស្រាវជ្រាវប្រតិបត្តិរបស់អ្នក

**ចំណងជើង៖** *សូមសរសេរសំណួរនៃការស្រាវជ្រាវប្រតិបត្តិរបស់អ្នកនៅទីនេះ*

**ឈ្មោះអ្នកស្រាវជ្រាវ៖** *សូមសរសេរឈ្មោះអ្នកនៅទីនេះ*

**កាលបរិច្ឆេទ៖** *សូមសរសេរកាលបរិច្ឆេទនៃការប្រគល់របាយការណ៍នៅទីនេះ*

## I. សេចក្តីផ្តើម

### សនិទានកម្ម

ក្នុងផ្នែកនេះ អ្នកគប្បី៖

១- ពន្យល់ពីមូលហេតុដែលអ្នកជ្រើសរើសយកបញ្ហានេះមកស្រាវជ្រាវ ហើយតើមានអ្វីទាក់ទងនឹងបញ្ហានេះ ដែលទាក់ទាញអ្នក ឬ ធ្វើឱ្យអ្នកចង់ស្វែងយល់បន្ថែម។

២- ពន្យល់ពី «តម្រូវការ» ដើម្បីធ្វើការស្រាវជ្រាវ និងអ្វីដែលអ្នករំពឹងថានឹងទទួលបានក្រោយពេលការស្រាវជ្រាវបានបញ្ចប់ និងមានការប្រែប្រួលជាវិជ្ជមាន។

### ធ្វើការពិនិត្យលើឯកសារពាក់ព័ន្ធប្រធានបទ

ក្នុងផ្នែកនេះ អ្នកគប្បី៖

១- សរសេរពីព័ត៌មានណាមួយដែលអ្នកបានរកឃើញ ដែលពាក់ព័ន្ធនឹងការស្រាវជ្រាវរបស់អ្នក ដូចជាផែនការសាលារៀន ទិន្នន័យពីស្រុក ផែនការប្រតិបត្តិប្រចាំឆ្នាំនៃការិយាល័យអយក. ឬ មន្ទីរអយក. អត្ថបទកាសែត កលិកបត្រ។ល។

២- រៀបរាប់ព័ត៌មានអ្វីខ្លះដែលអ្នកអាចប្រមូលបានពីឯកសារទាំងនោះ និងព័ត៌មានដែលជួយគាំទ្រដល់ការស្រាវជ្រាវរបស់អ្នក។

## II. វិធីសាស្ត្រប្រមូលព័ត៌មាន

ក្នុងផ្នែកនេះអ្នកគប្បី៖

១- ពន្យល់ថាតើអ្នកជ្រើសរើសអ្នកចូលរួមផ្តល់សម្ភាសក្នុងការស្រាវជ្រាវដោយរបៀបណា ហើយហេតុអ្វីបានជាអ្នកជ្រើសរើសពួកគេ?

២- ពន្យល់ឧទាហរណ៍៖ តើអ្នកធ្វើដូចម្តេច ដើម្បីទាក់ទងអ្នកចូលរួមផ្តល់សម្ភាសទាំងអស់នេះនិងធានាថាការជ្រើសរើសរបស់អ្នកមានតុល្យភាពយេនឌ័រ (ឬ បើមិនដូច្នោះទេ សូមពន្យល់ពីមូលហេតុដែលមិនមានតុល្យភាពយេនឌ័រ)?

៣- តើអ្នកជួបអ្នកចូលរួមផ្តល់សម្ភាសនៅកន្លែងណា ពេលណា ហើយអ្នកបានជួបពួកគេប៉ុន្មានដង?

៤- តើអ្នកចូលរួមផ្តល់សម្ភាសរបស់អ្នកមានបញ្ហាអ្វី ដែរឬទេ?

៥- តើអ្នកធានាថាពួកគេបានយល់ព្រមចូលរួមផ្តល់សម្ភាស ហើយមានអ្នកដកខ្លួនដែរឬទេ?

៦- តើពួកគេមានចំណាប់អារម្មណ៍លើការស្រាវជ្រាវរបស់អ្នក ដែរឬទេ? តើពួកគេបានចូលរួមឆ្លើយសំណួរគន្លឹះបានល្អ ដែរឬទេ?

៧- បន្ទាប់មក អ្នកត្រូវពិពណ៌នាវិធីសាស្ត្រនៃការប្រមូលទិន្នន័យ និងមូលហេតុដែលអ្នកជ្រើសរើសវិធីសាស្ត្រទាំងនេះដូចជា ការសម្ភាសផ្ទាល់ (មានអ្នកចូលរួមប៉ុន្មាននាក់ក្នុងការសម្ភាស) ការពិភាក្សាក្រុម សម្ភាសតាមទូរស័ព្ទ សារអេឡិចត្រូនិច កម្រងសំណួរ។ល។ (បើអ្នកប្រើប្រាស់ កម្រងសំណួរ អ្នកត្រូវរៀបរាប់ថាតើអ្នកបង្កើត និងសាកល្បងកម្រងសំណួរដោយរបៀបណា)។

៨- សូមពន្យល់ ប្រសិនបើ អ្នកមានបញ្ហាជាមួយនឹងវិធីសាស្ត្រ។

៩- អ្នកត្រូវពន្យល់ពីរបៀបដែលអ្នកកត់ត្រាព័ត៌មានដែលបានប្រមូល។ តើអ្នកបានថតសំឡេងសម្ភាស ការពិភាក្សាក្រុមដែរឬទេ? តើអ្នកបានកត់សម្គាល់ចំណុចសំខាន់ៗដែរឬទេ? តើមានការលំបាកអ្វីខ្លះ?

១០- មុននឹងអ្នកបញ្ចប់ផ្នែកនេះ អ្នកត្រូវតែរៀបរាប់ថា តើអ្នកបានអង្កេតលើគោលការណ៍ទាំងប្រាំនៃក្រមសីលធម៌ក្នុងការស្រាវជ្រាវ ដែរឬទេ?

## III. លទ្ធផល និងការពិភាក្សាដោយប្រើប្រាស់ការវិភាគទិន្នន័យ

ក្នុងផ្នែកនេះ អ្នកគប្បី៖

១- ពិនិត្យមើលលទ្ធផលស្រាវជ្រាវ (ទិន្នន័យមិនទាន់វិភាគ) វិភាគព័ត៌មាននិងសិក្សាឯកសារ បន្ទាប់មកស្វែងយល់ពីខ្លឹមសារទាំងនោះ។ ការវិភាគនេះ នឹងធ្វើឱ្យដឹងថា តើអ្នកបានឆ្លើយសំណួរស្រាវជ្រាវហើយឬនៅ និងថាតើអ្នកបានធ្វើឱ្យមានផលជះវិជ្ជមាន ដែរឬទេ។

២- សូមសរសេរថាតើអ្នកអាចកំណត់លំនាំ ឬគំនិតសំខាន់ណាមួយពីលទ្ធផលស្រាវជ្រាវ ដែរឬទេ?

៣- សូមសរសេរពីអ្វីដែលអ្នកចូលរួមផ្តល់សម្ភាសបាននិយាយ ថាតើពួកគេទាំងអស់គ្នាផ្តល់ចម្លើយដូចគ្នា ឬខុសគ្នា? តើហេតុអ្វីបានជាដូច្នេះ?

៤- តើមានការបែងចែកយេនឌ័រ ឬ អាយុ ដែរឬទេ?
៥- ប្រសិនបើអ្នកបានសរសេរបានច្បាស់លាស់ និងស្មោះត្រង់អំពីអ្នកចូលរួមផ្តល់សម្ភាស ហើយអ្នកបានយល់ពីពួកគេ នោះការស្រាវជ្រាវរបស់អ្នកនឹងត្រូវបានចាត់ទុកថា អាចជឿទុកចិត្តបាន។
៦- សូមសរសេរពីការឆ្លុះបញ្ចាំងថា តើអ្នកធ្វើការជាមួយនឹងអ្នកចូលរួមផ្តល់សម្ភាសដោយរបៀបណា មានទំនាក់ទំនងបែបណា ហើយវត្តមានក្នុងនាមជាអ្នកស្រាវជ្រាវ តើអ្នកអាចមានឥទ្ធិពលលើការស្រាវជ្រាវយ៉ាងដូចម្តេច?
៧- សូមសរសេរអំពីអ្វីដែលធ្វើឱ្យអ្នកភ្ញាក់ផ្អើល ឬអ្វីដែលខុសពីគំនិតដំបូងរបស់អ្នក។ តើការសន្មតរបស់អ្នកពីមុនមកផ្ទុយពីអ្វីជាក់ស្តែង ដែរឬទេ?

## IV. ចំណុចខ្លាំង និងចំណុចខ្សោយនៃការស្រាវជ្រាវ

នៅក្នុងផ្នែកនេះអ្នកត្រូវសរសេរអំពី៖
១- អ្វីដែលបានដំណើរការល្អក្នុងការស្រាវជ្រាវរបស់អ្នក
២- អ្វីដែលអ្នកគិតថាអាចកែលម្អបាន ប្រសិនបើអ្នកធ្វើវាម្តងទៀតនេះ គឺជា «ការពិនិត្យនិងវាយតម្លៃ» នៃរបាយការណ៍របស់អ្នក។ អ្នកត្រូវតែស្មោះត្រង់និងពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយ។

## V. សេចក្តីសន្និដ្ឋាន

ក្នុងផ្នែកនេះអ្នកត្រូវសរសេរអំពី៖
១- តើអ្នកបានឆ្លើយសំណួរស្រាវជ្រាវយ៉ាងដូចម្តេច (សង្ឃឹមថាដូចការរំពឹងទុក)?
២- តើអ្នកទទួលបានការប្រែប្រួលជាវិជ្ជមានក្នុងការអនុវត្តការងារនៅកន្លែងធ្វើការ ឬ អង្គភាពរបស់អ្នកដោយរបៀបណា?

# ឧបសម្ព័ន្ធ ៣

## សេចក្តីយល់ព្រមចូលរួមក្នុងការស្រាវជ្រាវ

- ខ្ញុំ..............................យល់ព្រមដោយស្ម័គ្រចិត្តលើការចូលរួមក្នុងការស្រាវជ្រាវនេះ។
- ខ្ញុំយល់ថា ទោះបី ខ្ញុំយល់ព្រមចូលរួមនៅពេលនេះក៏ដោយ ខ្ញុំអាចដកខ្លួន ឬ បដិសេធមិនឆ្លើយនឹងសំណួរណាមួយបានគ្រប់ពេល ដោយមិនមានផលវិបាកណាមួយកើតឡើងឡើយ។
- ខ្ញុំយល់ថា ខ្ញុំអាចដកការអនុញ្ញាតឱ្យប្រើទិន្នន័យពីការសម្ភាសរបស់ខ្ញុំក្នុងរយៈពេលពីរសប្តាហ៍បន្ទាប់ពីការសម្ភាស ដែលក្នុងករណីនេះឯកសារ ឬទិន្នន័យនឹងត្រូវបានលុបចោល។
- ខ្ញុំត្រូវបានពន្យល់ជាមុនពីគោលបំណង និងធម្មជាតិនៃការស្រាវជ្រាវ ហើយខ្ញុំមានឱកាសសួរសំណួរអ្វីដែលខ្ញុំចង់ដឹងទាក់ទងនឹងការស្រាវជ្រាវ។
- ខ្ញុំយល់ថា ការចូលរួមគឺពាក់ព័ន្ធនឹងការចែករំលែកទស្សនៈ គំនិត និងការសង្កេត។
- ខ្ញុំយល់ថា ខ្ញុំនឹងមិនទទួលបានអត្ថប្រយោជន៍ដោយផ្ទាល់ពីការចូលរួមក្នុងការស្រាវជ្រាវនេះទេ។
- ខ្ញុំយល់ព្រមឱ្យថតជាសំឡេងក្នុងការសម្ភាសរបស់ខ្ញុំ។
- ខ្ញុំយល់ថា ព័ត៌មានទាំងអស់ដែលខ្ញុំផ្តល់ជូនសម្រាប់ការស្រាវជ្រាវនេះនឹងត្រូវរក្សាទុកជាការសម្ងាត់។
- ខ្ញុំយល់ថា នៅក្នុងរបាយការណ៍ណាមួយស្តីពីលទ្ធផលនៃការស្រាវជ្រាវនេះ អត្តសញ្ញាណរបស់ខ្ញុំនឹងនៅតែជាអនាមិកដដែល។ ការផ្លាស់ប្តូរឈ្មោះរបស់ខ្ញុំ និងលាក់បាំងពីព័ត៌មានលម្អិតនៃបទសម្ភាសន៍ណា ដែលអាចបង្ហាញពីអត្តសញ្ញាណរបស់ខ្ញុំ ឬ អត្តសញ្ញាណរបស់មនុស្សដែលខ្ញុំនិយាយដល់។
- ខ្ញុំយល់ថា ប្រសិនបើខ្ញុំជូនដំណឹងដល់អ្នកស្រាវជ្រាវថា ខ្លួនខ្ញុំ ឬ អ្នកផ្សេងទៀតអាចប្រឈមនឹងគ្រោះថ្នាក់ ពួកគេអាចនឹងរាយការណ៍ទៅអាជ្ញាធរដែលពាក់ព័ន្ធ។ អ្នកទាំងនោះ នឹងត្រូវពិភាក្សារឿងនេះជាមួយខ្ញុំជាមុនសិន ប៉ុន្តែ ពួកគេក៏អាចរាយការណ៍ដោយមាន ឬ គ្មានការអនុញ្ញាតក៏បាន។
- ខ្ញុំយល់ថា ខ្ញុំមានសេរីភាពក្នុងការទាក់ទងជាមួយមនុស្សណាម្នាក់ ដែលចូលរួមក្នុងការស្រាវជ្រាវដើម្បីស្វែងរកការបញ្ជាក់ និងព័ត៌មានបន្ថែម។

**កាលបរិច្ឆេទ៖ ថ្ងៃទី.........ខែ.............ឆ្នាំ.................**

**ហត្ថលេខាអ្នកចូលរួមស្រាវជ្រាវ៖**________________________________

**ហត្ថលេខាអ្នកស្រាវជ្រាវ៖**____________________________________

# ឧបសម្ព័ន្ធ ៤

## គំរូថវិកាសម្រាប់ការស្រាវជ្រាវប្រតិបត្តិ

**ឧទាហរណ៍ទី១៖** ការសិក្សាខ្នាតតូចដែលអនុវត្តដោយនាយកសាលា៖ តើយើងត្រូវគាំទ្រសិស្សឱ្យរៀនបន្តបន្ទាប់ពីថ្នាក់ទី ៦ ដោយរបៀបណា?

| ល.រ | សកម្មភាព/ បរិយាយ | អ្នកចូលរួម/ ខ្ទង់ចំណាយ | បរិមាណ | តម្លៃឯកតា ជាដុល្លារ | សរុប |
|---|---|---|---|---|---|
| ១ | ការសម្ភាស និង ការពិភាក្សាក្រុម | ឪពុកម្តាយសិស្ស និងសិស្ស | ១២ | $២.00 | $២៤.00 |
| ២ | ចំណាយផ្សេងៗ | ក្រដាស ទឹកថ្នាំ ហ្វឺត | ១ | $៥0.00 | $៥0.00 |
| | | | | សរុប | $៧៤.00 |

**ឧទាហរណ៍ទី២៖** ការសិក្សាខ្នាតតូចមួយដែលអនុវត្តដោយមន្ត្រីការិយាល័យអយក.៖ តើយើងត្រូវលើកទឹកចិត្តឪពុកម្តាយឱ្យយកកូនមកចុះឈ្មោះចូលរៀនក្នុងមត្តេយ្យសហគមន៍ដោយរបៀបណា?

| ល.រ | សកម្មភាព/ បរិយាយ | ចំនួនអ្នកចូលរួម/ឯកតា | តម្លៃឯកតាជាដុល្លារ | ចំនួនថ្ងៃ/ យប់/គ.ម | សរុប |
|---|---|---|---|---|---|
| ១ | ការស្នាក់នៅ | ២ | ២0 | ១ | $៤0.00 |
| ២ | ប្រាក់របបប្រចាំថ្ងៃ | ២ | ១៤ | ២ | $៥៦.00 |
| ៣ | ការធ្វើដំណើរ | ២ | 0.១ | ៤៥ | $៩.00 |
| ៤ | អាហារសម្រន់សម្រាប់ កិច្ចប្រជុំបច្ចេកទេស | ២0 | ២ | ១ | $៤0.00 |
| ៥ | សម្ភារៈសិក្សា និង ថតចម្លង | ១ | 50 | | $៥0.00 |
| | | | | សរុប | $១៩៥.00 |

**ឧទាហរណ៍ទី៣៖** ការសិក្សាស្រាវជ្រាវខ្នាតតូចដែលអនុវត្តដោយមន្ត្រីមន្ទីរអេយក៖ តើយើងគួរលើកកម្ពស់ការចូលរួម និងគណនេយ្យភាពក្នុងការអភិវឌ្ឍផែនការប្រតិបត្តិប្រចាំឆ្នាំដោយរបៀបណា ?

| ល.រ | សកម្មភាព/ បរិយាយ | ចំនួនអ្នកចូលរួម/ឯកតា | តម្លៃឯកតា ជាដុល្លារ | ចំនួនថ្ងៃ/ យប់/គ.ម | សរុប |
|---|---|---|---|---|---|
| ១ | ប្រាក់របបប្រចាំថ្ងៃ | ២ | ១៤ | ២ | $៥៦.00 |
| ២ | ការធ្វើដំណើរ | ២ | 0.១ | ៣៥ | $៧.00 |
| ៣ | អាហារសម្រន់សម្រាប់ការប្រជុំ | ១២ | ២ | ១ | $២៤.00 |
| ៤ | សម្ភារៈសិក្សា និងថតចម្លង | ១ | ៥0 | | $៥0.00 |
| | | | | សរុប | $១៣៧.00 |

# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## មហាវិទ្យាល័យអប់រំផ្តល់ការបណ្តុះបណ្តាលពីកម្រិតវិញ្ញាបនបត្រ ដល់បណ្ឌិតដូចខាងក្រោម៖

- វិញ្ញាបនបត្រអប់រំកុមារតូច
- វិញ្ញាបនបត្រអប់រំបឋមសិក្សា

- បរិញ្ញាបត្រអប់រំ ឯកទេសសិក្សាអប់រំ
- បរិញ្ញាបត្រអប់រំ ឯកទេសគ្រប់គ្រង និងអភិវឌ្ឍឧត្តមសិក្សា
- បរិញ្ញាបត្រអប់រំ ឯកទេសអប់រំពេញមួយជីវិត
- បរិញ្ញាបត្រអប់រំ វិជ្ជាជីវៈគ្រូបង្រៀន ឯកទេស អក្សរសាស្ត្រខ្មែរ ប្រវត្តិវិទ្យា គណិតវិទ្យា គីមី រូបវិទ្យា និងជីវវិទ្យា
- បរិញ្ញាបត្រអប់រំ ឯកទេសគ្រប់គ្រងអប់រំ
- បរិញ្ញាបត្រអប់រំ ឯកទេសកម្មវិធីសិក្សានិងការបង្រៀនកម្រិតកុមារតូច

- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ វិជ្ជាជីវៈគ្រូបង្រៀន ឯកទេស អក្សរសាស្ត្រខ្មែរ ប្រវត្តិវិទ្យា គណិតវិទ្យា គីមី រូបវិទ្យា និងជីវវិទ្យា
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសកម្មវិធីសិក្សា និងការបង្រៀន
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសសិក្សាអប់រំ
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសគ្រប់គ្រង និងអភិវឌ្ឍឧត្តមសិក្សា
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសអប់រំពេញមួយជីវិត

- បណ្ឌិតអប់រំ ឯកទេសគ្រប់គ្រងអប់រំ
- បណ្ឌិតអប់រំ ឯកទេសកម្មវិធីសិក្សា និងការបង្រៀន
- បណ្ឌិតអប់រំ ឯកទេសអភិវឌ្ឍការអប់រំ
- បណ្ឌិតអប់រំ ឯកទេសអភិវឌ្ឍធនធានមនុស្ស និងអប់រំពេញមួយជីវិត

**មហាវិទ្យាល័យអប់រំក៏មានផ្តល់សេវាប្រឹក្សាយោបល់ និងស្រាវជ្រាវអប់រំផងដែរ។**

សម្រាប់ព័ត៌មានបន្ថែម សូមស្កេនខាងក្រោម

www.facebook.com/rupp.edu.kh

www.rupp.edu.kh/fed/

Facebook Page
Faculty of Education